ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

# ក្របខ័ណ្ឌ
# គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា
# ឆ្នាំ២០១៦-២០៣០

**បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី**

**ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

*រាជរដ្ឋាភិបាលកម្ពុជា*

# ក្របខ័ណ្ឌ
# គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា
# ឆ្នាំ២០១៦-២០៣០

# ផ្នែកទី១ ការពិនិត្យមើលលទ្ធផល
# និងជំហានបន្ទាប់

**បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី**

**ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨**

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

# អារម្ភកថា

នៅក្រោមបាវចនា "ជាតិ សាសនា ព្រះមហាក្សត្រ" រាជរដ្ឋាភិបាលកម្ពុជាសម័យទំនើប បានបន្តអនុវត្តរបៀបវារៈអភិវឌ្ឍជាតិរបស់ខ្លួនប្រកបដោយចីរភាព និងបរិយាបន្ន ដោយបានខិតខំពង្រឹងសាមគ្គីភាពជាតិ ប្រជាជនកម្ពុជា ពីគ្រប់ស្រទាប់វណ្ណៈ ពីសម្ព័ន្ធនយោបាយ និងពីគ្រប់ជាតិសាសន៍ទាំងក្នុងនិងក្រៅប្រទេស ពូនផ្តុំជាធ្លុងមួយដើម្បីរក្សាការពារអធិបតេយ្យភាពនិងបូរណភាពទឹកដីពេញលេញ សន្តិភាព និងភាពសុខដុមរមនារបស់កម្ពុជា ព្រមទាំងដើម្បីអភិវឌ្ឍកម្ពុជាឲ្យទៅជាប្រទេសចំណូលខ្ពស់នៅឆ្នាំ២០៥០។

ក្នុងរយៈពេលជាងមួយទសវត្សរ៍កន្លងមកនេះ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) បានដើរតួជាឧបករណ៍មួយយ៉ាងសំខាន់សម្រាប់ការអនុវត្តកម្មវិធីនយោបាយនិងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលកំណត់នូវការប្តេជ្ញាចិត្តនិងទិសដៅជាយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចរបស់កម្ពុជា។ ផ្អែកលើមូលដ្ឋានទាំងនេះ កម្ពុជាសម្រេចបាននូវគោលដៅធំៗជាច្រើនដូចជា សន្តិភាព ស្ថិរភាពនយោបាយ វិបុលភាពសង្គម និងការកាត់បន្ថយភាពក្រីក្រឆាប់រហ័សដែលមិនធ្លាប់មានពីមុនមក។ ទន្ទឹមនឹងនេះ កម្ពុជាបានធ្វើមូលដ្ឋាននីយកម្មគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍សកលលោក មកក្នុងបរិការណ៍កម្ពុជា គឺ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា(គ.អ.ស.ក.) ហើយកម្ពុជាសម្រេចបានគោលដៅជាច្រើនមុនកាលកំណត់ឆ្នាំ២០១៥។

ក្នុងខែកញ្ញា ឆ្នាំ២០១៥ រាជរដ្ឋាភិបាលកម្ពុជា ជាមួយនឹងប្រទេសជាសមាជិកអង្គការសហប្រជាជាតិ នៅក្នុងសម័យប្រជុំប្រចាំឆ្នាំរបស់មហាសន្និបាតអង្គការសហប្រជាជាតិ បានអនុម័តរបៀបវារៈគោលដៅអភិវឌ្ឍប្រកបដោយចីរភាព (គ.អ.ច.) ២០១៦-២០៣០។ ក្នុងដំណាក់កាលថ្មីនេះ រាជរដ្ឋាភិបាលកម្ពុជាបានបន្តការខិតខំរបស់ខ្លួនដើម្បីធ្វើមូលដ្ឋាននីយកម្មគោលដៅសកលនៃ គ.អ.ច. ឱ្យស្របទៅនឹងបរិការណ៍កម្ពុជា ដែលហៅថា គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា (គ.អ.ច.ក.) ហើយ គ.អ.ច.ក នេះនឹងត្រូវបានធ្វើសមាហរណកម្មទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ ជាពិសេស ត្រូវប្រើជាធាតុចូលដ៏សំខាន់សម្រាប់រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣។ ក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា ត្រូវបានរៀបចំឡើងដោយឆ្លងកាត់កិច្ចប្រជុំពិភាក្សាជាច្រើនដងជាមួយក្រសួង ស្ថាប័នរាជរដ្ឋាភិបាល និងក្រុមការងារបច្ចេកទេសចម្រុះ និងបានបញ្ចូលការវាយតម្លៃរួមឆាប់រហ័ស ការធ្វើអាទិភាព គ.អ.ច. សកល

មកក្នុងបរិការណ៍កម្ពុជា ការវាយតម្លៃលើសូចនាករនិងប្រភពទិន្នន័យរបស់អង្គភាពស្ថិតិរបស់អង្គការសហប្រជាជាតិ។

រាជរដ្ឋាភិបាលកម្ពុជាបានកសាងមូលដ្ឋានគ្រឹះមួយប្រកបដោយភាពរឹងមាំ សម្រាប់គាំទ្រដល់ដំណើរការអភិវឌ្ឍជាតិ ជាពិសេស គឺនៅក្នុងដំណាក់កាលដែលកម្ពុជាបានក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប។ គ.អ.ច.ក. នឹងចូលរួមចំណែកកាន់តែសំខាន់សម្រាប់ផ្តល់ការណែនាំដល់អ្នករៀបចំគោលនយោបាយ និងជាមធ្យោបាយមួយដ៏ទូលំទូលាយសម្រាប់វាស់វែងលទ្ធផលនៃការអនុវត្ត។ រាជរដ្ឋាភិបាលកម្ពុជានឹងបន្តកិច្ចខិតខំកែទម្រង់ស៊ីជម្រៅបន្ថែមទៀត ដើម្បីបង្កើនប្រសិទ្ធភាពការងារ និងលទ្ធផលប្រកបដោយគុណភាព ព្រមទាំងជំរុញឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ រួមទាំងវិស័យឯកជន សង្គមស៊ីវិល អង្គការជាតិ អន្តរជាតិ និងដៃគូអភិវឌ្ឍនានា។

រាជរដ្ឋាភិបាលកម្ពុជាមានការប្តេជ្ញាចិត្តខ្ពស់ចំពោះ គ.អ.ច.ក. និងផ្អែកលើក្របខ័ណ្ឌនេះ យើងនឹងរៀបចំគោលនយោបាយនិងផែនការយុទ្ធសាស្ត្រនានាសម្រាប់អនុវត្ត ឲ្យស្របតាមកម្រិតធនធានថវិកា និងកំណត់យន្តការសម្រាប់តាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្ត។ គ.អ.ច.ក. នឹងចូលរួមចំណែកយ៉ាងសំខាន់ក្នុងការសម្រេចឱ្យបានចក្ខុវិស័យ ឆ្នាំ២០៥០ របស់រាជរដ្ឋាភិបាលកម្ពុជា និងពាំនាំមកនូវ ភាពរុងរឿង សាមគ្គីភាព ចំណេះដឹងខ្ពស់ ភាពរីកចម្រើន និងវប្បធម៌រស់រវើក ភាពគ្មានភាពក្រីក្រ ដោយប្រជាជនកម្ពុជាទាំងអស់រស់នៅក្នុងភាពសុខដុមរមនា។

ថ្ងៃសុក្រ ១៤ កើត ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ២០១៨

**ហ៊ុន សែន**

# តារាងមាតិកា

**អារម្ភកថា** ................................................ i

**តារាងមាតិកា** ................................................ iii

**បញ្ជីតារាង និង រូបភាព** ................................................ v

**សេចក្តីផ្តើម** ................................................ ១

**ជំពូកទី១ : ក្របខ័ណ្ឌគោលនយោបាយនិងបរិបទនៃការអភិវឌ្ឍ** ................................................ ៤

១.១- ក្របខ័ណ្ឌរៀបចំផែនការ ................................................ ៤

១.១.១- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ................................................ ៤

១.១.២- យុទ្ធសាស្ត្រចតុកោណ ................................................ ៥

១.១.៣- តួនាទីរបស់ គ.អ.ច.ក. ................................................ ៧

១.២- បរិការណ៍គោលនយោបាយសេដ្ឋកិច្ច ................................................ ៨

១.៣- បរិការណ៍សេដ្ឋកិច្ច សង្គមកិច្ច ................................................ ១២

**ជំពូកទី២ : លទ្ធផលនិងបទពិសោធពីការសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (គ.អ.ស.ក.)** ................................................ ១៥

២.១- សេចក្តីផ្តើម ................................................ ១៥

២.២- សេចក្តីសង្ខេបនៃការពិនិត្យមើលឡើងវិញ លទ្ធផលនៃការសម្រេចបាន គ.អ.ស.ក. ....... ១៦

២.៣- ការពិនិត្យមើលឡើងវិញ តាមគោលដៅនីមួយៗ ................................................ ១៨

២.៣.១- គោលដៅទី១ : ភាពក្រីក្រនិងភាពអត់ឃ្លានធ្ងន់ធ្ងរ ................................................ ១៨

២.៣.២- គោលដៅទី២ : សម្រេចឲ្យបានសកលកម្មអក្ខរកម្មនិងការអប់រំបឋមសិក្សា ....... ២០

២.៣.៣- គោលដៅទី៣ : លើកកម្ពស់សមភាពយេនឌ័រនិងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី .. ២២

២.៣.៤- គោលដៅទី៤ : កាត់បន្ថយមរណភាពកុមារ ................................................ ២៤

២.៣.៥- គោលដៅទី៥ : កាត់បន្ថយមរណភាពមាតា ................................................ ២៥

២.៣.៦- គោលដៅទី៦ : ការប្រយុទ្ធប្រឆាំងមេរោគអេដស៍ ជំងឺអេដស៍ ជំងឺគ្រុនចាញ់ និងជំងឺផ្សេងៗទៀត ................................................ ២៦

២.៣.៧- គោលដៅទី៧ : ជានាចីរភាពបរិស្ថាន ................................................ ២៧

២.៣.៨- គោលដៅទី៨ : បង្កើតភាពជាដៃគូជាសកលសម្រាប់កិច្ចអភិវឌ្ឍ ................................................ ៣៩

២.៣.៩- គោលដៅទី៩ : ការបោសសម្អាតមីន សំណល់ជាតិផ្ទុះពីសង្គ្រាម និងការសង្គ្រោះជនពិការដោយសារមីន ........ ៣០

២.៤- បញ្ហាចម្បងៗ : ការឆ្លើយតបនិងបទពិសោធដែលទទួលបាន ........ ៣២

២.៥- ការរៀបចំផែនការនិងបញ្ហាក្នុងការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ........ ៣៤

**ជំពូកទី៣ : ក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា** ........ ៣៨

៣.១- សេចក្តីផ្តើម ........ ៣៨

៣.២- ដំណើរការរៀបចំក្របខ័ណ្ឌ គ.អ.ច.ក. ........ ៣៨

៣.៣- ក្របខ័ណ្ឌ គ.អ.ច.ក. ដែលបានស្នើឡើង ........ ៤២

៣.៣.១- ទិដ្ឋភាពទូទៅនៃ គ.អ.ច.ក. ........ ៤២

៣.៣.២- ការប្រៀបធៀបជាមួយក្របខ័ណ្ឌសកល ........ ៤៣

៣.៤- បញ្ហាដែលនៅសេសសល់ ........ ៤៦

**ជំពូកទី៤ : បញ្ហាប្រឈមក្នុងការអនុវត្តគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា** ........ ៤៨

៤.១- សេចក្តីផ្តើម ........ ៤៨

៤.២- ការបញ្ចូល គ.អ.ច.ក. ទៅក្នុងប្រព័ន្ធផែនការនិងគោលនយោបាយជាតិ ៤៨

៤.២.១- សង្គតិភាពនិងភាពប្រទាក់ក្រឡាគ្នា ........ ៤៨

៤.២.២- ការធ្វើអាទិភាព គោលដៅ ចំណុចដៅ និងសកម្មភាព ........ ៥០

៤.៣- ការផ្តល់ធនធាននិងការជ្រើសរើសគោលដៅ ........ ៥១

៤.៤- ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ និងការផ្តល់យោបល់ផ្នែកគោលនយោបាយ ........ ៥៤

៤.៤.១- សមាសភាគសំខាន់ៗរបស់ការរៀបចំការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ........ ៥៤

៤.៤.២- ការធ្វើឲ្យប្រសើរឡើង ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃប្រព័ន្ធអេកូឡូស៊ី គ.អ.ច.ក. ........ ៥៦

**ជំពូកទី៥ : សេចក្តីសន្និដ្ឋាននិងជំហានបន្ទាប់** ........ ៥៧

៥.១- ការសន្និដ្ឋានគន្លឹះ ........ ៥៧

៥.២- ជំហានបន្ទាប់ ........ ៥៩

**ឧបសម្ព័ន្ធទី១ : ពាក្យបំព្រួញ** ........ ៦០

**ឧបសម្ព័ន្ធទី២ : គេហទំព័ររបស់ក្រសួង ស្ថាប័ន** ........ ៦១

**ឧបសម្ព័ន្ធទី៣ : គ.អ.ស.ក. និងសមិទ្ធផលនៃការសម្រេចបាន គ.អ.ស.ក.** ........ ៦៣

# បញ្ជីតារាង និង រូបភាព

## តារាង


តារាង ២.១ : សេចក្តីសង្ខេបពីការអនុវត្ត គ.អ.ស.ក. នៅកម្រិតចំណុចដៅ ........................ ១៧

តារាង ២.២ : ការអនុវត្តគោលដៅទី១ ........................................................................ ១៨

តារាង ២.៣ : ការអនុវត្តគោលដៅទី២ នៃ គ.អ.ស.ក. ................................................. ២១

តារាង ២.៤ : ការអនុវត្តគោលដៅទី៣នៃ គ.អ.ស.ក. ................................................... ២២

តារាង ២.៥ : ការអនុវត្តគោលដៅទី៤ នៃ គ.អ.ស.ក. ................................................. ២៤

តារាង ២.៦ : ការអនុវត្តគោលដៅទី៥ នៃ គ.អ.ស.ក. ................................................. ២៥

តារាង ២.៧ : ការអនុវត្តគោលដៅទី៦ នៃ គ.អ.ស.ក. ................................................. ២៧

តារាង ២.៨ : ការអនុវត្តគោលដៅទី៧ នៃ គ.អ.ស.ក. ................................................. ២៨

តារាង ២.៩ : ការអនុវត្តគោលដៅទី៩ នៃ គ.អ.ស.ក. ................................................. ៣១

តារាង ៣.១ : ការវាយតម្លៃរបស់អង្គភាពស្ថិតិរបស់អង្គការសហប្រជាជាតិស្តីពីស្ថានភាព សូចនាករ ........................................................................ ៤០

តារាង ៣.២ : ក្របខ័ណ្ឌ គ.អ.ច.ក. (ធៀបនឹងចំណុចដៅនិងសូចនាករ គ.អ.ច.សកល) ........ ៤៥

តារាង ៤.១ : ទំនាក់ទំនងរវាង គ.អ.ច.ក. និង អាទិភាព ផ.យ.អ.ជ. ................................ ៥១

# រូបភាព


រូបភាព១ : គោលដៅអភិវឌ្ឍប្រកបដោយចីរភាពសាកល ............................................ ១

រូបភាព ១.១ : គំនូសបំប្រួញយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ ................................ ៥

រូបភាព ១.២ : កំណើនផ.ស.ស. ........................................................................ ៩

រូបភាព ១.៣ : ការកៀរគរចំណូល (% នៃ ផ.ស.ស.) ................................................ ១០

រូបភាព ១.៤ : ចំណែកតម្លៃបន្ថែមតាមវិស័យ ...................................................... ១១

រូបភាពទី១.៥ : អត្រាភាពក្រីក្រ ២០០៤-២០១៤ ....................................................... ១២

រូបភាព ១.៦ : មេគុណជីនី ២០០៩-២០១៦ ............................................................ ១៣

រូបភាព ១.៧ : សន្ទស្សន៍នៃការអភិវឌ្ឍមនុស្ស .......................................................... ១៤

រូបភាព ២.១ : ការសម្រេចបាន គ.អ.ស.ក. តាមចំណុចដៅនិងសូចនាករ ............................ ១៦

រូបភាព ២.២ : ការប៉ាន់ស្មានពីអត្រាភាពក្រីក្រនៅតាមខេត្ត (ឆ្នាំ២០១៤) ............................. ២០

រូបភាព ២.៣ : គន្លងផ្លូវនិងចំណុចដៅរបស់គោលដៅទី១ នៃ គ.អ.ស. ................................. ៣៥

រូបភាព ៣.១ : ការវាយតម្លៃភាពបន្សុីគ្នារវាង គ.អ.ច.និងគោលនយោបាយនិងយុទ្ធសាស្ត្រជាតិ ៣៩

រូបភាព ៣.២ : ការវាយតម្លៃសូចនាករ ..................................................................... ៤០

រូបភាព ៣.៣ : តារាងទី១និងទី២ ............................................................................ ៤២

រូបភាព ៣.៤ : ចំណុចដៅរបស់ គ.អ.ច.ក. និង គ.អ.ច. សាកល (តាមគោលដៅ) .................. ៤៣

រូបភាព ៣.៥ : សូចនាកររបស់ គ.អ.ច.ក. និង គ.អ.ច. សាកល (តាមគោលដៅ) .................. ៤៤

រូបភាព ៣.៦ : ការប្រែប្រួលនៃចំណុចដៅនិងសូចនាករ គ.អ.ច.ក. ធៀបនឹង គ.អ.ច, សាកល (តាមគោលដៅ) .................................................................................... ៤៥

រូបភាព ៤.១ : ចំណុចប្រសព្វជាមួយក្របខ័ណ្ឌនៃការរៀបចំផែនការ ................................ ៤៨

រូបភាព ៤.២ : ចំណោលលំហូរហិរញ្ញវត្ថុ ដល់ឆ្នាំ២០២៥ (សេណារីយ៉ូ ទាបនិងខ្ពស់) ............ ៥៣

# សេចក្តីផ្តើម

គោលដៅអភិវឌ្ឍប្រកបដោយចីរភាព(គ.អ.ច.) ដែលត្រូវបានអនុម័តដោយមហាសន្និបាតរបស់អង្គការសហប្រជាជាតិក្នុងឆ្នាំ២០១៥ គឺជារបៀបវារៈអភិវឌ្ឍមួយដែលមានលក្ខណៈទូលំទូលាយ និងបានកំណត់អាទិភាពថ្មីៗទាក់ទងនឹងតម្រូវការអភិវឌ្ឍនិងទិសដៅនានារបស់សកលលោក។ គ.អ.ច. មានអាទិភាពសាកលសំខាន់ពីរ គឺការធានានូវចីរភាពបរិស្ថាន(ជាពិសេស ការគំរាមកំហែងដែលបង្កឡើងដោយការប្រែប្រួលអាកាសធាតុ)និងការកាត់បន្ថយភាពក្រីក្រ។ គ.អ.ច. បានបង្កើនរហូតដល់ចំនួន១៧គោលដៅនិង១៦៩ចំណុចដៅ ដែលផ្តោតខ្លាំងលើការកាត់បន្ថយវិសមភាពឲ្យបានទាំងស្រុង ខណៈដែលគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ មានចំនួន៨គោលដៅ និង ៤៨ចំណុចដៅ។

ជារួម គ.អ.ច. មានគោលបំណងធ្វើឲ្យមានការវិវឌ្ឍឈានទៅរកការអភិវឌ្ឍប្រកបដោយចីរភាពសម្រាប់ប្រទេសទាំងអស់ ដោយផ្តល់ជាការណែនាំសម្រាប់ជម្រើសគោលនយោបាយនិងជាមធ្យោបាយក្នុងការត្រួតពិនិត្យវឌ្ឍនភាពជាតិ។ គ.អ.ច. ទទួលស្គាល់នូវសារៈសំខាន់នៃសមធម៌នៅក្នុងប្រទេស និងរវាងប្រទេសនិងប្រទេស តម្រូវការជាសាកល និងសិទ្ធិរបស់មនុស្ស ព្រមទាំងអន្តរទំនាក់ទំនងនៃភាពប្រឈមក្នុងការអភិវឌ្ឍ។ គោលដៅទាំង១៧ត្រូវបានរៀបចំជា៥ក្រុម គឺសន្តិភាព ប្រជាជន ផែនដី វិបុលភាព និងភាពជាដៃគូ (5Ps- Peace, People, Planet, Prosperity, and Partnership) ដែលមានភាពប្រទាក់ក្រឡាគ្នា (រូបភាព ១)។

**រូបភាព១ : គោលដៅអភិវឌ្ឍប្រកបដោយចីរភាពសាកល**





*ប្រភព : អង្គការសហប្រជាជាតិទទួលបន្ទុកគោលដៅអភិវឌ្ឍ*

គ.អ.ច. ត្រូវបានបង្កើតឡើងដោយបានគិតគូរបន្តពីគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍។ គោលដៅថ្មីៗរបស់ គ.អ.ច. ផ្តោតសំខាន់លើការអភិវឌ្ឍសម្រាប់ប្រជាជនគ្រប់រូបនិងគ្រប់ប្រទេសទាំងអស់ ដោយតម្រូវមិនឲ្យបោះបង់ប្រជាជនណាម្នាក់ ឬប្រទេសណាមួយនៅក្រៅការអភិវឌ្ឍ(នៅឯកោ)នោះទេ តាមរយៈការចូលរួមពីគ្រប់ដៃគូពាក់ព័ន្ធរួមមាន រដ្ឋាភិបាល វិស័យសាធារណៈ វិស័យឯកជន ព្រមទាំង

ប្រជាជនខ្លួនឯងផ្ទាល់ និងធានាភាពជាម្ចាស់និងការដឹកនាំដោយប្រទេសនីមួយៗ ជាពិសេស ផ្អែកលើអាទិភាពធនធាននិងសមត្ថភាពរបស់ខ្លួន។ ការសម្រេចបាននូវ គ.អ.ច. គឺ ពឹងផ្អែកខ្លាំងលើការដឹកនាំនិងប្រភពធនធានរបស់ប្រទេសនីមួយៗ ជាងការពឹងផ្អែកលើការផ្តល់ជំនួយអភិវឌ្ឍផ្លូវការថ្មីៗបន្ថែមទៀត ជាពិសេស ប្រទេសជាសមាជិកត្រូវធ្វើមូលដ្ឋាននីយកម្មគោលដៅទាំងអស់ ដើម្បីគាំទ្ររបៀបវារៈអភិវឌ្ឍរបស់ខ្លួន និងការពង្រឹងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាពប្រកបដោយប្រសិទ្ធភាព។ ប្រទេសនីមួយៗមានសិទ្ធិពេញលេញក្នុងការទទួលយកក្របខ័ណ្ឌសាកលក្នុងករណីដែលពិនិត្យឃើញថាគោលដៅ ចំណុចដៅ និងសូចនាករមានភាពសមស្របទៅតាមបរិការណ៍នៃប្រទេសខ្លួន។

កម្ពុជាបានចាប់ផ្តើមរៀបចំដំណើរការធ្វើមូលដ្ឋានីយកម្មរបស់ខ្លួនក្នុងចុងឆ្នាំ២០១៥ ដោយធ្វើការពិនិត្យនិងរៀបចំគោលដៅ ចំណុចដៅ និងសូចនាករសកលឲ្យស្របតាមអាទិភាពជាតិ។ ប្រទេសកម្ពុជាបានជ្រើសរើសយកគោលដៅទាំង១៧ នៃ គ.អ.ច. និងបន្ថែមគោលដៅមួយទៀតគឺ *"បញ្ចប់ផលប៉ះពាល់ជាអវិជ្ជមានរបស់គ្រាប់មីននិងសំណល់ពីសង្គ្រាម និងជំរុញការសង្គ្រោះជនរងគ្រោះ"* ដែលឆ្លុះបញ្ចាំងពីអាទិភាពជាតិក្នុងការបោសសម្អាតគ្រាប់មីននៅក្នុងប្រទេស។ ដូចនេះ គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា(គ.អ.ច.ក.) មានគោលដៅចំនួន១៨ ចំណុចដៅចំនួន៨៨ និងសូចនាករសរុបចំនួន១៤៨ ក្នុងនោះ សូចនាករថ្នាក់ជាតិមានចំនួន៩៦។ ទន្ទឹមនឹងនេះ ក្របខ័ណ្ឌសម្រាប់តាមដានត្រួតពិនិត្យសូចនាកររបស់ គ.អ.ច.ក ត្រូវបានរៀបចំឡើងដូចបានពិពណ៌នានៅក្នុងជំពូកទី៣ និងរៀបរាប់លម្អិតនៅក្នុងតារាងទី១និងតារាងទី២នៃផ្នែកទី២នៃឯកសារនេះ។ រាជរដ្ឋាភិបាលកម្ពុជាមិនទាន់បានបញ្ជាក់ជាផ្លូវការចំពោះការធ្វើការត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្តនៅឡើយទេ ប៉ុន្តែគ្រោងនឹងធ្វើក្នុងឆ្នាំ២០១៩។

ក្របខ័ណ្ឌ គ.អ.ច.ក. រួមជាមួយកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលដែលផ្តល់ការតម្រង់ទិសរួមដោយយុទ្ធសាស្ត្រចតុកោណ នឹងធ្វើជាមូលដ្ឋានសំខាន់សម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(ផ.យ.អ.ជ.)។ ក្របខ័ណ្ឌ គ.អ.ច.ក. នឹងត្រូវអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជានឹងរៀបចំយុទ្ធសាស្ត្រថ្មី សម្រាប់អនុម័តក្រោយការបោះឆ្នោតជាតិដែលនឹងរៀបចំនៅចុងខែកក្កដាឆ្នាំ២០១៨។ លើសពីនេះទៀត គ.អ.ច.ក. ដែលមានរយៈពេលសម្រាប់អនុវត្តរហូតដល់ឆ្នាំ២០៣០ ក៏ជាផ្នែកមួយសម្រាប់គាំទ្រចក្ខុវិស័យឆ្នាំ២០៥០របស់រាជរដ្ឋាភិបាលកម្ពុជា។

គ.អ.ច.ក. ក៏បានសង្កត់ធ្ងន់លើគោលការណ៍មិនបោះបង់នរណាម្នាក់ឲ្យនៅឯកោ មានន័យថាប្រជាជនកម្ពុជាទាំងអស់នឹងត្រូវទទួលបានផ្លែផ្កាពីការរីកចម្រើន និងការអភិវឌ្ឍប្រទេសនាពេលអនាគត។ ចំណុចនេះស្របគ្នាជាមួយការប្តេជ្ញាចិត្តសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ការអភិរក្សធនធានធម្មជាតិនិងការចូលរួមចំណែករបស់កម្ពុជា ក្នុងការបន្សាំនិងការកាត់បន្ថយផលប៉ះពាល់ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។

ក្របខ័ណ្ឌ គ.អ.ច.ក. បានកំណត់គោលបំណងចំនួន៤ ដើម្បីសម្រេចឱ្យបាននូវ គ.អ.ច.ក. គឺ៖

- បង្ហាញពីគោលដៅ ចំណុចដៅ និងសូចនាករ ដោយផ្អែកលើអាទិភាពរបស់ជាតិ។

- កំណត់ក្រសួង ស្ថាប័នទទួលខុសត្រូវសម្រាប់អនុវត្តសកម្មភាពនានា ដើម្បីសម្រេចបានចំណុចដៅ និងការងារតាមដានត្រួតពិនិត្យ។
- កំណត់ប្រភពទិន្នន័យសម្រាប់សូចនាករនីមួយៗនិងវដ្តទិន្នន័យ និងការរៀបចំនិយមន័យ ព្រមទាំងវិធីសាស្ត្រក្នុងការគណនាសូចនាករ។
- បង្ហាញពីនិន្នាការក្នុងការសម្រេចចំណុចដៅ ដោយយកទិន្នន័យឆ្នាំ២០១៥ ជាទិន្នន័យមូលដ្ឋានសម្រាប់សូចនាករទាំងអស់ និងកំណត់តម្លៃចំណុចដៅប្រចាំឆ្នាំ(ឬវដ្តនៃទិន្នន័យ) និងការអនុវត្តនៅថ្នាក់ក្រោមជាតិ។

ក្របខ័ណ្ឌ គ.អ.ច.ក.នេះមិនមែនជាផែនការសកម្មភាពសម្រាប់ការអនុវត្ត គ.អ.ច.ក. ទេ ប៉ុន្តែជាមូលដ្ឋានសម្រាប់ធ្វើសមាហរណកម្មទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(ផ.យ.អ.ជ.) និងការតាមដានត្រួតពិនិត្យនូវការសម្រេចបានរបស់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈកិច្ចខិតខំប្រឹងប្រែងនិងសកម្មភាពនានារបស់រាជរដ្ឋាភិបាល វិស័យឯកជន និងអ្នកមានចំណែកពាក់ព័ន្ធទាំងអស់។ ក្របខ័ណ្ឌ គ.អ.ច.ក. មាន៥ជំពូក ដូចខាងក្រោម៖

- **ជំពូកទី១** បង្ហាញពីក្របខ័ណ្ឌគោលនយោបាយនិងបរិការណ៍នៃការអភិវឌ្ឍ។
- **ជំពូកទី២** បង្ហាញពីការសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ដែលស្របតាមក្របខ័ណ្ឌសកលដែលបានបញ្ចប់ក្នុងឆ្នាំ២០១៥។
- **ជំពូកទី៣** បង្ហាញពីក្របខ័ណ្ឌ គ.អ.ច.ក. រួមទាំងចំណុចដៅនិងសូចនាករ ដែលផ្អែកលើអាទិភាពជាតិ និងប្រភពទិន្នន័យ។
- **ជំពូកទី៤** បង្ហាញពីបញ្ហាប្រឈមនានាដែលចាំបាច់ត្រូវដោះស្រាយដើម្បីធានាសម្រេចបានគោលដៅទាំងអស់។

**ជំពូកទី៥** ផ្តល់នូវសេចក្តីសន្និដ្ឋាននិងអនុសាសន៍។

# ជំពូកទី១ : ក្របខ័ណ្ឌគោលនយោបាយនិងបរិបទនៃការអភិវឌ្ឍ

ជំពូកនេះបង្ហាញពីការរៀបចំផែនការ ការកំណត់ក្រសួង ស្ថាប័នសម្រាប់អនុវត្ត គ.អ.ច.ក. ការពិនិត្យឡើងវិញនូវបរិបទនៃការអភិវឌ្ឍ និងការពន្យល់ពីការធ្វើសមាហរណកម្ម គ.អ.ច.ក. ទៅក្នុងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដើម្បីដោះស្រាយបញ្ហាប្រឈមក្នុងការអភិវឌ្ឍ។

## ១.១- ក្របខ័ណ្ឌរៀបចំផែនការ

### ១.១.១- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងបន្តរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) ដែលជាយុទ្ធសាស្ត្រស្នូលរបស់រាជរដ្ឋាភិបាល កំណត់បញ្ហាប្រឈមនានា ព្រមទាំងបានលើកឡើងនូវលក្ខខណ្ឌសម្រាប់ពង្រីកនិងពង្រឹងសេដ្ឋកិច្ចនិងការកែលម្អលក្ខខណ្ឌសេដ្ឋកិច្ច សង្គមកិច្ច ការវិភាជធនធាន និងការតាមដានត្រួតពិនិត្យ។

ផ.យ.អ.ជ. ត្រូវបានរៀបចំឡើងដោយមានការតម្រង់ទិសពីឯកសារគោលពីរសំខាន់ៗ៖ ទី១ កម្មវិធីនយោបាយនិងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល និងទី២ ចក្ខុវិស័យរយៈពេលវែង គឺចក្ខុវិស័យឆ្នាំ២០៣០ ដែលបង្ហាញពីការចាកចេញរបស់កម្ពុជាពីប្រទេសដែលមានចំណូលមធ្យមកម្រិតទាបទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ និងចក្ខុវិស័យឆ្នាំ២០៥០ ដែលកំណត់ថាកម្ពុជានឹងក្លាយជាប្រទេសដែលមានចំណូលខ្ពស់។

ផ.យ.អ.ជ. ២០១៩-២០២៣ នឹងផ្ដោតលើការយកចិត្តទុកដាក់លើការបង្កើនល្បឿនសមាហរណកម្មរបស់កម្ពុជាទៅក្នុងតំបន់និងសកល ការថមថយជំនួយអភិវឌ្ឍផ្លូវការ និងការបាត់បង់ការអនុគ្រោះពាណិជ្ជកម្ម។ ដោយសារឆ្នាំ២០១៥ ជាឆ្នាំចាប់ផ្ដើមសម្រាប់ គ.អ.ច.ក. ដូចនេះ ផ.យ.អ.ជ. នឹងកំណត់ពីសមត្ថភាពនិងវិធីសាស្ត្រថ្មីៗដើម្បីសម្រេចបាន គ.អ.ច.ក. និងដោះស្រាយការងារអាទិភាពនានា ជាពិសេស ការបញ្ចប់ការងារដែលនៅសេសសល់ពាក់ព័ន្ធនឹងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍។

លើសពីនេះទៅទៀត ផ.យ.អ.ជ. ២០១៩-២០២៣ នឹងត្រូវដាក់បញ្ចូលនូវការងារអាទិភាពទាំង៧ ដែលបានរកឃើញក្នុងរបាយការណ៍វាយតម្លៃពាក់កណ្ដាលអាណត្តិឆ្នាំ២០១៦នៃការអនុវត្ត ផ.យ.អ.ជ. ២០១៤-២០១៨ ក្នុងនោះរួមមាន ទី១ លើកកម្ពស់ការកាត់បន្ថយភាពក្រីក្រនិងកំណើនប្រកបដោយបរិយាបន្ន ទី២ លើកកម្ពស់វិស័យកសិកម្ម ទី៣ ធានាការប្រកួតប្រជែង ទី៤ គ្រប់គ្រងការធ្វើចំណាកស្រុកនិងនគរូបនីយកម្ម ទី៥ ប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុនិងការកាប់ព្រៃឈើ ទី៦ ពង្រឹងអភិបាលកិច្ចល្អ និងទី៧ ពង្រឹងធនធានមនុស្ស។

## ១.១.២- យុទ្ធសាស្ត្រចតុកោណ

កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី៦នៃរដ្ឋសភា ២០១៨-២០២៣ និង យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ នឹងរួមគ្នាបំពេញតួនាទីជាឯកសារក្របខណ្ឌគោលនយោបាយដែលគ្រប់ជ្រុងជ្រោយសម្រាប់រៀបចំ ផ.យ.អ.ជ ២០១៩-២០២៣ ដែលបានចែងក្នុងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលអាណត្តិថ្មី។ ដូចនេះ ផ.យ.អ.ជ. ជាឧបករណ៍គោលសម្រាប់អនុវត្តនិងធ្វើឲ្យសម្រេចបានអាទិភាពរបស់យុទ្ធសាស្ត្រចតុកោណ។ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ នឹងត្រូវបញ្ចប់បន្ទាប់ពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនៅខែកក្កដា ឆ្នាំ២០១៨។

**រូបភាព ១.១ : គំនូសបំព្រួញយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣**




*ប្រភព : យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣*

យុទ្ធសាស្ត្រចតុកោណផ្តល់ជាសំណុំគោលនយោបាយដែលមានលក្ខណៈជាប្រព័ន្ធ មានទំនាក់ទំនងគ្នា និងបំពេញឲ្យគ្នាទៅវិញទៅមក។ យុទ្ធសាស្ត្រចតុកោណផ្តោតលើលទ្ធផលចំនួនបួន គឺ កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព។ គោលការណ៍ដែលបានបង្កើតឡើងក្នុងយុទ្ធសាស្ត្រទាំង៤ រួមមាន ការលើកស្ទួយវិស័យកសិកម្ម ការបន្តស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការអភិវឌ្ឍផ្នែកឯកជននិងការងារ ការកសាងសមត្ថភាពនិងការអភិវឌ្ឍធនធានមនុស្ស ដែលមុំនីមួយៗមានសមាសភាគគោលនយោបាយចំនួន៤ និងមានអភិបាលកិច្ចល្អជាស្នូលរបស់ចតុកោណ។

ដំណាក់កាលនីមួយៗរបស់យុទ្ធសាស្ត្រចតុកោណ បានចែងពីទិសដៅគោលនយោបាយរបស់ខ្លួន សម្រាប់យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣គឺ៖

- ធានាឲ្យបាននូវកំណើនសេដ្ឋកិច្ចក្នុងអត្រាមធ្យមប្រចាំឆ្នាំប្រមាណ៧% ប្រកបដោយចីរភាព បរិយាបន្ន សមធម៌ និងភាពធន់នឹងវិបត្តិ តាមរយៈការធ្វើពិពិធកម្មនៃមូលដ្ឋានសេដ្ឋកិច្ចឲ្យបានទូលាយ និងមានសមត្ថភាពប្រកួតប្រជែងល្អប្រសើរជាងមុន ក្នុងបរិការណ៍អតិផរណាមានកម្រិតទាបដែលអាចគ្រប់គ្រងបាន អត្រាប្តូរប្រាក់មានស្ថិរភាព និងទុនបម្រុងមានកំណើនជាប្រចាំ។
- បង្កើតការងារឲ្យបានកាន់តែច្រើនឡើងជូនដល់ប្រជាជន ជាពិសេស សម្រាប់ស្រទាប់យុវជន តាមរយៈការបន្តខិតខំកែលម្អនិងបង្កើនភាពប្រកួតប្រជែងរបស់កម្ពុជាក្នុងការទាក់ទាញ និងការជំរុញលើកទឹកចិត្តដល់សកម្មភាពវិនិយោគ ទាំងវិនិយោគក្នុងប្រទេស ទាំងវិនិយោគក្រៅប្រទេស។
- សម្រេចឲ្យបាននូវគោលដៅនៃការកាត់បន្ថយភាពក្រីក្រក្នុងអត្រាជាង១% ក្នុងមួយឆ្នាំ ក៏ដូចជាគោលដៅផ្សេងៗទៀត ដែលត្រូវបានកំណត់ក្នុង គ.អ.ស.ក. ទន្ទឹមនឹងការផ្តោតអាទិភាពកាន់តែខ្លាំងឡើងលើការអភិវឌ្ឍធនធានមនុស្ស ការគ្រប់គ្រងបរិស្ថាន និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព។
- បន្តពង្រឹងសមត្ថភាពនិងអភិបាលកិច្ចនៃស្ថាប័នរដ្ឋ ទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិដើម្បីធានាឲ្យបាននូវប្រសិទ្ធភាពនិងសក្តិសិទ្ធភាពនៃសេវាសាធារណៈសំដៅបម្រើប្រជាជនឲ្យកាន់តែប្រសើរឡើង។

នៅពេលប្រកាសដាក់ឲ្យអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានគូសបញ្ជាក់ថា រាជរដ្ឋាភិបាលទទួលស្គាល់តម្រូវការក្នុងការធានាសង្គតិភាពទាក់ទងនឹងឋានានុក្រម តួនាទី ខ្លឹមសារ ទំនាក់ទំនង និងភាពស៊ីគ្នារវាងយុទ្ធសាស្ត្រចតុកោណ ផ.យ.អ.ជ. គោលនយោបាយអភិវឌ្ឍតាមវិស័យ និងគោលនយោបាយផ្សេងៗទៀត។ លើសពីនេះទៀត យុទ្ធសាស្ត្រចតុកោណនឹងត្រូវអនុវត្តតាមរយៈ ផ.យ.អ.ជ. ដើម្បីសម្រេចបាន គ.អ.ច.ក. កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល និងចក្ខុវិស័យរយៈពេលវែង។

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ នឹងត្រូវរៀបចំឡើងដើម្បីដោះស្រាយភាពប្រឈមថ្មីៗដែលកម្ពុជានឹងជួបប្រទះ និងជាពិសេស សំពាធដែលនឹងជួបប្រទះនៅពេលកម្ពុជាអភិវឌ្ឍបន្ត ហើយសេដ្ឋកិច្ចកម្ពុជានឹងក្លាយជាប្រទេសមានចំណូលមធ្យម។ ការបង្ហាញដំបូងស្នើឲ្យមានការតម្រឹមតម្រង់ឡើងវិញនិងទំនាក់ទំនងគ្នា ដោយផ្តោតលើផលិតភាពនិងភាពប្រកួតប្រជែង ជាពិសេ សកម្លាំងពលកម្ម។ សារៈសំខាន់នៃការអភិវឌ្ឍសង្គម ដូចជាទីផ្សារពលកម្មនិងការគាំពារសង្គម នឹងត្រូវយកចិត្តទុកដាក់ឲ្យបានច្រើន រួមជាមួយការប្តេជ្ញាចិត្តបន្ថែមទៀតចំពោះការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាព និងការអភិរក្សធនធានបរិស្ថានរបស់កម្ពុជា[1]។

### ១.១.៣- តួនាទីនៃគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា

ក្របខ័ណ្ឌ គ.អ.ច.ក. គឺជាលទ្ធផលនៃការធ្វើមូលដ្ឋាននីយកម្មគោលដៅអភិវឌ្ឍកបដោយចីរភាពសកល(គ.អ.ច.) មកក្នុងបរិបទកម្ពុជា ក្រោយអង្គការសហប្រជាជាតិអនុម័តកាលពីខែកញ្ញា ឆ្នាំ ២០១៥។

ខ្លឹមសារថ្មីៗរបស់ ផ.យ.អ.ជ. និងយុទ្ធសាស្ត្រចតុកោណខាងលើនេះ ត្រូវស្របគ្នាជាមួយនឹងគោលការណ៍និងទម្រង់របស់ គ.អ.ច.ក.។ គោលដៅទាំងអស់របស់គ.អ.ច.ក. ផ្តល់ជាការណែនាំផ្នែកគោលនយោបាយនិងមធ្យោបាយសម្រាប់តាមដានត្រួតពិនិត្យការអនុវត្ត ដោយលើកកម្ពស់សកម្មភាពនិងការធ្វើការសម្រេចចិត្តរួមគ្នា ជំរុញការសម្រេចបានទិសដៅអភិវឌ្ឍ។ ក្របខ័ណ្ឌសកលដែលបានដាក់បញ្ចូលក្នុង គ.អ.ច.ក. មានលក្ខណៈគ្រប់ជ្រុងជ្រោយជាងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍។ ការរៀបចំ គ.អ.ច. ត្រូវបានដឹកនាំដោយប្រទេសដែលមានចំណូលមធ្យម ហើយក្របខ័ណ្ឌនេះមានអត្ថប្រយោជន៍ចំពោះការរៀបចំផែនការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចក្នុងប្រទេសនានា ដែលមានស្ថានភាពប្រហាក់ប្រហែលប្រទេសកម្ពុជា។ ក្របខ័ណ្ឌនេះក៏បានបញ្ជាក់យ៉ាងច្បាស់អំពីភាពប្រឈមក្នុងការអនុវត្ត ដូចជាតម្រូវការធនធាននិងហិរញ្ញប្បទានក្នុងស្រុកត្រូវដើរតួនាទីក្នុងការសម្រេចបានសមិទ្ធផល ហើយការសម្រេចបានគោលដៅនានាគឺជាភារកិច្ចរបស់អ្នកមានចំណែកពាក់ព័ន្ធទាំងអស់ រួមទាំងវិស័យឯកជន និងប្រជាជន។

គ.អ.ច.ក. ជំរុញឲ្យមានការផ្សារភ្ជាប់ទំនាក់ទំនងគ្រប់វិស័យនិងអ្នករៀបចំគោលនយោបាយ ដូចជាក្រសួង ស្ថាប័ន និង រវាង ផ.យ.អ.ជ. និងចក្ខុវិស័យរយៈពេលវែង និងថវិកាប្រចាំឆ្នាំដែលបានកំណត់នៅក្នុងក្របខ័ណ្ឌកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ទាំងនេះនឹងជួយកំណត់ទិសដៅ និងជម្រើសគោលនយោបាយសម្រាប់សម្រេចបានទិសដៅអភិវឌ្ឍ និងជំរុញទំនាក់ទំនងដែលត្រូវធ្វើឡើងទាក់ទងនឹងហិរញ្ញប្បទាន។ ដូចមានចែងក្នុងជំពូកទី៣ រាជរដ្ឋាភិបាលបានដាក់ចេញនូវក្របខ័ណ្ឌគោលនយោបាយស្របទៅនឹងបរិបទកម្ពុជា ដើម្បីឆ្លើយតបនឹងតម្រូវការដោះស្រាយ

---

[1] ការផ្តួចផ្តើមដោយសង្ខេបការវិភាគពី SWOT ពីឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បញ្ហាប្រឈមនានា និងការប្តេជ្ញាចិត្ត ដោយប្រើប្រាស់ជាធាតុចូលសម្រាប់ ផ.យ.អ.ជ. និងសម្រួចក្របខ័ណ្ឌតាមដានត្រួតពិនិត្យ។ គ.អ.ច.ក. មានលទ្ធភាពបំបែកទិន្នន័យ តាមវិស័យ តាមតំបន់ និងរហូតដល់កម្រិតខេត្ត។ ទាំងនេះនឹងជំរុញកិច្ចខិតខំប្រឹងប្រែងការរៀបចំ ផ.យ.អ.ជ. ឲ្យមានទំនាក់ទំនងគ្នារវាងគោលនយោបាយនិងវិស័យនានា។ គ.អ.ច.ក. នឹងផ្តល់ជាការតម្រង់ទិសសម្រាប់ការវិនិយោគរបស់វិស័យឯកជន និងកែលម្អតវិយាបទរបស់អ្នកប្រើប្រាស់និងអ្នកផលិត។

## ១.២- បរិការណ៍គោលនយោបាយសេដ្ឋកិច្ច

ផ្នែកនេះ បង្ហាញពីខ្លឹមសារសង្ខេបស្តីពីស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ដែលជាមូលដ្ឋានសម្រាប់រៀបចំ គ.អ.ច.ក. ដោយចាប់ផ្តើមការពិនិត្យមើលធាតុចេញនិងសូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ និងការពិភាក្សាអំពីសេដ្ឋកិច្ចជាក់ស្តែង។ គ.អ.ច.ក. គ្របដណ្តប់ទាំងកម្រិតនិងគុណភាពនៃការអភិវឌ្ឍសេដ្ឋកិច្ច ព្រមទាំងបង្ហាញអំពីបរិយាបន្ននិងចីរភាព ដោយផ្តោតលើទំនាក់ទំនងរវាងការផ្លាស់ប្តូរសេដ្ឋកិច្ច បរិស្ថាន និងសង្គម និងកត្តាជំរុញផ្នែករចនាសម្ព័ន្ធផ្សេងទៀត។

ជាទូទៅ សេដ្ឋកិច្ចកម្ពុជាកំពុងដំណើរការយ៉ាងល្អប្រសើរ ហើយរាជរដ្ឋាភិបាលកម្ពុជាបានបន្តផ្តល់នូវបរិស្ថានអភិវឌ្ឍដែលមានស្ថិរភាព តាមរយៈការដោះស្រាយបញ្ហាប្រឈមនិងទប់ស្កាត់ហានិភ័យផ្នែកម៉ាក្រូសេដ្ឋកិច្ចដែលបណ្តាលមកពីកត្តាខាងក្នុងនិងខាងក្រៅ។ និន្នាការដែលពិភាក្សាខាងក្រោមដើម្បីរក្សា ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចបន្តទៀត មានភាពបត់បែនគ្រប់គ្រាន់ទាន់ពេលវេលាក្នុងការដោះស្រាយហានិភ័យនានាដែលកើតឡើងដោយចៃដន្យ។ ប៉ុន្តែ ទិន្នន័យសេដ្ឋកិច្ចជាក់ស្តែង ទាមទារឲ្យមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីកែលម្អផលិតភាពនិងភាពប្រកួតប្រជែង និងដើម្បីជំរុញការផ្លាស់ប្តូររចនាសម្ព័ន្ធ។

សេដ្ឋកិច្ចកម្ពុជាសម្រេចបានកំណើនរឹងមាំក្នុងរយៈពេល២ទសវត្សរ៍កន្លងមកនេះ ក្នុងអត្រាជាមធ្យមប្រចាំឆ្នាំក្នុងចន្លោះពី៧ ទៅ៨% ដែលជាប់ចំណាត់ថ្នាក់ក្នុងចំណោមសេដ្ឋកិច្ចកំពូលទាំង១០ក្នុងសកលលោក។ នៅប៉ុន្មានឆ្នាំចុងក្រោយនេះ កម្ពុជារក្សាបានកំណើនជាមធ្យមប្រចាំឆ្នាំក្នុងរង្វង់៧% ហើយការព្យាករបង្ហាញថាកំណើននេះនឹងនៅតែបន្តក្នុងរយៈពេលមធ្យមខាងមុខនេះ។ និន្នាការកំណើននេះបានបន្តលើកកម្ពស់ជីវភាពនិងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា។ ជាក់ស្តែង ផលិតផលក្នុងស្រុកសរុប(ផ.ស.ស.) សម្រាប់មនុស្សម្នាក់ៗមានការកើនឡើងជាបន្តបន្ទាប់ដោយកើនឡើងដល់១ ៣០៨ដុល្លារអាមេរិក ក្នុងឆ្នាំ២០១៦ ជាមួយកំណើនប្រជាជនជាមធ្យមប្រចាំឆ្នាំមានប្រមាណ១,៦%។ កម្ពុជាត្រូវបានចាត់ចូលជាប្រទេសមានចំណូលមធ្យមកម្រិតទាបនិងបន្តសម្រេចឲ្យបានជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។

កត្តាសំខាន់មួយជំរុញភាពជោគជ័យរបស់កម្ពុជាគឺ ការរក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងអតិផរណាដែលអាចគ្រប់គ្រងបាន ដែលគាំទ្រដោយការគ្រប់គ្រងស្ថានភាពហិរញ្ញវត្ថុប្រកបដោយ

ប្រសិទ្ធភាព។ លក្ខណៈនៃសេដ្ឋកិច្ចកម្ពុជាគឺការប្រើប្រាស់ប្រាក់ដុល្លារក្នុងកម្រិតខ្ពស់(លើស៨៥% នៃប្រតិបត្តិការសាច់ប្រាក់) និងការគ្រប់គ្រងដោយជោគជ័យលើរូបិយបណ្ណក្នុងស្រុក។ ប្រការនេះបានជួយពង្រឹងទំនុកចិត្តរបស់អ្នកវិនិយោគនិងសាធារណជនលើរូបិយបណ្ណក្នុងស្រុក និងបានជំរុញស្ថិរភាពប្រព័ន្ធធនាគារ។ ការរក្សាគោលការណ៍នេះក្នុងរយៈពេលមធ្យមនឹងជំរុញកម្ពុជាឲ្យធានាបាននូវស្ថិរភាពបន្តទៀត ហើយរក្សាបានអតិផរណាកម្រិតទាបក្នុងឆ្នាំខាងមុខ។ លើសពីនេះទៅទៀត តុល្យភាពជញ្ជីងទូទាត់មានភាពប្រសើរឡើងក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ។ ការនាំចេញ(ការនាំចេញបានកើនឡើងពី៤៩%ក្នុងឆ្នាំ២០០៩ ទៅ៦១%ក្នុងឆ្នាំ២០១៦)ដែលបានរក្សាល្បឿននៃការនាំចូលដែលបានកំណត់ឱនភាពពាណិជ្ជកម្មឲ្យនៅកម្រិតក្រោម៥% នៃ ផ.ស.ស.។

**រូបភាព ១.២ : កំណើនផ.ស.ស.**




*ប្រភព : ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងក្រសួងផែនការ*

ស្ថានភាពហិរញ្ញវត្ថុសាធារណៈ មានវឌ្ឍនភាពល្អប្រសើរឡើងគួរឲ្យកត់សម្គាល់ ដោយចំណូលបានកើនឡើងដល់ប្រមាណ១៨%នៃផ.ស.ស. នៅក្នុងឆ្នាំ២០១៥/២០១៦ (រូបភាព ១.២)[2]។ រាជរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងជាខ្លាំង ដើម្បីរក្សាឲ្យបាននិរន្តរភាពថវិកាតាមរយៈការជំរុញការប្រមូលចំណូលនិងការគ្រប់គ្រងចំណាយ។ សេវាសាធារណៈចាំបាច់ត្រូវពង្រឹង ដើម្បីសម្រេចបានចំណុចដៅរបស់ គ.អ.ច.ក.។ កិច្ចប្រឹងប្រែងទាំងនេះរួមមាន ការរៀបចំយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម រួមទាំងការបន្តអនុវត្តរបៀបវារៈកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ការប្រមូលចំណូលបច្ចុប្បន្នបានកើនឡើងក្នុងរង្វង់០,៥% នៃ ផ.ស.ស. ប្រចាំឆ្នាំចាប់តាំងពីឆ្នាំ២០១១មក (រូបភាព ១.៣)។ លើសពីនេះទៀត យុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជាមិនជាប់ពាក់ព័ន្ធជាមួយការបង្កើនពន្ធឬការបង្កើតពន្ធថ្មីៗ (លើកលែងតែសកម្មភាពនានាដែលប៉ះពាល់ដល់បរិស្ថានឬសុខភាពសាធារណៈ) ប៉ុន្តែបានពង្រឹងរដ្ឋបាលពន្ធនិងមិនមែនពន្ធ ច្បាប់ និងលិខិតបទដ្ឋានស្តីពីពន្ធ ពន្ធគយនិងអាករ និងចំណូលនានា។

[2] ការធ្វើចំណោលរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**រូបភាព ១.៣ : ការកៀរគរចំណូល (% នៃ ផ.ស.ស.)**




ការគ្រប់គ្រងថវិកាវិស័យសាធារណៈត្រូវបានពង្រឹង ដោយធានាថាការចំណាយត្រូវបានប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព និងកំណត់គោលដៅលើសេវាសាធារណៈនិងហេដ្ឋារចនាសម្ព័ន្ធ (ឧទាហរណ៍ ការវិភាជថវិកាសម្រាប់វិស័យអប់រំកើនឡើងពី១,៧%នៃ ផ.ស.ស.ក្នុងឆ្នាំ២០១៣ ដល់២,៦% នៃផ.ស.ស.ក្នុងឆ្នាំ២០១៦។ ការវិនិយោគក្នុងវិស័យអាទិភាពទាំងនេះនឹងជំរុញកម្ពុជាឲ្យសម្រេចបានការអភិវឌ្ឍប្រកបដោយបរិយាបន្ននិងចីរភាព និងសម្រេចបានរបៀបវារៈ គ.អ.ច.ក.។ ថវិកាកម្មវិធីនៅក្នុងដំណាក់ទី៣នៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈការអនុម័តផែនការយុទ្ធសាស្ត្រថវិកា ត្រូវបានពង្រីកជាបន្តបន្ទាប់ ហើយនឹងគ្របដណ្តប់គ្រប់ក្រសួងទាំងអស់ពីឆ្នាំ២០១៨ តទៅ។ ផែនការយុទ្ធសាស្ត្រថវិកា ពាក់ព័ន្ធនឹងផែនការថវិកា៣ឆ្នាំរំកិលដែលផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ដើម្បីសម្រេចបានប្រសិទ្ធភាពកាន់តែប្រសើរ(ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ២០១៧)។ ផែនការនេះផ្តល់ជាយន្តការសម្រាប់ផ្សារភ្ជាប់ គ.អ.ច.ក. ទៅនឹងការរៀបចំនិងអនុវត្តថវិកានិងការប្រតិបត្តិ។

តាមរយៈយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ រាជរដ្ឋាភិបាលបានធានាថាបំណុលសាធារណៈស្ថិតក្នុងការគ្រប់គ្រងបាន និងអនុញ្ញាតឲ្យខ្ចីបំណុលបន្ថែមបានសម្រាប់តែគាំទ្រដល់ការវិនិយោគសាធារណៈដែលចាំបាច់ប៉ុណ្ណោះ។ កម្រិតបំណុលនិងសេវាបំណុលមានកម្រិតថេរ។ យុទ្ធសាស្ត្រនេះមានគោលដៅរក្សាឱនភាពថវិកាក្នុងរង្វង់៣%នៃ ផ.ស.ស. នៅត្រឹមឆ្នាំ២០១៨។

នៅក្នុងសេដ្ឋកិច្ចពិត មានការប្តូររចនាសម្ព័ន្ធជាបន្តបន្ទាប់ (រូបភាព ១.៤) ហើយបានចូលរួមចំណែកដល់កំណើនវិស័យឧស្សាហកម្មប្រមាណ១០%។ និន្នាការនិងចំណែកតម្លៃបន្ថែមតាមវិស័យមានការប្រែប្រួលគួរឲ្យកត់សម្គាល់ ដោយវិស័យកសិកម្មបានធ្លាក់ចុះពី៣៧% ក្នុងឆ្នាំ២០១១ មកត្រឹម

២៧% ក្នុងឆ្នាំ២០១៦ ឧស្សាហកម្មបានកើនឡើងពី២៤% ដល់៣២% និងសេវាកម្មបានកើនពី៣៩% ដល់៤២% ក្នុងរយៈពេលដូចគ្នា។

**រូបភាព ១.៤ : ចំណែកតម្លៃបន្ថែមតាមវិស័យ**




*ប្រភព : ការគណនាផ្អែកតាមទិន្នន័យរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឆ្នាំ២០១៦*

ការគាំទ្រដល់ការផ្លាស់ប្តូរទាំងនេះ គឺជាការធ្វើឲ្យប្រសើរឡើងនូវផលិតភាពនិងការបង្កើនប្រាក់ចំណូលក្នុងវិស័យមិនមែនកសិកម្ម។ ក្រៅពីភាពជោគជ័យជាបន្តបន្ទាប់នៅក្នុងផលិតកម្មស្រូវអង្ករ វិស័យកសិកម្មនៅតែបន្តគ្របដណ្តប់ដោយសកម្មភាពកសិកម្មខ្នាតតូច និងមានលក្ខណៈសម្រាប់ចិញ្ចឹមជីវិតតែប៉ុណ្ណោះ។ រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ពីតម្រូវការក្នុងការបង្កើនផលិតភាពកសិកម្ម ទាំងការគាំទ្រដល់ការផ្លាស់ប្តូររចនាសម្ព័ន្ធនិងកម្រិតការងារក្នុងវិស័យកសិកម្ម ដើម្បីលើកកម្ពស់ជីវភាពនិងកាត់បន្ថយភាពក្រីក្រ។

វិស័យកម្មន្តសាលដែលនាំមុខរបស់កម្ពុជា រួមមាន សម្លៀកបំពាក់ និងស្បែកជើង បន្តគាំទ្រដល់ការផ្លាស់ប្តូររចនាសម្ព័ន្ធនិងកំណើនទៅលើតម្លៃបន្ថែម។ ពិពិធកម្មមូលដ្ឋានឧស្សាហកម្ម ដូចជាគ្រឿងបង្គុំយានយន្តនិងគ្រឿងអេឡិចត្រូនិច កំពុងលេចរូបរាងជាបណ្តើរៗ ប៉ុន្តែមូលដ្ឋាននេះនៅមានកម្រិតចង្អៀតនៅឡើយ។ សមិទ្ធផលទាំងនេះរងនូវបញ្ហាប្រឈមមួយចំនួន ដូចជាកំណើនប្រាក់ខែគោលនិងភាពប្រសើរឡើងយឺតនៃផលិតភាពពលកម្ម និងការប្រើប្រាស់ប្រាក់ដុល្លារអាមេរិក។ លើសពីនេះទៀត ចំណាយផលិតកម្មក្នុងស្រុកសម្រាប់អគ្គិសនីនិងការដឹកជញ្ជូននៅខ្ពស់នៅឡើយធៀបនឹងប្រទេសជិតខាង។ វិស័យសេវាកម្មបានកើនឡើងយ៉ាងខ្លាំង ដោយមានកំណើនជាមធ្យមប្រមាណ៨% ក្នុងមួយឆ្នាំ តែវិស័យនេះបានជួបប្រទះនឹងបញ្ហាប្រឈមមួយចំនួន រួមមាន កំណើនយឺតយ៉ាវក្នុងវិស័យទេសចរណ៍និងវិស័យអចលនទ្រព្យ ប៉ុន្តែទទួលបានលទ្ធផលល្អប្រសើរនៅក្នុងវិស័យពាណិជ្ជកម្មក្នុងប្រទេសនិងការដឹកជញ្ជូន។ ខណៈវិស័យទេសចរណ៍និងអចលនទ្រព្យដែលជាអ្នកចូលរួមចំណែក

ដ៏ខ្លាំងក្លាទៅដល់ផ្នែកសេវាកម្មក្នុងរយៈពេលមធ្យម និងជាវិស័យដ៏សំខាន់ក្នុងការបង្កើតការងារ ប៉ុន្តែអត្រាកំណើននៃទិន្នផលហាក់ដូចជាថមថយនាប៉ុន្មានឆ្នាំចុងក្រោយនេះ។

បញ្ហាអន្តរវិស័យគឺតម្រូវការក្នុងការកែលម្អពលកម្មនិងផលិតភាព និងរក្សាភាពប្រកួតប្រជែងជាតិក្នុងទីផ្សារនាំចេញ ដែលតម្រូវឲ្យមានជាតុចូលរបស់សេដ្ឋកិច្ចទាំងមូល ដូចជាការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ប្រភពថាមពលធានានិរន្តរភាពនិងប្រសិទ្ធភាពចំណាយ ការបណ្តុះបណ្តាល ការអប់រំមូលដ្ឋាន និងការផ្លាស់ប្តូរតាមវិស័យ ដូចជា វិស័យកសិកម្ម រួមមានការប្រើប្រាស់ពូជដំណាំដែលមានតម្លៃខ្ពស់និងធន់នឹងអាកាសធាតុ បច្ចេកទេសនិងការអនុវត្តការដាំដុះប្រសើរ វិស័យឧស្សាហកម្មមានការផ្លាស់ប្តូរបច្ចេកវិទ្យា ដោយមានគោលការណ៍ជាប្រព័ន្ធសម្រាប់ការទទួលស្គាល់គុណភាពនៃការបណ្តុះបណ្តាល។ ដោយឡែកវិស័យសេវាកម្ម មានការយកចិត្តទុកដាក់លើវិស័យទេសចរណ៍ដោយពង្រីកទិសដៅទេសចរណ៍ និងគុណភាព។ គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម គឺជាស្នូលនៃកិច្ចខិតខំប្រឹងប្រែងក្នុងការផ្លាស់ប្តូរសេដ្ឋកិច្ចនិងជំរុញតម្លៃបន្ថែម។

## ១.៣- បរិការណ៍សេដ្ឋកិច្ច សង្គមកិច្ច

កំណើនសេដ្ឋកិច្ច បានកើតឡើងដោយសារការរីកវិវឌ្ឍរីជ្ជមាននៃសេដ្ឋកិច្ចសង្គម។ អ្វីដែលគួរឱ្យកត់សម្គាល់បំផុតនោះគឺ ការកាត់បន្ថយភាពក្រីក្រយ៉ាងឆាប់រហ័សជាមួយនឹងអត្រាសមាមាត្រដែលផ្អែកលើខ្សែបន្ទាត់ភាពក្រីក្រដែលធ្លាក់ចុះពី៤៧,៨%នៅឆ្នាំ២០០៧ ដល់១៣,៥%នៅក្នុងឆ្នាំ២០១៤ (រូបភាព ១.៥)។ ការធ្លាក់ចុះមេគុណជីនី(វិសមភាព) ពី០,៣៤នៅឆ្នាំ២០០៩ មក០,២៨នៅឆ្នាំ២០១៦ ពិតជាបានបង្ហាញថា កម្ពុជាមានកម្រិតវិសមភាពទាបនៅក្នុងតំបន់អាស៊ីអាគ្នេយ៍(រូបភាព ១.៦)។

**រូបភាពទី១.៥ : អត្រាភាពក្រីក្រ ២០០៤-២០១៤**



## រូបភាព ១.៦ : មេគុណជីនី ២០០៩-២០១៦




*ប្រភព : ក្រសួងផែនការ*

ទីផ្សារការងាររបស់ប្រទេសកម្ពុជាដែលមានភាពបត់បែន និងផលិតកម្មការងារដែលពឹងផ្អែកខ្លាំងលើកម្លាំងពលកម្មនោះគឺជាកត្តាគន្លឹះមួយនៃនិន្នាការវិវត្តជាវិជ្ជមាន។ អត្រានៃការចូលរួមការងារដែលជំនួសពីការធ្វើកសិកម្មនៅមានកម្រិតខ្ពស់(សរុប៨៨,៥% ស្ត្រី៧៧,២% ក្នុងឆ្នាំ២០១៦) និងអត្រាអ្នកគ្មានការងារធ្វើនៅកម្រិតមួយទាប។ ការងារដែលផ្លាស់មកពីវិស័យកសិកម្ម(ជាលទ្ធផលនៃការផ្លាស់ប្តូររចនាសម្ព័ន្ធ) ត្រូវបានស្រូបយកដោយឧស្សាហកម្មថ្មីៗ ជាពិសេស វិស័យកាត់ដេរនិងសំណង់ និងការធ្វើចំណាកស្រុកទៅក្រៅប្រទេស(ប្រទេសថៃ) បានស្រូបយកកម្លាំងលើសតម្រូវការបន្ថែមទៀត។ ទោះជាយ៉ាងណាក៏ដោយក៏កម្លាំងពលកម្មភាគច្រើននៅតែគ្មានជំនាញ និងការងារមិនទៀង។ ទីផ្សារការងារសម្រាប់យុវជននៅតែជាបញ្ហាប្រឈមនៅឡើយ។

កត្តាសំខាន់ផ្សេងទៀត គឺការកើតមានឡើងនៃភាពងាយរងគ្រោះមានទំហំធំដែលជាហានិភ័យមួយដែលងាយធ្លាក់ចូលទៅក្នុងភាពក្រីក្រវិញ។ ខណៈដែលចំនួនដ៏ច្រើនបានចាកចេញពីភាពក្រីក្រ សមាមាត្រនៃប្រជាជនដែលរស់នៅពីលើក្បែរៗខ្សែបន្ទាត់ភាពក្រីក្រ (ដែលគេហៅថាអ្នកនៅក្បែរភាពក្រីក្រ) បានកើនឡើងគួរឲ្យកត់សម្គាល់។ តាមលទ្ធផលនៃការសិក្សាស្រាវជ្រាវរបស់ធនាគារពិភពលោកក្នុងឆ្នាំ២០១៣ បានបង្ហាញពីផលប៉ះពាល់នៃប្រាក់ចំណូល អាចមានទំហំធំ ដែលបានប៉ាន់ប្រមាណថាការកាត់បន្ថយត្រឹមតែ ០,៧ដុល្លារអាមេរិក ក្នុងប្រាក់ចំណូលជាមធ្យមប្រចាំថ្ងៃនឹងអាចបង្កើនអត្រាភាពក្រីក្រឲ្យលើសពី៤០%។ តាមការកត់សម្គាល់ ជាទូទៅក្រុមអ្នកមានចំណូលមធ្យមមិនបានទទួលប្រាក់កម្រៃគ្រប់គ្រាន់សម្រាប់ចិញ្ចឹមខ្លួននិងគ្រួសាររបស់ពួកគេទេ ហើយពួកគេក៏នៅក្រៅគោលដៅនៃកម្មវិធីជំនួយទៀតផង។ ការឆ្លើយតបទៅនឹងតម្រូវការរបស់ក្រុមចម្រុះនេះ គឺជាបញ្ហាប្រឈមសំខាន់សម្រាប់ប្រទេសដែលមានចំណូលមធ្យមដូចជាប្រទេសកម្ពុជា។ រាជរដ្ឋាភិបាលបានទទួលស្គាល់បញ្ហានេះនៅក្នុងក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ ដោយមានសំណើដើម្បីបង្កើនជំនួយសង្គមនិងការធានារ៉ាប់រងសង្គម ដែលនឹងត្រូវបានអនុវត្តក្នុងអាណត្តិ ផ.យ.អ.ជ. ថ្មី។

វិធានការនៃសុខុមាលភាព បានបង្ហាញពីភាពកាន់តែទូលំទូលាយជាងមុន។ សន្ទស្សន៍នៃការអភិវឌ្ឍមនុស្សរបស់កម្មវិធីអភិវឌ្ឍសហប្រជាជាតិ ដែលមានសមាសធាតុ សន្ទស្សន៍សុខភាព ការអប់រំ និងស្ថានភាពជីវភាពរស់នៅសមរម្យ មានភាពប្រសើរឡើងចាប់តាំងពីពាក់កណ្ដាលទសវត្សរ៍ឆ្នាំ១៩៩០។ សមិទ្ធផលកាន់តែមានភាពប្រសើរឡើងខ្លាំងរវាងឆ្នាំ២០០០និងឆ្នាំ២០១០ នៅពេលដែលប្រទេស កម្ពុជាមានសន្ទស្សន៍នៃការអភិវឌ្ឍមនុស្ស រីកលូតលាស់យ៉ាងឆាប់រហ័សនៅក្នុងតំបន់ និងបានស្ថិតនៅក្នុងលំដាប់កំពូលក្នុងចំណោមប្រទេស៥ នៅទូទាំងពិភពលោក (រូបភាព ១.៧)។

**រូបភាព ១.៧ : សន្ទស្សន៍នៃការអភិវឌ្ឍមនុស្ស**




***ប្រភព :** កម្មវិធីអភិវឌ្ឍសហប្រជាជាតិ ២០១៦*

# ជំពូកទី២ : លទ្ធផលនិងបទពិសោធពីការសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា( គ.អ.ស.ក. )

## ២.១- សេចក្តីផ្តើម

គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍( គ.អ.ស ) ត្រូវបានប្រកាសផ្សព្វផ្សាយដោយអង្គការសហប្រជាជាតិនៅឆ្នាំ២០០២និង បានដំណើរការអនុវត្តរហូតដល់ដំណាច់ឆ្នាំ២០១៥ ដែលជាការផ្តួចផ្តើមឲ្យមានទំនាក់ទំនងរវាងគោលនយោបាយរួម ផ្សារភ្ជាប់ទៅនឹងការបង្កើនជំនួយអភិវឌ្ឍផ្លូវការ[3]។ បណ្តាប្រទេសដែលមានចំណូលទាបនិងមធ្យមសម្រេចបានគោលដៅរបស់ គ.អ.ស. ជាច្រើនយ៉ាងឆាប់រហ័ស តាមរយៈការតស៊ូមតិនិងមធ្យោបាយសម្រាប់តាមដានត្រួតពិនិត្យពីលទ្ធផលនៃការអនុវត្ត។ តាមរយៈដំណើរការនៃការធ្វើមូលដ្ឋាននីយកម្មទៅក្នុងបរិការណ៍ជាតិ និងសមាហរណកម្មទៅក្នុងក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលដៅនៃ គ.អ.ស. បានក្លាយជាគោលនយោបាយនិងការតាមដានត្រួតពិនិត្យរបស់បណ្តាប្រទេសកំពុងអភិវឌ្ឍភាគច្រើន។ សារៈសំខាន់នៃ គ.អ.ស. ត្រូវបានលើកកម្ពស់បន្ថែមទៀត តាមរយៈការរៀបចំរបាយការណ៍វាយតម្លៃពីការសម្រេចបានទាំងនៅថ្នាក់ជាតិនិងសកល និងការដាក់បញ្ចូលចំណុចដៅ គ.អ.ស. ក្នុងក្របខ័ណ្ឌរបស់អង្គការសហប្រជាជាតិនិងវិទ្យាស្ថានហិរញ្ញវត្ថុអន្តរជាតិ។ ចំពោះគោលដៅអភិវឌ្ឍប្រកបដោយចីរភាព( គ.អ.ច. ) គឺមានភាពខុសគ្នាដាច់ស្រឡះពី គ.អ.ស. ទាំងវិសាលភាព មហិច្ឆតា ការគិតគូរបន្ថែមលើ គ.អ.ស. និងរួមទាំងបទពិសោធនានាដែលទទួលបានពីកម្រិតជាតិនិងសកល។ លើសពីនេះ បណ្តាគោលដៅនានារបស់ គ.អ.ស. ដែលមិនទាន់សម្រេចបាននៅត្រឹមឆ្នាំ២០១៥ ត្រូវបានចាត់ទុកជាអាទិភាពដំបូងនៅក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីសម្រេចបាន គ.អ.ច.។

កម្ពុជាគឺជាប្រទេសមួយ ក្នុងចំណោមប្រទេសជាសមាជិកនៃអង្គការសហប្រជាជាតិចំនួន ១៨៩ ដែលគាំទ្រដល់ គ.អ.ស. និងបានធ្វើមូលដ្ឋាននីយកម្មទៅក្នុងបរិការណ៍ជាតិ គឺគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា( គ.អ.ស.ក. ) នៅក្នុងកំលុងឆ្នាំ២០០៣។ គ.អ.ស.ក. ត្រូវបានរៀបចំច្បាស់លាស់និងត្រូវបានបន្ថែមគោលដៅទី៩មួយទៀត ស្តីពីការលុបបំបាត់មីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម និងបានកំណត់ចំណុចដៅយ៉ាងច្រើនក្នុងគោលដៅមួយចំនួនដើម្បីផ្តល់នូវជាតុផ្សំនិងឆ្លុះបញ្ចាំងពីអាទិភាពជាតិដាច់ដោយឡែក។ បន្ថែមពីលើនេះ គ.អ.ស.ក. ត្រូវបានតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលនៃការសម្រេចបាន ប៉ុន្តែ មិនបានរាយការណ៍ពីការអនុវត្តគោលដៅទី៨ ដែលជាគោលដៅស្តីពីកិច្ចសហប្រតិបត្តិការសកល។ គ.អ.ស.ក. ត្រូវបានពិនិត្យនិងកែសម្រួលជាច្រើនដង សរុបមានចំណុចដៅចំនួន២៨និងសូចនាករចំនួន៦៥។ ជាទូទៅ ចំណុចដៅត្រូវបានកំណត់តម្លៃដើមគ្រានៅឆ្នាំ២០០០ និងគោលដៅចុងក្រោយក្នុងឆ្នាំ២០១៥។ រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងផែនការ

3 *បានឯកភាពនៅក្នុងផ្នែកនៃកិច្ចព្រមព្រាង ម៉ុងតេរី ឆ្នាំ២០០២*

ជាសេនាធិការ បានដឹកនាំការសម្របសម្រួល រៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំនៃការសម្រេចបាន គ.អ.ស.ក. ចាប់ពីឆ្នាំ២០០៨។ គ.អ.ស.ក. ត្រូវបានធ្វើសមាហរណកម្មទៅក្នុង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ និង ផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិ រួមជាមួយតារាងផ្ដល់ពិន្ទុពីលទ្ធផលនៃការសម្រេចបាន គ.អ.ស.ក.។

ជំពូកនេះ នឹងពិនិត្យមើលពីលទ្ធផលចុងក្រោយនៃការសម្រេចបាននិងបទពិសោធនៃការអនុវត្ត គ.អ.ស.ក. ដើម្បីគាំទ្រនិងរៀបចំក្របខ័ណ្ឌ គ.អ.ច.ក.។ ផ្នែកដំបូងនឹងចាប់ផ្ដើមពីសេចក្ដីសង្ខេបនៃលទ្ធផល រួមជាមួយការវិភាគតាមគោលដៅនីមួយៗ និងផ្នែកចុងក្រោយពិភាក្សាលើចំណុចសំខាន់ៗមួយចំនួនដែលមិនទាន់សម្រេចបាននិងបញ្ហាប្រឈមនានា ដែលមានការពាក់ព័ន្ធជាមួយ គ.អ.ច.ក.។

## ២.២- សេចក្ដីសង្ខេបនៃការពិនិត្យមើលឡើងវិញ លទ្ធផលនៃការសម្រេចបាន គ.អ.ស.ក.

ផ្នែកនេះ នឹងបង្ហាញពីរបាយការណ៍ប្រចាំឆ្នាំនិងរបាយការណ៍ចុងក្រោយនៃការសម្រេចបាន គ.អ.ស.ក.។ ជាលទ្ធផល កម្ពុជាទទួលជោគជ័យយ៉ាងត្រចះត្រចង់ក្នុងការសម្រេចបាន គ.អ.ស.ក. ដែលប្រមាណ៦៤%នៃចំណុចដៅទាំង២៨ ត្រូវបានសម្រេចឬហៀបនឹងសម្រេចបាន។ គួរកត់សម្គាល់ផងដែរថា វឌ្ឍនភាពបន្ថែមទៀតឆ្ពោះទៅសម្រេចបាន គ.អ.ស.ក. ត្រូវបានបង្ហាញច្បាស់ចាប់ពីឆ្នាំ២០១៥។

### រូបភាព ២.១ : ការសម្រេចបាន គ.អ.ស.ក. តាមចំណុចដៅនិងសូចនាករ







*ប្រភព : របាយការណ៍នៃការសម្រេចបាន គ.អ.ស.ក. ក្រសួងផែនការ*

តារាង ២.១ បង្ហាញថាការអនុវត្តនៅកម្ពុជាមានភាពល្អប្រសើរបំផុត ជាពិសេស លើការកាត់បន្ថយភាពក្រីក្រ ដែលជាចំណុចដៅនៃគោលដៅទី១និងសុខភាពកុមារ និងមាតានៃគោលដៅទី៤និងទី៥។ ចំណុចដៅជាច្រើន ត្រូវបានសម្រេចមុនឆ្នាំកំណត់ ហើយការខិតខំអនុវត្តដើម្បីសម្រេចបានចំណុចដៅទាំងនោះ មានកម្រិតលើសពីស្តង់ដាដែលបានកំណត់។

## តារាង ២.១ : សេចក្តីសង្ខេបពីការអនុវត្ត គ.អ.ស.ក. នៅកម្រិតចំណុចដៅ

| គោលដៅ | ចំណុចដៅ | ការអនុវត្ត |
|---|---|---|
| ១. លុបបំបាត់ភាពក្រីក្រនិងភាពអត់ឃ្លានធ្ងន់ធ្ងរ | (១a) កាត់បន្ថយឲ្យបានពាក់កណ្តាលសមាមាត្រនៃប្រជាជនរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្ររបស់ជាតិ | សម្រេចបាន |
| | (១b) កាត់បន្ថយសមាមាត្រប្រជាជនដែលទទួលរងនូវភាពអត់ឃ្លាន | សម្រេចបាន |
| | (១c) បង្កើនចំណែកនៃចំណូលរបស់ប្រជាជនក្របំផុត២០% | មិនទាន់សម្រេចបាន |
| | (១d) លើកកម្ពស់អាហារូបត្ថម្ភនិងលុបបំបាត់ភាពក្រិន | មិនទាន់សម្រេចបាន |
| ២. សម្រេចឲ្យបានសកលកម្មអក្ខរកម្ម និងការអប់រំបឋមសិក្សា | (២a) សម្រេចឲ្យបាន១០០% ការសិក្សាពិតនៅកម្រិតបឋមសិក្សា | ហៀបនឹងសម្រេចបាន |
| | (២b) សម្រេចឲ្យបាន១០០% អត្រាបញ្ចប់ការសិក្សានៅកម្រិតសិក្សាបឋមភូមិ | មិនទាន់សម្រេចបាន |
| | (២c) សម្រេចឲ្យបានសកលកម្មអក្ខរកម្ម ក្នុងចំណោមប្រជាជនអាយុ ពី ១៥-២៥ឆ្នាំ | ហៀបនឹងសម្រេចបាន |
| | (២d) សម្រេចឲ្យបាននូវសមភាពយេនឌ័រ នៅកម្រិតបឋមសិក្សា | សម្រេចបាន |
| ៣. លើកកម្ពស់សមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី | (៣a) សម្រេចឲ្យបានសមភាពយេនឌ័រក្នុងវិស័យអប់រំនិងអក្ខរកម្ម | សម្រេចបាន |
| | (៣b) ផ្តល់សិទ្ធិអំណាចដល់ស្ត្រីក្នុងការងារទទួលបានប្រាក់ឈ្នួល | មិនទាន់សម្រេចបាន |
| | (៣c) ផ្តល់សិទ្ធិអំណាចដល់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្ត | មិនទាន់សម្រេចបាន |
| | (៣d) បញ្ចប់អំពើហិង្សាលើយេនឌ័រ | មិនមានចំណុចដៅ |
| ៤. កាត់បន្ថយអត្រាមរណភាពកុមារ | (៤a) កាត់បន្ថយអត្រាមរណភាពទារក | សម្រេចបាន |
| | (៤b) កាត់បន្ថយអត្រាមរណភាពកុមារក្រោមអាយុ៥ឆ្នាំ | សម្រេចបាន |
| ៥. លើកកម្ពស់សុខភាពមាតា | (៥a) កាត់បន្ថយអត្រាមរណភាពមាតា | សម្រេចបាន |
| | (៥b) បង្កើនអត្រាសម្រាលកូនដោយបុគ្គលិកសុខាភិបាលមានជំនាញ | សម្រេចបាន |
| ៦. ការប្រយុទ្ធប្រឆាំងមេរោគអេដស៍ ជំងឺអេដស៍ ជំងឺគ្រុនចាញ់ និងជំងឺផ្សេងៗទៀត | (៦a) កាត់បន្ថយអត្រាប្រេវ៉ាឡង់មេរោគអេដស៍ក្នុងចំណោមប្រជាជនទូទៅ | សម្រេចបាន |
| | (៦b) កាត់បន្ថយ អត្រាស្លាប់ដោយជំងឺរបេងនិងអត្រាប្រេវ៉ាឡង់ | សម្រេចបាន |
| | (៦c) កាត់បន្ថយអត្រាស្លាប់ដោយជំងឺគ្រុនចាញ់ | សម្រេចបាន |
| ៧. ធានាចីរភាពបរិស្ថាន | (៧a) បញ្ចូលគោលការណ៍អភិវឌ្ឍប្រកបដោយចីរភាពនិងការថយចុះនៃធនធានធម្មជាតិ | មិនមានចំណុចដៅ |
| | (៧b) សម្រេចឲ្យបាន ការទទួលបានទឹកសុវត្ថិភាពបរិភោគ និងអនាម័យ នៅតំបន់ជនបទនិងតំបន់ទីប្រជុំជន | សម្រេចបាន |
| | (៧c) កាត់បន្ថយ ការពឹងផ្អែករបស់គ្រួសារកម្ពុជា លើអុសសម្រាប់ប្រើជាថាមពល | មិនទាន់សម្រេចបាន |
| | (៧d) បង្កើនសមាមាត្រប្រជាជនកាន់កាប់ដីធ្លីប្រកបដោយចីរភាព | សម្រេចបាន |
| ៨. បង្កើតភាពជាដៃគូជាសកលសម្រាប់កិច្ចអភិវឌ្ឍ | មិនមានចំណុចដៅ | មិនមានចំណុចដៅ |
| ៩. ការបោសសម្អាតមីន សំណល់ជាតិផ្ទុះពីសង្គ្រាម និងការសង្គ្រោះជនពិការដោយសារមីន | (៩a) កាត់បន្ថយចំនួនប្រជាជនដែលរងគ្រោះដោយសារមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម | សម្រេចបាន |
| | (៩b) ផ្ទៃដីដែលបានបោសសម្អាតមីននិងយុទ្ធភណ្ឌមិនទាន់ផ្ទុះពី សង្គ្រាម | សម្រេចបាន |

*ប្រភព : ក្រសួងផែនការ*

ការកាត់បន្ថយភាពក្រីក្រ ពិតសម្រេចបានគួរជាទីមោទនៈ ដោយកម្ពុជាសម្រេចបានការកាត់បន្ថយ អត្រានៃភាពក្រីក្រឲ្យថយចុះពាក់កណ្តាល នៅក្នុងឆ្នាំ២០១២ គឺមុនកាលកំណត់ចំនួន៣ឆ្នាំ។ កម្ពុជាក៏សម្រេចបានវឌ្ឍនភាពជាច្រើនលើការបោសសម្អាតមីននិងយុទ្ធភណ្ឌមិនទាន់ផ្ទុះសល់ពីសង្គ្រាម ដែលជាគោលដៅពិសេសរបស់កម្ពុជា។

ទោះជាដូចនេះក្តី មានចំណុចដៅមួយចំនួននៃ គ.អ.ស.ក. នៅមិនទាន់សម្រេចបាននៅឡើយ។ ស្របពេលដែលគម្លាតទាំងនេះត្រូវបានបង្ខិតឲ្យកាន់តែជិតគ្នា ឬហៀបនឹងសម្រេចបាននៅឆ្នាំ២០១៥ ជាពិសេស នៅក្នុងវិស័យអប់រំនិងសិទ្ធិអំណាចដល់ស្ត្រី នៅមានបញ្ហាមួយចំនួន មិនទាន់បានសម្រេចនៅឡើយ។ ការសម្រេចមិនបានគ្រប់ចំណុចដៅពាក់ព័ន្ធនឹងបរិស្ថាននៃគោលដៅទី៧ ចំណុចដៅពាក់ព័ន្ធនឹងអាហារូបត្ថម្ភនៃគោលដៅទី១ និងការកាត់បន្ថយអត្រាស្លាប់ដោយជំងឺរបេងនៃគោលដៅទី៦ នឹងត្រូវដោះស្រាយបន្តនៅក្នុងក្របខ័ណ្ឌ គ.អ.ច.ក.។

## ២.៣- ការពិនិត្យមើលឡើងវិញតាមគោលដៅនីមួយៗ

### ២.៣.១- គោលដៅទី១៖ លុបបំបាត់ភាពក្រីក្រនិងភាពអត់ឃ្លានធ្ងន់ធ្ងរ

កម្ពុជាសម្រេចបានវឌ្ឍនភាពគួរជាទីមោទន ក្នុងការកាត់បន្ថយភាពក្រីក្រ។ អត្រានៃប្រជាជនក្រីក្របានថយចុះពី៥៣,៣%នៅក្នុងឆ្នាំ២០០៤ មកត្រឹម១៣,៥%នៅក្នុងឆ្នាំ២០១៤។ ដូចគ្នានេះដែរ តារាង ២.២ អត្រានៃប្រជាជនអត់ឃ្លាន(ប្រជាជនដែលរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រម្ហូបអាហារ) ត្រូវបានកាត់បន្ថយពីប្រមាណ២០%នៅក្នុងឆ្នាំគោល មកសូន្យ និងបានកាត់បន្ថយវិសមភាព ដែលក្នុងនោះ ចំណែកនៃការប្រើប្រាស់របស់ប្រជាជនមានចំណូលទាបបំផុត២០% បានកើនឡើងពី៦,៨៥%ក្នុងឆ្នាំ២០០៧ មក៩%នៅឆ្នាំ២០១៤។

**តារាង ២.២ : ការអនុវត្តគោលដៅទី១**

| ល.រ | សូចនាករ | | សមិទ្ធផល | | | | |
|---|---|---|---|---|---|---|---|
| | | ឯកតា | ២០០០ | ២០០៥ | ២០១០ | ២០១៥ ជាក់ស្តែង | ២០១៥ ចំណុចដៅ |
| (១a) កាត់បន្ថយឲ្យបានពាក់កណ្តាលសមាមាត្រនៃប្រជាជនរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្ររបស់ជាតិ | | | | | | | |
| ១ | កាត់បន្ថយសមាមាត្រប្រជាជនរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រដល់ទាបជាង១៩,៥% | % | ៣៩,៥ (១៩៩៣) | ៤៧,៨ (២០០៧) | ២១,១ | ១៣,៥ (២០១៤) | ≤ ១៩,៥ |
| (១b) កាត់បន្ថយសមាមាត្រប្រជាជនដែលទទួលរងនូវភាពអត់ឃ្លាន | | | | | | | |
| ២ | កាត់បន្ថយសមាមាត្រប្រជាជនរស់នៅក្នុងភាពអត់ឃ្លានឲ្យទាបជាង១០% | % | ២០,០ (១៩៩៣) | ៤,៣២ | ៤,០៧ | ០ (២០១៤) | ≤ ១,០ |
| (១c) បង្កើនចំណែកនៃចំណូលរបស់ប្រជាជនក្របំផុត ២០% | | | | | | | |
| ៣ | បង្កើនចំណែកនៃចំណូលរបស់ប្រជាជនក្រីក្របំផុត២០% ឲ្យដល់១១% | % | ៧,៤ (១៩៩៣) | ៦,៨៥ (២០០៧) | ៧,៩ | ៩,០ (២០១៤) | ≥ ១១,០ |
| (១d) លើកកម្ពស់អាហារូបត្ថម្ភនិងលុបបំបាត់ភាពគ្រិន | | | | | | | |
| ៤ | កាត់បន្ថយប្រេវ៉ាឡង់នៃកុមារខ្វះគ្រប់ទម្ងន់(អាយុក្រោម៥ឆ្នាំ) | % | ៤៥,២ | ២៨,០ | ២៨,០ | ២៣,០ (២០១៤) | ≤ ១៩,០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៥ | កាត់បន្ថយប្រេវ៉ាឡង់នៃកុមារគ្រិន | % | ៤៤,៦ | ៤៣,០ | ៤០,០ | ៣២,០ (២០១៤) | ≤ ២៥,០ |
| ៦ | កាត់បន្ថយប្រេវ៉ាឡង់នៃកុមារស្គមស្គាំង | % | ១៥,០ | ៨,០ | ១១,០ | ១០,០ | ≤ ៩,០ |
| ៧ | កាត់បន្ថយប្រេវ៉ាឡង់កង្វះគ្រាប់ឈាមរបស់កុមារអាយុ៦-៥៩ខែ | % | - | ៦២,០ | ៥៥,០ | ៥៦,០ (២០១៤) | ៤២,០ |
| ៨ | កាត់បន្ថយប្រេវ៉ាឡង់កង្វះគ្រាប់ឈាមរបស់ស្ត្រីអាយុ១៥-៤៩ឆ្នាំ | % | - | ៤៧,០ | ៤៤,០ | 45.0 (២០១៤) | ៤២,០ |
| ៩ | បង្កើនសមាមាត្រគ្រួសារដែលប្រើប្រាស់អំបិលអ៊ីយ៉ូដ | % | - | - | ៨៣,០ | - | ៩០,០ |
| ១០ | កាត់បន្ថយអត្រានៃពលកម្មកុមារ (តិចជាងឬស្មើអាយុ១៧ឆ្នាំ)នៃចំនួនកុមារសរុបនៅក្នុងក្រុមអាយុនោះ | % | ១៦,៥ (១៩៩៩) | - | ១៦,៨ | ១៩,៣ (២០១៤) | ≤ ៨,០ |

*ប្រភព÷ ក្រសួងផែនការ*

លទ្ធផលនេះ ជាសមិទ្ធផលធំៗដែលជាកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំនិងកិច្ចខិតខំប្រឹងប្រែងសម្របសម្រួលរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីរក្សាឲ្យបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ការបើកទូលាយទីផ្សារ និងជំរុញកំណើនសេដ្ឋកិច្ច។ ការកាត់បន្ថយភាពក្រីក្រ សម្រេចបានដោយសារកំណើនសេដ្ឋកិច្ច និងការបែងចែកប្រកបដោយសមធម៌។ ទោះជាដូចនេះក្តី ការរក្សាបាននូវការកាត់បន្ថយភាពក្រីក្រទៅអនាគត គឺជាបញ្ហាប្រឈម ដោយសារប្រជាជនក្រីក្រមានការលំបាកក្នុងការទទួលបានការបែងចែកកំណើនប្រកបដោយសមធម៌ពីកំណើនសេដ្ឋកិច្ច។ លើសពីនេះ តាមរយៈការវិភាគលទ្ធផលខាងលើ បង្ហាញថា រាជរដ្ឋាភិបាលកម្ពុជាត្រូវបង្កើនកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតដើម្បីធានាឲ្យបានថា ប្រជាជនកំពុងរស់នៅលើខ្សែបន្ទាត់ភាពក្រីក្រនឹងមិនធ្លាក់ចុះក្រោមខ្សែបន្ទាត់ភាពក្រីក្រវិញ។

ដូចគ្នានេះដែរ នៅពេលដែលសមភាពនៃប្រាក់ចំណូលត្រូវបានផ្តល់ ការរីកចម្រើននេះ មានការធ្លាក់ចុះខ្លះតាមចំណុចដៅមួយចំនួន។ បន្ថែមលើនេះទៀតនៅពេលអនាគត ការរីកចម្រើននៃសេដ្ឋកិច្ចកម្ពុជា តាមរយៈការធ្វើពិពិធកម្មជាមូលដ្ឋានទៅកផលិតកម្មដែលមានតម្លៃបន្ថែមខ្ពស់ និងផ្តល់ជំនាញមានបៀវត្សរ៍ខ្ពស់ នឹងនាំឲ្យការសម្រេចបានសមភាពនៃប្រាក់ចំណូលកាន់តែមានការពិបាក។ ស្រដៀងគ្នានេះដែរ គឺការបន្តមានគម្លាតប្រាក់ចំណូលរបស់ប្រជាជននៅតំបន់ទីប្រជុំជននិងជនបទ។ រូបភាព ២.២. ខាងក្រោម បង្ហាញថា អត្រានៃភាពក្រីក្រនៅតាមបណ្តាខេត្តមានភាពខុសគ្នា។ ភាពក្រីក្រត្រូវបានប៉ាន់ស្មានខ្ពស់ដល់ទៅ២៨% នៅក្នុងខេត្តរតនគិរី និងឧត្តរមានជ័យ[4]។ ប្រហាក់ប្រហែលគ្នានេះដែរ កង្វះអាហារូបត្ថម្ភ ត្រូវបានបង្ហាញថា មានកម្រិតខ្ពស់ជាង៤០% នៅខេត្តព្រះវិហារ និងកំពង់ឆ្នាំង។ ការខិតខំប្រឹងប្រែងបន្តដើម្បីធ្វើសម្រេចឲ្យមានវឌ្ឍនភាពនៅថ្នាក់ក្រោមជាតិ គឺជាអាទិភាពដែលត្រូវអនុវត្ត។

[4] *វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ ការប៉ាន់ស្មានតំបន់តូចៗ*

## រូបភាព ២.២ : ការប៉ាន់ស្មានពីអត្រាភាពក្រីក្រនៅតាមខេត្ត (ឆ្នាំ២០១៤)




*ប្រភព : ក្រសួងផែនការ*

ការលុបបំបាត់ភាពក្រីក្រធ្ងន់ធ្ងរឬភាពក្រីក្រម្ហូបអាហារ(ដែលកំណត់ថាជាភាពអត់ឃ្លាន) ក៏ទទួលបានជោគជ័យយ៉ាងត្រចះត្រចង់ ដែលធ្វើឲ្យរាជរដ្ឋាភិបាលកម្ពុជាទទួលការគាំទ្រពីបញ្ហានេះ។ ប៉ុន្តែ ទិន្នន័យសម្រាប់វាស់វែងសូចនាករពាក់ព័ន្ធនឹងភាពក្រិន និងខ្វះទម្ងន់នៅមានកម្រិត(តារាង ២.៣) ដែលទាមទារឱ្យមានកិច្ចខិតខំប្រឹងប្រែងនិងធនធានថ្មីៗបន្ថែមទៀតដើម្បីបំពេញតម្រូវការខាងលើ។ លទ្ធផលជាវិជ្ជមាន ចំពោះកុមារមានភាពស្លេកស្លាំងត្រូវបានកាត់បន្ថយ ហើយចំណុចដៅសម្រាប់ការប្រើប្រាស់អំបិលអ៊ីយ៉ូតត្រូវបានសម្រេចតាមកាលកំណត់។

### ២.៣.២- គោលដៅទី២៖ សម្រេចឲ្យបានសកលកម្មអក្ខរកម្មនិងការអប់រំបឋមសិក្សា

ការអនុវត្តរបស់កម្ពុជាពាក់ព័ន្ធនឹងគោលដៅអប់រំ ទទួលបានលទ្ធផលចម្រុះ (តារាង ២.៣.)។ វិស័យអប់រំសម្រេចបានជោគជ័យ អត្រាអក្ខរកម្មរបស់ប្រជាជនអាយុពី១៥ ដល់២៥ឆ្នាំ កើនឡើងគួរឲ្យកត់សម្គាល់សម្រាប់ ដោយកើនឡើងពី៨០,៤%នៅឆ្នាំ២០០០ ដល់៩៣,០%នៅឆ្នាំ២០១៣។ អត្រាពិតនៃការសិក្សានៅកម្រិតបឋមសិក្សាបានកើនឡើងពី៨៥,០%នៅឆ្នាំ២០០០ ដល់៩៨,០%នៅឆ្នាំ២០១៥ ហើយគម្លាតយេនឌ័រក្នុងផ្នែកវត្តមានសិស្សក្នុងសាលា នៅរក្សាដដែលមិនកើនឡើង។ ចំណុចដៅនីមួយៗ ក្នុងវិស័យនេះសម្រេចបានតាមការកំណត់។

ប៉ុន្តែ អត្រាួម និង អត្រាបញ្ចប់ការសិក្សា នៅកម្រិតខ្ពស់ជាងនេះ សម្រេចបានកម្រិតទាបដែលចាំបាច់ត្រូវមានវិធានការបន្ថែមទៀត។ នៅឆ្នាំ២០១៥ អត្រាួមនៃការសិក្សានៅកម្រិតមធ្យមសិក្សាបឋមភូមិសម្រេចបាន៥៥,១% និងអត្រាបញ្ចប់ការសិក្សានៅកម្រិតមធ្យមសិក្សាបឋមភូមិសម្រេចបាន៨៤,១% និងទុតិយភូមិសម្រេចបាន៤០,៣%។

## តារាង ២.៣ : ការអនុវត្តគោលដៅទី២ នៃ គ.អ.ស.ក.

| ចំណុចដៅ/ សូចនាករ | | សមិទ្ធផល | | | | |
|---|---|---|---|---|---|---|
| | ឯកតា | ២០០០ | ២០០៥ | ២០១០ | ២០១០ ជាក់ស្តែង | ២០១៥ ចំណុចដៅ |
| (២a) សម្រេចឲ្យបាន ១០០% ការសិក្សាពិតនៅកម្រិតបឋមសិក្សា | | | | | | |
| អត្រាអក្ខរកម្ម ក្នុងចំណោមប្រជាជនអាយុ ១៥-២៤ឆ្នាំ ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០១៣ | % | | ៨០,៤ | ៨៨,៨ | ៩៣,០ | ៩៤,៥ |
| (២b) សម្រេចឲ្យបាន ១០០% អត្រាបញ្ចប់ការសិក្សានៅកម្រិតសិក្សាបឋមភូមិ | | | | | | |
| អត្រាពិតនៃការសិក្សានៅកម្រិតបឋមសិក្សា | % | ៨៥,០ (២០០១) | ៧៦,៦ | ៨៥,៦ | ៩៧,៩ (២០១៤/១៥) | ១០០ |
| (២c) សម្រេចឲ្យបានសកលកម្មអក្ខរកម្ម ក្នុងចំណោមប្រជាជនអាយុ ពី ១៥-២៤ឆ្នាំ | | | | | | |
| អត្រាសរុបនៃការសិក្សានៅកម្រិតមធ្យមសិក្សាបឋមភូមិ | % | - | ៤៥,៨ | ៥៨,១ | ៥៥,១ | ៧៤,០ |
| អត្រាបញ្ចប់ការសិក្សានៅកម្រិតបឋមសិក្សា | | ៥១ (២០០១ | ៤៦,៨ | ៨៣,២ | ៨៤,១ | ១០០ |
| អត្រាបញ្ចប់ការសិក្សានៅកម្រិតមធ្យមសិក្សាបឋមភូមិ | % | - | ១៩,៧ | ៤៨,៧ | ៤០,៣ | ១០០ |
| (២d) សម្រេចឲ្យបាននូវសមភាពយេនឌ័រ នៅកម្រិតបឋមសិក្សា | | | | | | |
| សន្ទស្សន៍យេនឌ័រនៅកម្រិតបឋមសិក្សា | សន្ទស្សន៍ | ០,៩៥ | ០,៩៧ | ០,៩១ | ១ | ១ |
| សន្ទស្សន៍យេនឌ័រនៅកម្រិតមធ្យមសិក្សាបឋមភូមិ | សន្ទស្សន៍ | ០,៦៨ | ០,៧៩ | ០,៩៧ | ១,១ | ១ |

*ប្រភព : ក្រសួងផែនការ*

សមិទ្ធផលសំខាន់ៗក្នុងគោលដៅទី២ នៃ គ.អ.ស.ក. ត្រូវបានជំរុញយ៉ាងខ្លាំងដោយគោលនយោបាយ។ គំនិតផ្តួចផ្តើមរបស់ ក្រសួងអប់រំ យុវជន និងកីឡា តាមរយៈការផ្តល់ចំណីអាហារដល់សិស្ស ការមិនយកថ្លៃសិក្សា ការសាងសង់សាលានៅជិតភូមិប្រជាជន និងការផ្តោតការយកចិត្តទុកដាក់លើសមាសភាពយេនឌ័រ បានជួយជំរុញកុមារឲ្យទៅសិក្សា។ ម្យ៉ាងទៀត ការគាំទ្រថវិការបស់រាជរដ្ឋាភិបាលដើម្បីពង្រីកនិងពង្រឹងមជ្ឈមណ្ឌលអប់រំសហគមន៍ ក៏បានចូលរួមចំណែកយ៉ាងសំខាន់ដល់ការលើកកម្ពស់កម្រិតអក្ខរកម្មរបស់ប្រជាជន។ ទោះជាដូចនេះក្តី បញ្ហាប្រឈមមួយចំនួននៅតែបន្តក្នុងផ្នែកគុណភាពអប់រំ និងកម្រិតនៃវឌ្ឍនភាពនៅតាមសាលានិងខេត្ត។

ការបង្កើនអត្រាបញ្ចប់ការសិក្សា គឺជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីបំពេញតាមតម្រូវការទីផ្សារការងារ និងផ្តល់ផលប្រយោជន៍ដល់ការងារទាំងមូល។ កិច្ចខិតខំប្រឹងប្រែងដើម្បីដោះស្រាយកម្រិតភាពក្រីក្រនៅខេត្តនិងតំបន់ដាច់ស្រយាល មានសារៈសំខាន់ក្នុងការអនុញ្ញាតឲ្យឪពុកម្តាយបញ្ជូនកូនទៅសាលារៀន និងការបង្កើននូវការយល់ដឹងពីផលប្រយោជន៍រយៈពេលវែងពីការសិក្សានៅក្នុងចំណោមសហគមន៍ទាំងនោះក៏មានសារៈសំខាន់ផងដែរ។ ការផ្តល់បរិយាកាសអំណោយផលតាមរយៈមធ្យោបាយងាយស្រួលដល់ស្ត្រី និងហេដ្ឋារចនាសម្ព័ន្ធសម្រាប់ជំរុញឲ្យមានការងាយស្រួលធ្វើដំណើរទៅសាលារៀន(ផ្លូវតភ្ជាប់ពីសាលាទៅភូមិរបស់ប្រជាជន) គឺជាអាទិភាពដែលត្រូវអនុវត្តបន្ត។

ការបង្កើនតម្រូវការតាមរយៈ ការលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការសិក្សាជាមូលដ្ឋាននៅក្នុងសាលា និងការពង្រឹងការបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ គឺជាលក្ខខណ្ឌដ៏សំខាន់។

រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចំណុចទាំងនេះ ជាគោលនយោបាយអាទិភាពនៅក្នុងយុទ្ធសាស្ត្រចតុកោណគ្រប់ដំណាក់កាល ដោយទទួលស្គាល់ថាការអប់រំគឺជាស្នូលនៃការអភិវឌ្ឍធនធានមនុស្ស ហើយក៏ជាកត្តាជោគជ័យសម្រាប់ការរីកចម្រើននិងអភិវឌ្ឍប្រទេសជាតិ។

### ២.៣.៣- គោលដៅទី៣ : លើកកម្ពស់សមភាពយេនឌ័រនិងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី

ការអនុវត្តក្នុងគោលដៅទី៣ពាក់ព័ន្ធយេនឌ័រ គឺទទួលបានលទ្ធផលចម្រុះ។ នៅក្នុងវិស័យនេះ មានតែសូចនាករក្នុងចំណុចដៅ៣ប៉ុណ្ណោះ ហើយគ្មានប្រភពទិន្នន័យសម្រាប់គាំទ្រដល់សូចនាករស្តីពីអំពើហិង្សាក្នុងគ្រួសារទេ។ ទោះជាដូចនេះក្តី តាមរយៈតារាង ២.៤ បានបង្ហាញច្បាស់ថា មានតែសូចនាករមួយតែប៉ុណ្ណោះ(សមភាពក្នុងការអប់រំនិងអក្ខរកម្ម) ដែលសម្រេចបានតាមចំណុចដៅកំណត់។

**តារាង ២.៤ : ការអនុវត្តគោលដៅទី៣នៃ គ.អ.ស.ក.**

| ល.រ | សូចនាករ | ឯកតា | សមិទ្ធផល | | | | |
|---|---|---|---|---|---|---|---|
| | | | ២០០០ | ២០០៥ | ២០១០ | ២០១៥ ជាក់ស្តែង | ២០១៥ ចំណុចដៅ |
| | (៣a) សម្រេចឲ្យបានសមភាពយេនឌ័រក្នុងវិស័យអប់រំនិងអក្ខរកម្ម | | | | | | |
| 1 | អត្រាភេទ (ស្ត្រី/ប្រុស) នៅកម្រិតមធ្យមសិក្សាទុតិយភូមិ | % | ៤៨ (២០០១) | ៦០ | ៨២ | ១០០ | ១០០ |
| 2 | អត្រាភេទ (ស្ត្រី/ប្រុស) នៅកម្រិតឧត្តមសិក្សា | % | ៣៨ (២០០១) | ៤៥,៦ | ៨៦,៧ | ៨៥ | ៨៥ |
| 3 | អត្រាភេទ (ស្ត្រី/ប្រុស) អាយុ ១៥-២៤ឆ្នាំ នៃអក្ខរកម្ម | % | ៨៧ (១៩៩៨) | ៩០ | ៩៨,៣ | ១០០ | ១០០ |
| 4 | អត្រាភេទ (ស្ត្រី/ប្រុស) អាយុ ២៥-៤៤ឆ្នាំ នៃអក្ខរកម្ម | % | ៧៨ (១៩៩៨) | ៨០ | ៩៩ | ១០០ | ១០០ |
| | (៣b) ផ្តល់សិទ្ធិអំណាចដល់ស្ត្រីក្នុងការងារទទួលបានប្រាក់ឈ្នួល | | | | | | |
| 5 | ស្ត្រីធ្វើការងារមានបៀវត្សរ៍ក្នុងគ្រប់វិស័យ | % | - | - | ៤២,២ | - | ៥០ |
| 6 | សមាមាត្រស្ត្រីធ្វើការមានបៀវត្សរ៍ ក្នុងវិស័យកសិកម្ម | % | ៣៥,០ (១៩៩៨) | ៥២,៥ | ៥៣,០ | ៤៥,៧ (២០១៣) | ៥០ |
| 7 | សមាមាត្រស្ត្រីធ្វើការមានបៀវត្សរ៍ វិស័យឧស្សាហកម្ម | % | ៤៤ (១៩៩៨) | ៥៣,៣ | ៧៣,៧ | ៤៥,៤ | ៥០ |
| 8 | សមាមាត្រស្ត្រីធ្វើការមានបៀវត្សរ៍ វិស័យសេវាកម្ម | % | ២១,០ | ២៧,០ | ២៧,៤ | ៣២,០ | ៥០ |

| ល.រ | សូចនាករ | | សមិទ្ធផល | | | | |
| --- | --- | --- | --- | --- | --- | --- | --- |
| | | ឯកតា | ២០០០ | ២០០៥ | ២០១០ | ២០១៥ ជាក់ស្តែង | ២០១៥ ចំណុចដៅ |
| | | | (១៩៩៨) | | | (២០១៣) | |
| (៣c) ផ្តល់សិទ្ធិអំណាចដល់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្ត | | | | | | | |
| 9 | សមាមាត្រនៃអាសនៈរបស់ស្ត្រីនៅក្នុងសភាជាតិ | % | ១២,៣ (១៩៩៨) | ១៩,៥ (២០០៣) | ២១ (២០០៨) | ២០,៣២ (២០១៣) | ៣០ |
| 10 | សមាមាត្រនៃអាសនៈរបស់ស្ត្រីនៅក្នុងព្រឹទ្ធសភា | % | ១៤,៧៥ (១៩៩៩) | ១៤,៧៥ (២០០៦) | ១៤,៧៥ (២០១២) | ១៤,៧៥ (២០១២) | ៣០ |
| 11 | សមាមាត្ររបស់ស្ត្រីជារដ្ឋមន្ត្រី | % | ៧,៤ (១៩៩៨) | ៧,១ (២០០៣) | ៧,១ (២០០៨) | ១០,៧ (២០១៣) | ១៥ |
| 12 | សមាមាត្ររបស់ស្ត្រីជារដ្ឋលេខាធិការ | % | ៦ (១៩៩៨) | ៦,៦ (២០០៣) | ៨ (២០០៨) | ២០,៥៤ (២០១៣) | ១៨ |
| 13 | សមាមាត្ររបស់ស្ត្រីជាអនុរដ្ឋលេខាធិការ | % | ៤ (១៩៩៨) | ៧.៥ (២០០៣) | ១៥,១ (២០០៨) | ១៧,៦ (២០១៣) | ២០ |
| 14 | សមាមាត្ររបស់ស្ត្រីជាអភិបាលរាជធានី ខេត្ត | % | 0 | 0 | 0 | 0 | ១០ |
| 15 | សមាមាត្ររបស់ស្ត្រីជាអភិបាលរងរាជធានី ខេត្ត | % | 0 | ១ (២០០៣) | ២០ (២០១១) | ១៧ (២០១៤) | ១៥ |
| 16 | សមាមាត្រនៃអាសនៈរបស់ស្ត្រីនៅក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ | % | - | ៩,០ (២០០២) | ១៥,១ (២០០៧) | ១៧,៨ (២០១២) | ២៥ |
| (៣d) បញ្ចប់អំពើហិង្សាលើយេនឌ័រ | | | | | | | |
| 17 | ចំនួនដងការការពារអំពើហិង្សាលើស្ត្រីភេទ បែងចែកតាមបញ្ហា | ចំនួនដង | - | - | - | - | - |

*ប្រភព៖ ក្រសួងផែនការ*

ទោះជាដូចនេះក្តី ទាំងសូចនាករនៃការធ្វើសេចក្តីសម្រេចចិត្តផ្នែកនយោបាយ និងសេវាសាធារណៈផ្នែកយេនឌ័រ បានបង្ហាញពីការកែលម្អយ៉ាងខ្លាំង ទោះបីជាមានកម្រិតលម្អៀងក្តី ជាពិសេសគឺសមាមាត្រនៃអាសនៈរបស់ស្ត្រីក្នុងរដ្ឋសភា និងសមាមាត្រស្ត្រីជារដ្ឋលេខាធិការ។ វឌ្ឍនភាពនៃយេនឌ័រក្នុងវិស័យសេដ្ឋកិច្ច នៅមានកម្រិតទាបជាងចំណុចដៅនៅឡើយ ជាពិសេស ស្ត្រីធ្វើការងារមានបៀវត្សរ៍នៅក្នុងគ្រប់វិស័យ និងវឌ្ឍនភាពថ្មីៗនេះ ក្នុងវិស័យឧស្សាហកម្មនិងកសិកម្ម ដែលបង្ហាញថាសូចនាករទាំងពីរត្រូវបានធ្វើឲ្យសម្រេចចំណុចដៅនៅឆ្នាំ២០០៥ និង២០១០ បានថយចុះបន្តិចនៅឆ្នាំ២០១៥។

រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់យ៉ាងខ្លាំង អំពីស្ថានភាពអំពើហិង្សាប្រឆាំងនឹងស្ត្រី ប៉ុន្តែដោយសារកង្វះទិន្នន័យ ពិតជាមានការលំបាកក្នុងការរៀបរាប់អំពីស្ថានភាពអំពើហិង្សាប្រឆាំង

នឹងស្ត្រី។ រាជរដ្ឋាភិបាលបានអនុម័តច្បាប់មួយចំនួននៅក្នុងកំឡុងពេលនៃ គ.អ.ស.ក. ដើម្បីការពារសិទ្ធិរបស់ស្ត្រីនិងកុមារី រួមទាំងច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងការការពារជនរងគ្រោះ(ឆ្នាំ២០០៥) និងច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្សនិងការកេងប្រវ័ញ្ចផ្លូវភេទ(ឆ្នាំ២០០៧)។ បន្ថែមលើនេះទៀត ផែនការសកម្មភាពទី២ ដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រី ត្រូវបានប្រកាសផ្សព្វផ្សាយនៅឆ្នាំ២០១៥។

ជាទូទៅ សមភាពយេនឌ័រ គឺជាវិស័យគន្លឹះដែលមិនទាន់សម្រេចបានតាមគោលដៅកំណត់ ដែលទាមទារឲ្យផ្តោតការយកចិត្តទុកដាក់នៅក្នុងរបៀបវារៈ គ.អ.ច.ក.។ ការអនុវត្តយេនឌ័រនេះ ផ្តោតលើវិស័យជាក់លាក់ ដែលលើកកម្ពស់ទិន្នន័យអប់រំ និងបង្ហាញពីឆន្ទៈរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការសម្រេចបាននូវសមភាពយេនឌ័រក្នុងសេវាសាធារណៈ។ ការប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាលើស្ត្រី គឺជាបញ្ហាជាក់លាក់មួយ ហើយការកំណត់ទិន្នន័យដែលអាចទុកចិត្តបាន គឺជាអាទិភាពខ្ពស់បំផុត។

### ២.៣.៤- គោលដៅទី៤ : កាត់បន្ថយមរណភាពកុមារ

ដូចមានបង្ហាញច្បាស់នៅក្នុងតារាង ២.៥ កម្ពុជាសម្រេចបានលទ្ធផលគួរឲ្យកត់សម្គាល់ លើគោលដៅនេះ តាមរយៈសូចនាករមូលដ្ឋានចំនួន២(អត្រាមរណភាពទារកនិងកុមារក្រោមអាយុ៥ឆ្នាំ) បង្ហាញថា បានសម្រេចនៅមុនពេលកំណត់។ សូចនាករពាក់ព័ន្ធនឹងកុមារទទួលបានថ្នាំវ៉ាក់សាំងបង្ការ និងសមាមាត្រការបំបៅកូនដោយទឹកដោះម្តាយ ក៏បានបង្ហាញពីលទ្ធផលល្អក្នុងការអនុវត្តផងដែរ។ ទោះជាដូចនេះក្តី ការធ្វើឲ្យប្រសើរឡើងជាងនេះ នៅតែជាប្រការចាំបាច់។

**តារាង ២.៥ : ការអនុវត្តគោលដៅទី៤ នៃ គ.អ.ស.ក.**

| ល.រ | ចំណុចដៅ/ សូចនាករ | ឯកតា | សមិទ្ធផល | | | | |
|---|---|---|---|---|---|---|---|
| | | | ២០០០ | ២០០៥ | ២០១០ | ២០១០ ជាក់ស្តែង | ២០១៥ ចំណុចដៅ |
| (៤a) កាត់បន្ថយអត្រាមរណភាពទារក (4a) | | | | | | | |
| 1 | អត្រាមរណភាពទារកឲ្យនៅ៥០ ក្នុងឆ្នាំ ២០១៥ | /១០០០ កំណើតរស់ | ៩៥ (១៩៩៨) | ៦៦,០ | ៤៥,០ | ២៨ (២០១៤) | ៥០ |
| (៤b) កាត់បន្ថយអត្រាមរណភាពកុមារក្រោមអាយុ ៥ឆ្នាំ | | | | | | | |
| 2 | អត្រាមរណភាពកុមារក្រោមអាយុ ៥ឆ្នាំ | /១០០០ កំណើតរស់ | ១២៤,០ (១៩៩៨) | ៨៣,០ | ៥៤,០ | ៣៥ | ៦៥ |
| (៤c)បង្កើនការផ្តល់វ៉ាក់សាំងដល់កុមារ | | | | | | | |
| 3 | កុមារច្រើនជាង៩០% ទទួលបានការចាក់ថ្នាំ វ៉ាក់សាំង | % | ៧១,០ | ៧៩,០ | ៩២,០ | ៩៨ (២០១៤) | >៩០ |
| (៤d) បង្កើនការបំបៅដោះដល់កុមារ | | | | | | | |
| 4 | បង្កើនការបំបៅដោះដល់កុមាររហូតដល់អាយុ៦ខែ ឲ្យបាន៧០% | % | ១១,៤ | - | ៧៤,០ | ៦៣ (២០១៤) | ៧០ |

*ប្រភព : ក្រសួងផែនការ*

តាមការសង្កេតបង្ហាញថា ភាពជោគជ័យដែលទទួលបានមកនេះ លេចចេញពីលទ្ធផលនៃការធ្វើឲ្យប្រសើរឡើងសេវាទាំង២ប្រភេទ គឺសេវាថែទាំមុននិងក្រោយសម្រាលកូន(បុគ្គលិកសុខាភិបាលមានជំនាញនិងការផ្គត់ផ្គង់សម្ភារៈសុខាភិបាល) និង កំណើនយ៉ាងទូលំទូលាយផ្នែកសេដ្ឋកិច្ច សង្គមកិច្ច (ការកាត់បន្ថយភាពក្រីក្រនិងធ្វើឲ្យប្រសើរឡើងខាងផ្នែកអាហារូបត្ថម្ភ)។ តាមការវិភាគនៅថ្នាក់ក្រោមជាតិ ដោយប្រើប្រាស់ទិន្នន័យអង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា បានបង្ហាញយ៉ាងច្បាស់ថា គឺនៅគ្រប់រាជធានីខេត្តទោះជាច់ស្រយាលក្តី ក៏សម្រេចបានសូចនាករនេះ។ ភាពប្រសើរឡើងនេះស្របជាមួយនឹងវិធានការនានារបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានដាក់ចេញដើម្បីលើកកម្ពស់សុខុមាលភាពរបស់ប្រជាជន និងទិន្នន័យពីអាយុកាលសង្ឃឹមរស់ពីកំណើត ដែលបានពិភាក្សានៅក្នុងជំពូកទី១។ ប៉ុន្តែ ភាពខុសគ្នាពីខេត្តមួយ ទៅខេត្តមួយ គឺជាឫសគល់នៃវិសមភាព ចំណូលនិងជីវភាពរស់នៅ ការទទួលបានសេវាថែទាំសុខភាពដែលមានគុណភាព និងសេវាសាធារណៈផ្សេងទៀតរបស់ប្រជាជន។

### ២.៣.៥- គោលដៅទី៥ : កាត់បន្ថយមរណភាពមាតា

គោលដៅទី៥ ជាគូជាមួយគោលដៅទី៤ ក៏ត្រូវបានរាយការណ៍ថា មានការអនុវត្តយ៉ាងល្អប្រសើរ ដោយសម្រេចបានចំណុចដៅ២ ក្នុងចំណោមចំណុចដៅចំនួន៣ គឺអត្រាមរណភាពមាតា និងអត្រាផ្តល់កំណើត ប៉ុន្តែចំណុចដៅពាក់ព័ន្ធនឹងការថែទាំក្រោយពេលសម្រាល និងការប្រើប្រាស់វិធីសាស្ត្រពន្យារកំណើត មិនសម្រេចបានតាមការកំណត់ទេ។ តារាង ២.៦ បង្ហាញពីការធ្វើឲ្យប្រសើរឡើងជាតុចូលវេជ្ជសាស្ត្រសំខាន់ៗ រួមមាន វត្តមាននៃបុគ្គលិកសុខាភិបាលមានជំនាញសម្រាប់ការសម្រាលកូនបានកើនឡើងដល់៨៥% និងសម្រាប់ការថែទាំក្រោយពេលសម្រាលបានកើនដល់៩០% និងចំនួននៃសម្រាលដោយការវះកាត់មានការកើនឡើងខ្ពស់។ លទ្ធផលនេះកើតចេញពីការពង្រីកប្រព័ន្ធថែទាំសុខភាពរបស់កម្ពុជា ជាពិសេស នៅតំបន់ដាច់ស្រយាលនិងតំបន់ដែលមានការអភិវឌ្ឍសេដ្ឋកិច្ចទាប ដែលត្រូវបានផ្តល់អាទិភាពដោយរាជរដ្ឋាភិបាលកម្ពុជា។

**តារាង ២.៦ : ការអនុវត្តគោលដៅទី៥ នៃ គ.អ.ស.ក.**

| ល.រ | ចំណុចដៅ/ សូចនាករ | | សមិទ្ធផល | | | | |
|---|---|---|---|---|---|---|---|
| | | ឯកតា | ២០០០ | ២០០៥ | ២០១០ | ២០១០ ជាក់ស្តែង | ២០១៥ ចំណុចដៅ |
| (៥a) កាត់បន្ថយអត្រាមរណភាពមាតានិងការសម្រាលកូន | | | | | | | |
| ១ | អត្រាមរណភាពមាតា (ក្នុង១០០ ០០០ កំណើតរស់) | អត្រា | ៤៣៧ (១៩៩៧) | ៤៧២ | ២០៦ | ១៧០ (២០១៤) | ២៥០ |
| ២ | សមាមាត្រនៃការសម្រាលកូនជាមួយបុគ្គលិកសុខាភិបាលជំនាញ | % | ៣២ | ៤៤ | ៧១ | ៨៩ (២០១៤) | ៨៩ |
| ៣ | សមាមាត្រនៃការសម្រាលកូនដោយវិធីវះកាត់ | % | ១,១២ | ១,១៨ | ២,៥៦ | ៥,៣៧ (២០១៤) | ៨ |
| (៥b) ធ្វើឲ្យប្រសើរឡើងការប្រើប្រាស់មធ្យោបាយពន្យារកំណើត និងសេវាថែទាំមុននិងក្រោយសម្រាលកូន | | | | | | | |
| 4 | សមាមាត្រនៃស្ត្រីរៀបការ ប្រើប្រាស់មធ្យោ | % | ១៩ | ២១ | ២៤,៨២ | ៣៥ | ៦០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | បាយពន្យារកំណើតទំនើប | | | | (២០០៨) | (២០១៤) | |
| 5 | សមាមាត្រស្ត្រីមានផ្ទៃពោះ ទទួលបានការពិនិត្យផ្ទៃពោះ២ដងឬច្រើនជាងនេះ | % | ២៥,៤ | ៥២,២ | ៧២ | ៩០,៥ (២០១៤) | ៩០ |
| | (៥c) កាត់បន្ថយអត្រាផ្តល់កំណើត | | | | | | |
| 6 | អត្រាផ្តល់កំណើតសរុប | % | ៤,០ | ៣,៤ | ៣,០ | ២,៧ | ៣,០ |

*ប្រភព: ក្រសួងផែនការ*

ទោះជាដូចនេះក្តី ប្រការសំខាន់យើងត្រូវទទួលស្គាល់ថា តម្លៃនៃចំណុចដៅរបស់អត្រាមរណភាពមាតាដែលបានកំណត់ នៅមានកម្រិតខ្ពស់នៅឡើយធៀបនឹងស្តង់ដាអន្តរជាតិ។ ផ្ទុយទៅវិញ កំណើននៃការចំណាយសម្រាប់ការងារនេះ មានកម្រិតខ្ពស់ដែលទាមទារឲ្យមានការដោះស្រាយពីគុណភាពនិងប្រសិទ្ធភាពនៃការអនុវត្តការងារ។ បញ្ហាប្រឈមពាក់ព័ន្ធនឹងការប្រើប្រាស់ការពន្យារកំណើត ទទួលបានតែ៣៥% ប៉ុណ្ណោះធៀបនឹងចំណុចដៅកំណត់៦០% ហើយការមានផ្ទៃពោះក្នុងវ័យជំទង់នៅតែមានកម្រិតខ្ពស់។ អត្តចរិតនៃការអនុវត្តមិនល្អមួយចំនួនទាមទារឲ្យមានការកែប្រែដែលត្រូវបានបង្កើតឡើងដោយវប្បធម៌និងទំនៀមទម្លាប់ប្រពៃណី។ រាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងបោះជំហានទៅមុខលើរបៀបវារៈនេះ តាមរយៈ *កម្មវិធី១០ចំណុចស្តីពីសុខភាព*។

### ២.៣.៦- គោលដៅទី៦: ការប្រយុទ្ធប្រឆាំងមេរោគអេដស៍ ជំងឺអេដស៍ ជំងឺគ្រុនចាញ់ និងជំងឺផ្សេងៗទៀត

ការអនុវត្តចំណុចដៅ៣ នៅក្នុងគោលដៅទី៦ នេះទទួលបានលទ្ធផលចម្រុះ(តារាង ២.៧)។ កម្ពុជាសម្រេចបានជោគជ័យនូវចំណុចដៅពាក់ព័ន្ធនឹងប្រេវ៉ាឡង់មេរោគអេដស៍/ជំងឺអេដស៍ ចំណុចដៅពាក់ព័ន្ធនឹងគ្រុនចាញ់ និង ចំណុចដៅពាក់ព័ន្ធនឹងជំងឺរបេង។

គោលនយោបាយពិតជាមានសារៈសំខាន់ ក្នុងការកាត់បន្ថយអត្រាមរណៈដោយជំងឺគ្រុនចាញ់និងកាត់បន្ថយជំងឺរបេង (អត្រាប្រេវ៉ាឡង់ត្រូវបានកាត់បន្ថយនៅពេលដែលធ្វើការពង្រីកការអនុវត្តយុទ្ធសាស្ត្រដូតស៍ (DOTS) ដល់ថ្នាក់មណ្ឌលសុខភាពទាំងអស់នៅទូទាំងប្រទេសចាប់ពីចុងឆ្នាំ២០០៤មក)។

ដូចគ្នានឹងចំណុចដៅផ្សេងទៀតដែរ កម្រិតខុសគ្នាយ៉ាងច្រើននៅតែបន្តកើតមាននៅក្នុងតំបន់ចំពោះជំងឺទាំងនេះ។ បញ្ហានេះ គឺមួយផ្នែកពាក់ព័ន្ធនឹងតំបន់ភូមិសាស្ត្រ(ដូចជាខេត្តដែលមានដង់ស៊ីតេមូសមានកម្រិតខ្ពស់) មួយផ្នែកពាក់ព័ន្ធនឹងស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច (គ្រួសារក្រីក្រមានបញ្ហាប្រឈមតម្រូវការច្រើន ហើយមានលទ្ធភាពតិចតួចក្នុងការទទួលបានការព្យាបាលដោយខ្លួនឯង។ បញ្ហាធនធាននិងការបែងចែកធនធាននេះដល់សកម្មភាពការងារ ហើយសេវានៃប្រព័ន្ធសុខភាពនៅមូលដ្ឋាន នៅតែមានកម្រិតទាំងគុណភាពទាំងថវិកាគាំទ្រ។

## តារាង ២.៧ : ការអនុវត្តគោលដៅទី៦ នៃ គ.អ.ស.ក.

| ចំណុចដៅ/ សូចនាករ | ឯកតា | សមិទ្ធផល | | | | |
|---|---|---|---|---|---|---|
| | | ២០០០ | ២០០៥ | ២០១០ | ២០១៥ ជាក់ស្តែង | ២០១៥ ចំណុចដៅ |
| (៦a) កាត់បន្ថយអត្រាប្រេវ៉ាឡង់មេរោគអេដស៍ក្នុងចំណោមប្រជាជនទូទៅ | | | | | | |
| អត្រាផ្ទុកនៃមេរោគអេដស៍ | % | ១,៦ | ១,១ | ០,៨ | ០,៦ | <០,៦ |
| (៦c) កាត់បន្ថយអត្រាស្លាប់ដោយជំងឺគ្រុនចាញ់ | | | | | | |
| ប្រេវ៉ាឡង់នៃជំងឺរបេងគ្រប់ទម្រង់ | /ប្រជាជន ១០០០០០នាក់ | ១ ៦២០ | ១ ២៣០ | ៨៧៥ | ៦៦៨ (២០១៤) | ៨៣៥ |
| អត្រាស្លាប់ដោយជំងឺរបេង | /ប្រជាជន ១០០ ០០០ នាក់ | ១២៨ | ៩៣ | ៦៨ | ៥៨ (២០១៤) | - |
| (៦c) កាត់បន្ថយអត្រាស្លាប់ដោយជំងឺគ្រុនចាញ់ | | | | | | |
| អត្រាស្លាប់ដោយជំងឺគ្រុនចាញ់ | /ប្រជាជន ១០០០០០នាក់ | ៥,៣ | ១,៤ | ០,៩៨ | ០,០៧ (២០១៤) | ០,៧៨ |

*ប្រភព : ក្រសួងផែនការ*

### ២.៣.៧- គោលដៅទី៧ : ធានាចីរភាពបរិស្ថាន

គោលដៅទី៧ស្តីពីចីរភាពបរិស្ថាន បង្ហាញពីបញ្ហាប្រឈមចម្បងៗរបស់កម្ពុជា និងមានចំណុចដៅសំខាន់ចំនួន៤ និងសូចនាករមួយចំនួនធំ (តារាង ២.៨)។ ក្នុងគោលដៅនេះ ជាទូទៅមានការពិបាកក្នុងការផ្តល់អនុសាសន៍ពីការអនុវត្ត ដោយតម្លៃចំណុចដៅសម្រាប់ឆ្នាំចុងក្រោយរបស់ចំណុចដៅទី១មិនត្រូវបានកំណត់ទេ (ការបញ្ចូលការអភិវឌ្ឍប្រកបដោយចីរភាពទៅក្នុងគោលនយោបាយជាតិ និងស្តារឡើងវិញធនធានបរិស្ថានដែលបានបាត់បង់)។ បន្ថែមលើនេះទៀត ជាមួយគ្នានឹងចំណុចដៅទី២ (បង្កើនសមាមាត្រប្រជាជនមានលទ្ធភាពប្រើប្រាស់ទឹកស្អាត) និងទី៤ (បង្កើនសមាមាត្រប្រជាជនទទួលបានសុវត្ថិភាពដីធ្លី) មានវឌ្ឍនភាពយ៉ាងខ្លាំង ចំណុចដៅទី៣ ស្តីពីកាត់បន្ថយការប្រើប្រាស់អុសសម្រាប់ចម្អិនអាហារ មិនបានសម្រេចតាមការកំណត់ឡើយ។ ទោះបីជាស្ថិតនៅក្រោមគោលដៅតែមួយក៏ដោយ ចំណុចដៅទាំងនេះ មានបរិបទនិងទិសដៅខុសៗគ្នាយ៉ាងច្រើន។

ការរកឃើញដ៏សំខាន់មួយពីចំណុចដៅនៃសូចនាករ បង្ហាញថា ការការពារបរិស្ថានធម្មជាតិនៅកម្ពុជាក្នុងដំណាក់កាល គ.អ.ស.ក. នៅមានកម្រិតនៅឡើយ។ ផ្ទៃដីគ្របដណ្តប់ដោយព្រៃឈើបានថយចុះនៅក្នុងកំលុងពេលនេះ ជាមួយគ្នានឹងផលប៉ះពាល់ជាអវិជ្ជមានទៅលើប្រព័ន្ធអេកូឡូស៊ី។ នៅក្នុងឆ្នាំចុងក្រោយនៃដំណាក់កាល គ.អ.ស.ក. រាជរដ្ឋាភិបាលកម្ពុជាបានកំណត់ និងបានកែទម្រង់វិធីសាស្ត្ររបស់ខ្លួនសម្រាប់ដោះស្រាយបញ្ហានេះដោយបង្កើតឡើងនូវសហគមន៍ព្រៃឈើ ជំរុញនិង

លើកទឹកចិត្តឲ្យដាំដើមកៅស៊ូជំនួសឲ្យការបាត់បង់ព្រៃឈើ និងបង្កើនផ្ទៃដីនៃតំបន់ការពារ។ បញ្ហានេះត្រូវបានបញ្ជាក់ថា សកម្មភាពនេះត្រូវការពេលវេលាយូរ ដើម្បីទទួលបានលទ្ធផលដែលចង់បាន។ ពាក់ព័ន្ធនឹងជលផល លទ្ធផលដែលទទួលបានមានលក្ខណៈវិជ្ជមានច្រើន ដោយចំនួនសហគមន៍នេសាទមានការកើនឡើង ការលុបបំបាត់ឡូត៍នេសាទ និងការពង្រីកតំបន់អភិរក្ស។

ការទទួលបានទឹកស្អាតបរិភោគនិងអនាម័យ ដែលជាចំណុចដៅសំខាន់មួយផ្សេងទៀតរបស់គោលដៅទី៧ នៃ គ.អ.ស.ក. មានវឌ្ឍនភាពគួរឲ្យកត់សម្គាល់ ទាំងនៅក្នុងតំបន់ជនបទនិងតំបន់ទីប្រជុំជន គឺសម្រេចបានជោគជ័យ និងមុនពេលវេលាកំណត់។ លទ្ធផលនេះ ផ្តល់នូវមូលដ្ឋានគ្រឹះមួយសម្រាប់បោះជំហានទៅមុខ ទោះបីជាកម្រិតនៃការសម្រេចបានអនាម័យនៅទាបជាងស្តង់ដាអន្តរជាតិ។ លទ្ធផលនៃការសម្រេចបានលើចំណុចដៅពាក់ព័ន្ធនឹងការកាន់កាប់ដីធ្លីប្រកបដោយសុវត្ថិភាពមានកម្រិតខ្ពស់ ដែលការចុះឈ្មោះលើកម្មសិទ្ធិដីធ្លីបានកើនឡើងពី១០% នៅឆ្នាំ២០០០ ដល់ ៥៨%នៅឆ្នាំ២០១៥។

ចុងក្រោយ ចំណុចដៅពាក់ព័ន្ធនឹងការពឹងផ្អែកលើអុសក្នុងការចម្អិនអាហារ មិនបានសម្រេចតាមការកំណត់ទេ។ បញ្ហានេះ រាជរដ្ឋាភិបាលកម្ពុជាចាំបាច់ត្រូវជំរុញកិច្ចខិតខំប្រឹងប្រែងបន្តដើម្បីបង្កើតប្រភពជំនួសនិងជំរុញប្រជាជនឲ្យប្រើប្រាស់ចង្ក្រានចម្អិនអាហារដោយឥន្ទនៈ។

**តារាង ២.៨ : ការអនុវត្តគោលដៅទី៧ នៃ គ.អ.ស.ក.**

| ល.រ | សូចនាករ | ឯកតា | ២០០០ | ២០០៥ | ២០១០ | ២០១៥ ជាក់ស្តែង |
|---|---|---|---|---|---|---|
| (៧a) បញ្ចូលគោលការណ៍អភិវឌ្ឍន៍ប្រកបដោយចីរភាព និងការថយចុះនៃធនធានធម្មជាតិ | | | | | | |
| ១ | គម្របព្រៃឈើ | % | ៦៣,៧ | ៥៩,១ | ៥៧,១ | ៤៩,៩ (២០១៤) |
| | | ពាន់ហ.ត. | ១១ ៥៤០ | ១០ ៧៣០ | ១០ ៣៦៣ | ៩ ០៥៦ (២០១៤) |
| ២ | សហគមន៍ព្រៃឈើ | ចំនួន | ២៦៤ | ៤០២ | ៤៤១ | ៤៩៧ |
| | | ហ.ត. | ១៧៩ ០២១ | ៣៨០ ៥៨៩ | ៣៩១ ៨៣១ | ៥១៤ ៨៣៤ |
| ៣ | សហគមន៍ព្រៃឈើបានចុះបញ្ជីផ្លូវការ | ចំនួន | - | - | ២៣៣ | ៤០១ |
| | | ហិកតា | - | - | ២៣០ ៣៧០ | ៣៣៨ ៣១៧ |
| ៤ | ផ្ទៃដីកៅស៊ូកសិឧស្សាហកម្មវិនិយោគ | ពាន់ហ.ត. | ៥៧ | ៥០ | ៥៤ | ៥៥,៩ |
| ៥ | ផ្ទៃដីកៅស៊ូកសិឧស្សាហកម្មវិនិយោគ | ពាន់ហ.ត. | ៣៤.៦ (២០១០) | ៦៦.៥ (២០១១) | ១១៨,៤ (២០១២) | ១៣៥,៤(២០១៣) |
| ៦ | ផ្ទៃដីកៅស៊ូគ្រួសារ | ពាន់ហ.ត. | ៨៨,៩ (២០១០) | ៩៥,៩ (២០១១) | ១០៦,៧ (២០១២) | ១៣៧,៤(២០១៣) |
| ៧ | ផ្ទៃដីតំបន់ការពារធម្មជាតិ២៣កន្លែង | ពាន់ហ.ត. | ៣ ២៦៣ | ៣ ១១១ | ៣ ១០១ | ៣ ០៩៨ |
| ៨ | សហគមន៍តំបន់ការពារធម្មជាតិ | ចំនួន | ៤ | ៥៩ | ៩៨ | ១២៩ |

| ល.រ | សូចនាករ | ឯកតា | ២០០០ | ២០០៥ | ២០១០ | ២០១៥ ជាក់ស្តែង |
|---|---|---|---|---|---|---|
| ៩ | ចំនួនមន្ត្រីអនុរក្សនៅក្នុងតំបន់ការពារ | តំបន់ | ៣២៥ | ៧០០ | ៤៨០ | ៩៦០ |
| ១០ | ការកាត់បន្ថយចំនួនឡូតិ៍នេសាទទៅដល់សហគមន៍មូលដ្ឋាន | % | - | ៥៦,៤ | ៥៦,៧ | ៨៩,៨ |
| ១១ | ការចាប់ត្រី - ត្រីទឹកសាប ត្រីសមុទ្រ និងវារីវប្បកម្ម | ពាន់តោន | ១៣៦ (២០០២) | ៣៥៤.៩ | ៥៥០ | ៦៧៤ (២០១៤) |
| ១២ | សហគមន៍នេសាទ | ចំនួន | - | ៤៤០ | ៤៦៩ | ៥១៦ |
| (៧b) សម្រេចឲ្យបាន ការទទួលបានទឹកសុវត្ថិភាពបរិភោគ និងអនាម័យ នៅតំបន់ជនបទនិងតំបន់ទីប្រជុំជន | | | | | | |
| ១៣ | សមាមាត្រប្រជាជននៅតំបន់ជនបទ ដែលទទួលបានទឹកស្អាតប្រើប្រាស់ | % | ២៤,០ (១៩៩៨) | ៤១,៤ (២០០៨) | ៤៣,៤៩ | ៥០ (២០១៤) |
| ១៤ | សមាមាត្រប្រជាជននៅតំបន់ទីប្រជុំជន ដែលទទួលបានទឹកស្អាតប្រើប្រាស់ | % | ៦០,០ (១៩៩៨) | - | ៨០,៥ | ៨០,៧ (២០១៤) |
| ១៥ | សមាមាត្រប្រជាជននៅតំបន់ជនបទ ដែលទទួលបានសេវាអនាម័យ | % | ៨,៦ (១៩៩៨) | ១៦,៨ (២០០៥) | ២៩,២ | ៤៦,២ (២០១៤) |
| ១៦ | សមាមាត្រប្រជាជននៅតំបន់ទីប្រជុំជនដែលទទួលបានសេវាអនាម័យ | % | ៤៩,០ (១៩៩៨) | - | ៨៦,៦ | ៨៩,០ (២០១៤) |
| (៧c) កាត់បន្ថយ ការពឹងផ្អែករបស់គ្រួសារកម្ពុជា លើអុសសម្រាប់ប្រើជាថាមពល ឲ្យនៅត្រឹម៥២% | | | | | | |
| ១៧ | កាត់បន្ថយ ការពឹងផ្អែករបស់គ្រួសារកម្ពុជា លើអុសសម្រាប់ចម្អិនអាហារ | % | ៩២,០ (១៩៩៣) | ៨៤,០ | ៧៩,៥ | ៧៤,៨ (២០១៤) |
| (៧d) បង្កើនសមាមាត្រប្រជាជនកាន់កាប់ដីធ្លីប្រកបដោយសុវត្ថិភាព | | | | | | |
| ១៨ | បង្កើនសមាមាត្រប្រជាជនកាន់កាប់ដីធ្លីប្រកបដោយសុវត្ថិភាព | % | ១០,០ | ១៥,០ | ៣២,០ | ៥៨,០ |

***ប្រភព :*** *ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*

## ២.៣.៨- គោលដៅទី៨ : បង្កើតភាពជាដៃគូជាសកលសម្រាប់កិច្ចអភិវឌ្ឍ

គោលដៅទី៨ នៃ គ.អ.ស.ក. ការបង្កើតភាពជាដៃគូជាសកលសម្រាប់កិច្ចអភិវឌ្ឍន៍ ត្រូវបានផ្តោតការយកចិត្តទុកដាក់លើបណ្តាប្រទេសអភិវឌ្ឍក្នុងពិភពលោក និងភ្ជាប់ទៅនឹងកិច្ចព្រមព្រៀងម៉ុងតេរ៉ីដែលបណ្តាប្រទេសទាំងនោះប្តេជ្ញាអនុវត្តជាថ្មី ក្នុងការរួមចំណែកផ្តល់ជំនួយអភិវឌ្ឍផ្លូវការឲ្យដល់កម្រិតបទដ្ឋានប្រមាណ០,៧% នៃផលិតផលក្នុងស្រុកសរុបរបស់ខ្លួន។ គោលដៅនេះត្រូវបានកំណត់៦ចំណុចដៅ និងចែកចេញជា៣ក្រុមគឺ ការធ្វើឲ្យប្រសើរឡើងច្បាប់អន្តរជាតិ ការបែងចែកធនធានជំនួយអភិវឌ្ឍផ្លូវការសំខាន់ៗនិងបច្ចេកវិទ្យាផងដែរ និង កសាងនូវភាពជាដៃគូថ្មីក្នុងចំណោមស្ថាប័នអន្តរជាតិ។

កម្ពុជាមិនមានសូចនាករជាផ្លូវការសម្រាប់ គ.អ.ស.ក. ប៉ុន្តែ បានអនុវត្តទៅតាមលំហូរនៃធនធានជំនួយអភិវឌ្ឍន៍ផ្លូវការ និងបានស្វែងរកការពង្រឹងភាពជាដៃគូរបស់ខ្លួនជាមួយតួអង្គអន្តរជាតិនានា។

រាជរដ្ឋាភិបាលកម្ពុជា បានទទួលជោគជ័យក្នុងការបន្តកៀរគរធនធាននិងប្រើប្រាស់ធនធានទាំងនេះសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច។ ជំនួយអភិវឌ្ឍផ្លូវការសរុបបានកើនឡើងដល់១,៤៣ ពាន់លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៤ ទោះបីជាបន្ទាប់ពីនោះមក បានធ្លាក់ចុះជាបណ្តើរៗក៏ដោយ។ បន្ថែមលើនេះទៀត សមាមាត្រនៃកម្ចីសម្បទានសម្រាប់គោលដៅនៃការអភិវឌ្ឍ ជារៀងរាល់ពេលបានប្តូរគោលដៅទៅរកការវិនិយោគក្នុងផ្នែកហេដ្ឋារចនាសម្ព័ន្ធច្រើនជាងវិស័យសង្គមកិច្ច។ ពេលអនាគតដ៏ខ្លីនេះ ការផ្តល់ហិរញ្ញប្បទានរបស់រាជរដ្ឋាភិបាលកម្ពុជា នឹងត្រូវផ្លាស់ប្តូរបន្ថែមទៀតដើម្បីជានាការកើនឡើងនៃចំណូលពន្ធក្នុងស្រុក និងជំរុញការវិនិយោគរបស់ផ្នែកឯកជន។ ទោះជាដូចនេះក្តី ដើម្បីសម្រេចបានតាមគោលដៅនេះ ទាមទារឲ្យមានការពង្រឹងសមត្ថភាពនិងប្រើប្រាស់វិធីសាស្ត្រថ្មីៗ។

រាជរដ្ឋាភិបាលកម្ពុជាបានពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍនានា តាមរយៈការរៀបចំយុទ្ធសាស្ត្រនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍនិងភាពជាដៃគូអភិវឌ្ឍ ឆ្នាំ២០១៤-២០១៨ ដែលបានកំណត់តួនាទីនិងការទទួលខុសត្រូវច្បាស់លាស់ និងការរៀបចំឲ្យមានការពិគ្រោះយោបល់ជាមួយដៃគូអភិវឌ្ឍ។

ការប្រែក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប និងការធ្វើសមាហរណកម្មទៅក្នុងតំបន់កាន់តែស៊ីជម្រៅជាងមុនតាមរយៈការបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ាន ក៏បានបង្ហាញពីកាលានុវត្តភាពថ្មីសម្រាប់ការកសាងភាពជាដៃគូ និងការរៀនសូត្រពីបទពិសោធពីមិត្តភក្តិជាសមាជិកកាន់តែច្រើន និងពីកិច្ចសហប្រតិបត្តិការត្បូងត្បូងផងដែរ។ ការទាក់ទាញផ្នែកឯកជន ក៏ជាផ្នែកមួយនៃកិច្ចសហប្រតិបត្តិការក្នុងតំបន់ផងដែរ។ ទស្សនៈនៃការធ្វើហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍដែលសំដៅលើការរៀបចំផែនការលំហូរធនធានទាំងអស់ ទាំងផ្នែកសាធារណៈនិងឯកជន ក្នុងនិងក្រៅប្រទេស ត្រូវបានយកចិត្តទុកដាក់យ៉ាងខ្លាំងពីរាជរដ្ឋាភិបាលកម្ពុជា ហើយការអនុវត្តការងារនេះនឹងមានសារៈសំខាន់ក្នុងការផ្តល់ជាធាតុចូលដល់ គ.អ.ច.ក.។

## ២.៣.៩-គោលដៅទី៩ : ការបោសសម្អាតមីន សំណល់ជាតិផ្ទុះពីសង្គ្រាម និងការសង្គ្រោះជនពិការដោយសារមីន

ការបន្ថែមគោលដៅទី៩ គឺជាឧទាហរណ៍យ៉ាងច្បាស់ពីការទទួលយកយ៉ាងពេញលេញនូវគោលដៅសកលនានាមកដាក់ក្នុងបរិការណ៍កម្ពុជា។ ចំណុចនេះ គឺបង្ហាញពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការបោសសម្អាតមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម ចេញពីសហគមន៍មូលដ្ឋាន។ នៅក្នុងគោលដៅនេះ ត្រូវបានកំណត់នូវចំណុចដៅចំនួន២គឺ៖ កាត់បន្ថយជនរងគ្រោះដែលបង្កឡើង

ដោយសារគ្រាប់មីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម និងផ្ទៃដីដែលបានបោសសម្អាតគ្រាប់មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម។

ចំណុចដៅទាំង២នេះត្រូវបានកំណត់ដោយអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពមីននិងសង្គ្រោះជនពិការដោយសារមីន និងមានគោលដៅចម្បង ដើម្បីសម្រេចឲ្យបានការលុបបំបាត់កុំឲ្យមានជាបន្តនូវមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាមក្រោមដីនិងលើដីកម្ពុជា និងកុំឲ្យមានជនរងគ្រោះ (ស្លាប់និងរងរបួស) ដោយសារមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម។ តារាង ២.៩ បង្ហាញយ៉ាងច្បាស់ពីវឌ្ឍនភាពដែលសម្រេចបានពេញលេញសម្រាប់ចំណុចដៅទាំង២ នៅឆ្នាំ២០១៥។ ជាការសំខាន់ផងដែរដែលត្រូវបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជាក៏បានជួយឧបត្ថម្ភនិងស្តារនីតិសម្បទាដល់ប្រជាជនដែលរងគ្រោះដោយសារមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍ បានកសាងមជ្ឈមណ្ឌលស្តារនីតិសម្បទាចំនួន១៥ និងបានផ្តល់ការស្តារនីតិសម្បទាដល់ជនរងគ្រោះប្រមាណ១០០នាក់ ជារៀងរាល់ឆ្នាំ។

**តារាង ២.៩ : ការអនុវត្តគោលដៅទី៩ នៃ គ.អ.ស.ក.**

| ល.រ | សូចនាករ | ឯកតា | ២០០០ | ២០០៥ | ២០១០ | ២០១៥ ជាក់ស្តែង |
|---|---|---|---|---|---|---|
| 1 | ចំនួននៃជនរងគ្រោះដែលបង្កឡើងដោយគ្រាប់មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម (ស្លាប់និងរបួស) | | | | | |
| | ចំណុចដៅ | នាក់ | ៥៧៥ | ៣៥៧ | ២២០ | ១៣០ |
| | លទ្ធផល | នាក់ | ៨៥៨ | ៨៧៥ | ២៨៦ | ៧៩ |
| 2 | ផ្ទៃដីដែលបានបោសសម្អាតគ្រាប់មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម | | | | | |
| | ចំណុចដៅ | ហ.ត. | ១ ៥៦២ | ៤ ៤៦៦ | ៥ ៣៧៤ | ៥ ៩០៩ |
| | លទ្ធផល | ហ.ត. | ៣ ២០៨ | ៤ ០៦៥ | ១១ ៩៥០ | ១៦ ១០៤ |

*ប្រភព : អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីននិងសង្គ្រោះជនពិការដោយសារមីន*

នៅដំណាក់កាលដំបូងនៃក្របខ័ណ្ឌ គ.អ.ស.ក. រាជរដ្ឋាភិបាលមានការពិបាកក្នុងការកំណត់ផ្ទៃដីដែលមានបង្កប់ដោយគ្រាប់មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម ដើម្បីកំណត់ធនធានសម្រាប់គាំទ្រដល់សកម្មភាពពាក់ព័ន្ធនឹងការបោសសម្អាតគ្រាប់មីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម។ នៅពេលដែលកម្មវិធីមានការរីកចម្រើន ការព្យាករនិងចំណុចដៅរបស់អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីននិងសង្គ្រោះជនពិការដោយសារមីន កាន់តែមានភាពត្រឹមត្រូវ ប៉ុន្តែជៀសមិនផុតពីការជំរុញការបោសសម្អាតមីនឲ្យអស់ពីផ្ទៃដីឡើយ។ បញ្ហាប្រឈមក៏បានបង្ហាញផងដែរ ពីទឹកជំនន់ ដែលបានជន់លិចផ្ទៃដីដែលបានបោសសម្អាតគ្រាប់មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមកន្លងទៅនិងបានប្រគល់ឲ្យប្រជាជនរស់នៅ។ តំបន់ទាំងនេះជាញឹកញាប់ត្រូវបានរាលដាលឡើងវិញដោយសារគ្រាប់មីននិងសំណល់ជាតិផ្ទុះពីសង្គ្រាមដែលនាំមកដោយទឹកជំនន់។ ការងារដែលត្រូវអនុវត្តនៅថ្ងៃអនាគត ការងារ

សំខាន់គឺត្រូវរៀបចំផែនការដែលមានភាពត្រឹមត្រូវនិងជាក់លាក់និងបានបញ្ជាក់ច្បាស់ថា ការងារដែលនៅសេសសល់នៅមានច្រើន។

ប្រភពធនធានពីបរទេស សម្រាប់ការបោសសម្អាតគ្រាប់មីននិងសំណល់ជាតិផ្ទុះពីសង្គ្រាមមានការថយចុះ បណ្តាលឲ្យមានសម្ពាធបន្ថែមទៀតលើការងាររបស់អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពមីននិងសង្គ្រោះជនពិការដោយសារមីន។ រាជរដ្ឋាភិបាលកម្ពុជានឹងស្វែងរកប្រភពធនធានដើម្បីគាំទ្រដល់ការងារដោះមីនជាអាទិភាពនៅពេលអនាគត។

## ២.៤- បញ្ហាចម្បងៗ : ការឆ្លើយតបនិងបទពិសោធដែលទទួលបាន

នៅក្នុងផ្នែកចុងក្រោយនេះ នឹងបង្ហាញពីបទពិសោធ និង បញ្ហាប្រឈមនានា ដែលកម្ពុជាទទួលបានក្នុងកំលុងនៃការអនុវត្ត គ.អ.ស.ក. ដែលផ្តោតលើ៣ចំណុចសំខាន់ៗ គឺៈ (១) ការកំណត់គោលដៅនៃ គ.អ.ស.ក. ដែលមិនទាន់សម្រេចបាន ដែលនឹងត្រូវផ្តល់អាទិភាពក្នុងការងារអនុវត្ត គ.អ.ច.ក.។ (២) ការរៀបចំផែនការ ការប្រមូលទិន្នន័យ និងបញ្ហានៃការតាមដានត្រួតពិនិត្យនិងវាយតម្លៃ។ និង (៣) ការពិនិត្យមើលឡើងវិញនិងចែករំលែកបទពិសោធ។

### គ.អ.ស.ក. ដែលមិនទាន់សម្រេចបានៈ

ស្របគ្នាជាមួយនឹងការពិភាក្សាខាងលើ ចំណុចដៅមួយចំនួនត្រូវបានកំណត់ថាមិនទាន់សម្រេចបាននឹងត្រូវបានផ្តល់អាទិភាពខ្ពស់អនុវត្តបន្តក្នុងក្របខ័ណ្ឌ គ.អ.ច.ក.។ ចំណុចដៅទាំងនោះដូចមាននៅក្នុងបញ្ជីខាងក្រោម ជាមួយគ្នានឹងការវាយតម្លៃអាទិភាពនៃទំនាក់ទំនងរបស់ចំណុចដៅទាំងនោះ ជាមួយនឹងសកម្មភាពគោលនយោបាយ។

- ក្នុងគោលដៅទី១ :
  - *ចំណុចដៅ (១.c)* បង្កើនចំណែកនៃចំណូលទទួលបានដោយប្រជាជនក្រីក្របំផុត ២០%នៃចំនួនប្រជាជនសរុប។ ចំណុចដៅនេះទាមទារឲ្យមានការធានាចំណូលរបស់ប្រជាជនក្រីក្រមានសមាមាត្រខ្ពស់ជាងក្រុមបញ្ចភាគផ្សេងទៀត។ ចំណុចដៅនេះ គឺមានភាពលម្អៀងតិចតួច ធៀបនឹងគន្លងផ្លូវឆ្ពោះទៅរកការសម្រេចបានគោលដៅដែលបានកំណត់ និងម៉ាទ្រីសផ្សេងទៀតដែលបង្ហាញពីការធ្វើឲ្យប្រសើរឡើងវិសមភាពដូចនេះ វាជាអាទិភាពមធ្យមឬទាប។ ការងារនេះសម្រេចបានតាមរយៈការបង្កើនកាលានុវត្តភាពសេដ្ឋកិច្ចដល់ក្រុមនិងតំបន់ដែលមានជីវភាពទាបជាងគេ និងការដាក់ចេញនូវវិធានការជំនួយសង្គមដល់ប្រជាជនក្រីក្រ។
  - *ចំណុចដៅ (១d)* ធ្វើឲ្យប្រសើរឡើងស្ថានភាពអាហារូបត្ថម្ភ និងកាត់បន្ថយភាពក្រិនរបស់កុមារ នៅមានគម្លាតពីគោលដៅដែលបានកំណត់។ កិច្ចខិតខំប្រឹងប្រែងធ្វើឲ្យ

សម្រេចបានចំណុចដៅនេះ គឺជាអាទិភាពខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជា។ នេះគឺជាតម្រូវការនៃគោលនយោបាយ និងទាមទារនូវកិច្ចអន្តរាគមន៍មួយចំនួន រួមទាំង ជំនួយសង្គម ជាពិសេស ផ្តល់អាហារបំប៉នដល់កុមារ ផ្តល់អាហារដល់សិស្សនៅសាលារៀន វិធានការសុខភាពសាធារណៈ និងទំនាក់ទំនងសម្រាប់ការអភិវឌ្ឍ។

- ក្នុងគោលដៅទី២ :
    - *ចំណុចដៅ (២b)* សម្រេចឲ្យបាន ១00% អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សានិងមធ្យមសិក្សា ដែលជាគូនឹងអត្រានៃការសិក្សា និងមានទិសដៅនៃការផ្លាស់ប្តូរដូចគ្នាក្នុងពេលវេលាដូចគ្នា។ លទ្ធផលនៃការសម្រេចបាន មានកម្រិតលម្អៀងពីគន្លងឆ្ពោះទៅការសម្រេចបានតាមការកំណត់ ហើយគម្លាតនេះបានបន្តរួមកាន់តែតូចវិញ ដែលការសម្រេចបានចំណុចដៅនេះគឺជាអាទិភាពកម្រិតមធ្យម។ កិច្ចខិតខំប្រឹងប្រែងលើគោលនយោបាយ ដើម្បីធ្វើឲ្យប្រសើរឡើងគុណភាពនៃការសិក្សា រួមជាមួយនឹងការតាមដានត្រួតពិនិត្យផ្នែករដ្ឋបាលលើការសិក្សារបស់សិស្សបានប្រសើរជាងមុន អាចនឹងរួមចំណែកដ៏ល្អក្នុងការធ្វើឲ្យសម្រេចបានចំណុចដៅខាងលើ។

- ក្នុងគោលដៅទី៣ :
    - *ចំណុចដៅ (៣b) ស្តីពីសិទ្ធិអំណាចសេដ្ឋកិច្ចរបស់ស្ត្រី ជាពិសេស តួនាទីរបស់ស្ត្រីក្នុងទីផ្សារពលកម្ម* គឺជាសូចនាករគាំទ្រដែលបានប្រែប្រួលទៅតាមពេលវេលាកំណត់ សម្រេចបានជោគជ័យតាមកាលកំណត់ ក្រោយមកបានធ្លាក់ចុះវិញ។ ការងារជាអាទិភាព គឺការពិនិត្យមើលឡើងវិញនូវទិន្នន័យចាំបាច់នានាមុនពេលធ្វើការកំណត់អាទិភាព។
    - *ចំណុចដៅ (៣c) ធ្វើឲ្យប្រសើរឡើងតួនាទីរបស់ស្ត្រីនៅក្នុងវិស័យសាធារណៈនិងការធ្វើសេចក្តីសម្រេចចិត្ត។* ក្នុងចំណោមសូចនាករចំនួន៥ នៃចំណុចដៅនេះមានសូចនាករចំនួន២ សម្រេចបានតាមការកំណត់ និង សូចនាករចំនួន៣ផ្សេងទៀតមិនបានសម្រេច។ ទោះជាដូចនេះ មិនមានតុល្យភាពទេនៅក្នុងតួនាទីកម្រិតខ្ពស់ ដូចជា រដ្ឋមន្ត្រី និងអភិបាលរាជធានី ខេត្ត ហើយនេះគឺជាអាទិភាពខ្ពស់សម្រាប់ធ្វើឲ្យសម្រេចបានតុល្យភាព។

- ក្នុងគោលដៅទី៦ :
    - *ចំណុចដៅ(៦c) កាត់បន្ថយបន្ថែមទៀតប្រេវ៉ាឡង់មេរោគអេដស៍/ជំងឺអេដស៍:* ទោះបីជាមានវឌ្ឍនភាពគួរឲ្យកត់សម្គាល់ *ប្រេវ៉ាឡង់មេរោគអេដស៍/ជំងឺអេដស៍* នៅមានកម្រិត

ខ្ពស់នៅក្នុងតំបន់ខ្ពង់រាប។ ទិន្នន័យរបស់ទីភ្នាក់ងារប្រយុទ្ធប្រឆាំងជំងឺអេដស៍អង្គការសហប្រជាជាតិបានបង្ហាញថាមានការបន្តធ្លាក់ចុះជាបន្តបន្ទាប់រហូតដល់០,៤% នៅឆ្នាំ ២០១៦ ជាការបញ្ជាក់ឲ្យឃើញថា សម្រេចបានតាមចំណុចដៅ។

- ក្នុងគោលដៅទី៧ :
  - *ចំណុចដៅ (៧c) កាត់បន្ថយការពឹងផ្អែកលើអុសសម្រាប់ចម្អិនអាហារ* មានវឌ្ឍនភាពយឺតយ៉ាវ ហើយទាមទារឲ្យមានសកម្មភាពសម្រាប់ជំរុញឲ្យមានភាពជោគជ័យចំណុចដៅនេះ។ ការផ្តល់ប្រភពថាមពល ប្រកបដោយចីរភាពសម្រាប់ជំនួសការប្រើប្រាស់អុស គឺជាគន្លឹះនៃភាពជោគជ័យ ប៉ុន្តែ ត្រូវរួមបញ្ចូលគ្នាជាមួយនឹងវិធានការនានាដើម្បីកែប្រែទំនៀមទម្លាប់ ការអនុវត្ត និងការយល់ដឹងពីទំនៀមទម្លាប់របស់ប្រជាជន។

បន្ថែមលើនេះទៀត ព័ត៌មានមិនគ្រប់គ្រាន់សម្រាប់ *ចំណុចដៅ (៣d) កាត់បន្ថយអំពើហិង្សាប្រឆាំងស្ត្រី* ដែលទិន្នន័យសម្រាប់គាំទ្រហាក់ដូចជាមិនត្រូវបានប្រមូល និង *ចំណុចដៅ (៧a) ការរួមបញ្ចូលគោលការណ៍នៃការអភិវឌ្ឍប្រកបដោយចីរភាពនិងការខាតបង់នៃធនធានធម្មជាតិ* ដែលមិនបានកំណត់ពីចំណុចដៅចុងក្រោយឡើយ។ ចំណុចដៅទាំង២នេះ គឺជាតម្រូវការចាំបាច់សម្រាប់ការតាមដានត្រួតពិនិត្យ។

ពិនិត្យជារួម គោលដៅជាច្រើននៃ គ.អ.ស.ក. ដែលអនុវត្តនៅថ្នាក់ជាតិបានសម្រេចតាមចំណុចដៅចុងក្រោយ ប៉ុន្តែ នៅថ្នាក់ក្រោមជាតិ មានភាពខុសគ្នាច្រើនពីតំបន់មួយទៅតំបន់មួយ។ លើសពីនេះទៀត ភាពខុសគ្នានេះមានទម្រង់រួមមួយ គឺលទ្ធផលល្អនៅក្នុងតំបន់សំខាន់ៗ តែពុំមានលទ្ធផលល្អនៅតំបន់ដែលមានសកម្មភាពសេដ្ឋកិច្ចតិច។ គម្លាតរវាងតំបន់ភូមិសាស្ត្រនេះ គឺជាសមាសភាពបន្ថែមមួយនៃការងារដែលត្រូវអនុវត្តបន្ត ហើយនឹងត្រូវបានសន្មតថាមានសារៈសំខាន់សម្រាប់ គ.អ.ច.ក. ដែលកំណត់ថា មិនបោះបង់នរណាម្នាក់នៅឯកោឡើយ។ និន្នាការទាំងនេះ គឺជាភស្តុតាងជាក់ស្តែងលើគោលដៅស្តីពីភាពក្រីក្រ និងគោលដៅជាច្រើនស្តីពីសេវាសាធារណៈ នៃ គ.អ.ស.ក.។

## ២.៥- ការរៀបចំផែនការនិងបញ្ហាក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ការរៀបចំផែនការនិងតាមដាន ត្រួតពិនិត្យអំពីលទ្ធផល បានផ្តល់នូវបទពិសោធចំនួន២ នៃការអនុវត្ត គ.អ.ស.ក. រួមទាំងការប៉ាន់ស្មានពីចំណុចដៅ ការតាមដានត្រួតពិនិត្យតាមពេលវេលាកំណត់ និងការប្រមូលទិន្នន័យ។

ការកំណត់ចំណុចដៅអាចត្រូវបានកំណត់តាមលក្ខណវិនិច្ឆ័យ SMART ឬទេ។ ឧទាហរណ៍ តើចំណុចដៅនោះ ជាក់លាក់ អាចវាស់វែង អាចសម្រេចបាន ជឿទុកចិត្ត និងសម្រេចបានតាមពេលវេលាកំណត់។ សម្រាប់រយៈពេលវែងនៃការរៀបចំ និង មិនមានប្រភពទិន្នន័យ គឺជាបញ្ហាប្រឈមចម្បង ហើយតាមបទពិសោធទទួលបានក្នុងកំលុងពេលអនុវត្ត គ.អ.ស.ក. បង្ហាញថា ខណៈពេល

ដែលកិច្ចខិតខំប្រឹងប្រែងត្រូវបានធ្វើឡើង ដើម្បីកំណត់ចំណុចដៅជាតិឲ្យត្រូវតាមលក្ខណវិនិច្ឆ័យ SMART ចំណុចដៅមួយចំនួនត្រូវបានកែសម្រួល និងកំណត់ឡើងវិញ នៅក្នុងដំណាក់កាលនៃការអនុវត្ត។ ការកែសម្រួលនេះ រួមមានបញ្ចូលទាំងការផ្លាស់ប្តូរ(ការបន្ធូរបន្ថយ) តម្លៃនៃចំណុចដៅ និងការជ្រើសរើសសូចនាករបន្ថែម ដើម្បីប្រើប្រាស់ជាមធ្យោបាយជំនួសសម្រាប់វាស់វែងនៅពេលដែលពុំមានប្រភពទិន្នន័យគាំទ្រដល់សូចនាករណាមួយ។ ទោះបីជាការងារនេះគឺជាផ្នែកមួយនៃដំណើរការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ការផ្លាស់ប្តូរទាំងនេះចាំបាច់ត្រូវបានធ្វើឡើងតាមរយៈដំណើរការបើកទូលាយការពិនិត្យមើលឡើងវិញដោយភាគីពីខាងក្រៅ និងត្រូវបានគាំទ្រដោយភស្តុតាង។

បន្ថែមលើនេះ ដោយសារតែបញ្ហាប្រឈមជាភស្តុតាង ការតាមដានពីរយៈពេល (ចំណុចដៅតាមឆ្នាំ) គឺជាវិធីសាស្ត្រដំបូងនិងជាទូទៅវិធីសាស្ត្រលីនេអ៊ែ ត្រូវបានប្រើប្រាស់។ ទោះជាដូចនេះក្តី បទពិសោធពីការសម្រេចបាន គ.អ.ស.ក. បានបង្ហាញថា សូចនាករភាគច្រើនទទួលបានលទ្ធផលមិនតាមគន្លងលីនេអ៊ែ ហើយទ្រឹស្តីនៃការផ្លាស់ប្តូរបង្ហាញថា លទ្ធផលនេះត្រូវគ្នានឹងទម្រង់ស្តង់ដា៖ (១) ជំហាននៃការផ្លាស់ប្តូរ ជា កន្លែងដែលទទួលឥទ្ធិពលពីការអនុវត្តអាស្រ័យទៅតាមធនធានដែលបានផ្តល់ឲ្យ (២) អិចស្ប៉ូណង់ស្យែល ដែលមានការប្រែប្រួលយឺតប៉ុន្តែជំរុញផ្នែកគោលនយោបាយឬសន្ទុះនៃការផ្តល់ជាតុចូល ឬ (៣) ឡូហ្គារីត ការផ្លាស់ប្តូរដែលបានផ្តួចផ្តើមមានទំហំធំ និងមានការថយចុះ។ បន្ថែមពីលើនេះ ទម្រង់នៃសូចនាករទោលអាចផ្លាស់ប្តូរក្នុងរូបភាពច្រើនបែប។

ការកាត់បន្ថយភាពក្រីក្រក្នុងគោលដៅទី១ គឺជាឧទាហរណ៍ដ៏មានសារៈសំខាន់ (រូបភាព ២.៣)។ និន្នាការនៃចំណុចដៅ ត្រូវបានកំណត់ផ្អែកលើគន្លងបន្ទាត់លីនេអ៊ែ ប៉ុន្តែ ត្រូវបានប្រែប្រួលយ៉ាងឆាប់រហ័សទៅជាទម្រង់ឡូហ្គារីត(ពីឆ្នាំ២០០៧) ជាមួយគ្នានឹងការថយចុះយ៉ាងច្រើន។ លទ្ធផលនេះ មិនទាន់បានឆ្លុះបញ្ចាំងពីចំណុចដៅចុងក្រោយនៅឡើយ។

**រូបភាព ២.៣ : គន្លងផ្លូវនិងចំណុចដៅរបស់គោលដៅទី១ នៃ គ.អ.ស.**




*ប្រភព៖ ទិន្នន័យអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា*

ប្រសិនបើចំណុចដៅចុងក្រោយនៅតែមានលក្ខណៈដាក់លាក់និងមានការពាក់ព័ន្ធ នោះទាមទារឲ្យមានការវិភាគស៊ីជម្រៅ នៅដើមគ្រា និងគន្លងដែលមិនមែនជាលីនេអ៊ែ។ ការពិនិត្យមើលជាប្រចាំ គួរតែត្រូវបានអនុវត្ត ដើម្បីធ្វើបច្ចុប្បន្នកម្មទម្រង់នៃការផ្លាស់ប្តូរតាមពេលវេលា។

### បទពិសោធដែលទទួលបានពីការពិនិត្យមើល គ.អ.ស.ក. និងការរៀបចំដើម្បីទទួលបានជោគជ័យ

បញ្ហាចុងក្រោយ គឺសំដៅការបែងចែកតួនាទីនិងការទទួលខុសត្រូវ តួនាទីនៃការផ្តល់យោបល់ផ្នែកគោលនយោបាយ និងការផ្សារភ្ជាប់ទៅនឹងការវិភាជធនធាន (តាមរយៈ ផ.យ.អ.ជ. និងផែនការថវិកា)។

ការគិតគូរជាចម្បង ចំពោះប្រព័ន្ធកំណត់ចំណុចដៅណាមួយ គឺជាការកំណត់តួនាទីនិងការទទួលខុសត្រូវរវាងក្រសួង ស្ថាប័ននានា និងសារៈសំខាន់ដាច់ដោយឡែកពីគ្នា ប៉ុន្តែក៏ទទួលជោគជ័យក្នុងការបញ្ចូលគ្នារវាងការតាមដានត្រួតពិនិត្យនិងការអនុវត្ត។ ក្នុងករណី គ.អ.ស.ក. នៅថ្នាក់ជាតិ ក្រសួងផែនការគឺជាស្ថាប័នទទួលខុសត្រូវក្នុងការដឹកនាំ សម្របសម្រួល និងពិនិត្យមើលការអនុវត្ត ហើយក្រសួង ស្ថាប័នពាក់ព័ន្ធមានភារកិច្ចអនុវត្តតាមតួនាទីក្នុងវិស័យនីមួយៗ។ ការធ្វើបច្ចុប្បន្នកម្ម និងការរៀបចំរបាយការណ៍ឲ្យបានត្រឹមត្រូវរួមទាំងការផ្តល់នូវមតិយោបល់ នឹងមានប្រយោជន៍សម្រាប់អ្នករៀបចំគោលនយោបាយ។

នៅកម្រិតវិស័យនិងថ្នាក់ក្រោមជាតិ វិធីសាស្ត្រដែលអនុវត្តមានលក្ខណៈពិសេស។ ការត្រួតពិនិត្យនៅក្នុងវិស័យនីមួយៗ ត្រូវបានបែងចែករវាងក្រសួងផែនការ ជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធ តាមរយៈការរៀបចំ តារាងពិន្ទុតាមវិស័យ ខណៈពេលដែលការអនុវត្តគឺជាការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន។ នេះគឺជាដំណើរការដ៏ល្អប្រសើរបំផុត ដែលក្រសួង ស្ថាប័នបានចូលរួមកាន់តែច្រើន ហើយជាសំខាន់ គោលដៅត្រូវបានសម្រេចដោយផ្ទាល់ តាមរយៈសកម្មភាពរបស់រាជរដ្ឋាភិបាល។ គួរកត់សម្គាល់ថា គ.អ.ស.ក. រួមបញ្ចូលប្រភេទគោលដៅទាំងនេះ(ជាញឹកញាប់ គោលដៅដែលមានមូលដ្ឋានលើលទ្ធផលនៃការងារសាធារណៈ) និងគោលដៅផ្សេងទៀត ដែលការធ្វើអន្តរាគមន៍ជាផ្លូវការ មានឥទ្ធិពលជាង ការអនុវត្តដោយគ្មានអន្តរាគមន៍ (ឧទាហរណ៍ លទ្ធផលនៃភាពក្រីក្រនិងបរិស្ថាន)។ លក្ខខណ្ឌទាំងនេះ បានធានាថាមានដំណើរការល្អចំពោះវិស័យអប់រំនិងសុខាភិបាល ហើយអាចនិយាយបានដែរថា វិស័យទាំងនេះបានទទួលលទ្ធផលល្អប្រសើរបំផុតក្នុងការសម្រេចបាន គ.អ.ស.ក.។ ទាំងនេះ ជាបទពិសោធដ៏ល្អរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការរៀបចំរបៀបវារៈកម្មវិធីគោលនយោបាយ និងសមត្ថភាពសម្រាប់ការឈានទៅសម្រេចបាន គ.អ.ច.ក.។

នៅថ្នាក់ក្រោមជាតិ ការអនុវត្តទទួលបានលទ្ធផលទាប ទោះបីជាមានតំបន់មួយចំនួនទទួលបានតារាងពិន្ទុ គ.អ.ស.ក. ពេញលេញ។ ក្នុងខណៈពេលដែលត្រូវបានទទួលស្គាល់ថា អំណាចរបស់ពួកគេមានកម្រិតក្នុងការធ្វើឲ្យមានឥទ្ធិពលដល់ការវិវឌ្ឍ និងការបង្ហាញឲ្យឃើញច្បាស់ពីភាពទន់ខ្សោយ

នៃសមត្ថភាពនៅមូលដ្ឋាន ក៏គួរកត់សម្គាល់ផងដែរក្នុងការកំណត់តួនាទី អាចបង្ហាញថា ការអនុវត្តជាក់ស្តែងមានភាពខុសគ្នាពីតំបន់មួយទៅតំបន់មួយ។

ចំណុចប្រសព្វរវាងការអនុវត្ត ការតាមដានត្រួតពិនិត្យនិងការរៀបចំរបាយការណ៍ និងកិច្ចខិតខំប្រឹងប្រែងអនុវត្ត ដែលជាទូទៅសំដៅលើ *ដំណើរការផ្តល់មតិយោបល់ផ្នែកគោលនយោបាយ* ក៏មានសារៈសំខាន់ផងដែរ ដើម្បីសម្រេចលទ្ធផលនៃការអនុវត្ត គ.អ.ស.ក.។ ភាពផ្សារភ្ជាប់គ្នានេះ គឺសំដៅការផ្សារភ្ជាប់ក្របខ័ណ្ឌ គ.អ.ស.ក. តាមរយៈការរៀបចំថវិកានិងប្រព័ន្ធថវិកា ទៅនឹងសេចក្តីសម្រេចចិត្តផ្នែកគោលនយោបាយ និងការវិភាជថវិកា។ បទពិសោធទទួលបានពី គ.អ.ស.ក. មួយផ្សេងទៀត គឺកិច្ចពិភាក្សាជាមួយដៃគូអភិវឌ្ឍនានា និង អ្នកមានចំណែកពាក់ព័ន្ធនានា តាមរយៈយន្តការនៃក្រុមការងារបច្ចេកទេសចម្រុះ។ ជាពិសេស ការផ្សារភ្ជាប់យ៉ាងល្អ ផ.យ.អ.ជ. និងផែនការតាមវិស័យដោយផ្អែកលើបរិបទនៃភាពជាដៃគូ។ កិច្ចខិតខំប្រឹងប្រែងបន្តទៀតគឺ លើកកម្ពស់ដំណើរការរៀបចំថវិកា ប៉ុន្តែដំណើរការនេះកំពុងស្ថិតនៅក្នុងដំណាក់កាលកំណត់នៅឡើយ។ ជាមួយនេះដែរ មតិយោបល់ភាគច្រើនទៅលើការអនុវត្ត គ.អ.ស.ក. បានធ្វើឡើងកាលពីអតីតកាលដែលការអភិវឌ្ឍនៅមានកម្រិតទាបនៅឡើយ។ ដូច្នេះ ការលើកកម្ពស់ដំណើរការនៃការផ្សារភ្ជាប់ទំនាក់ទំនងខាងលើ ក្នុងដំណាក់កាលដែលធនធានក្នុងស្រុកនឹងដើរតួនាទីសំខាន់ក្នុងការអភិវឌ្ឍ ពិតជាមានសារៈសំខាន់សម្រាប់ឈានទៅសម្រេចបាន គ.អ.ច.ក។ ការពិភាក្សាលម្អិត នៅជំពូកទី៥។

# ជំពូកទី៣ : ក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា

## ៣.១ សេចក្តីផ្តើម

ជំពូកទី៣នេះ បង្ហាញពីក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា(គ.អ.ច.ក.) ដែលបានរៀបចំនិងចងក្រងឡើងក្រោមការដឹកនាំរបស់ក្រសួងផែនការ។ ជំពូកនេះនឹងផ្តល់ព័ត៌មានដល់អ្នកមានចំណែកពាក់ព័ន្ធទាំងអស់ អំពីសំណើរបស់រាជរដ្ឋាភិបាលនិងទទួលយកនូវមតិយោបល់និងធាតុចូលទាក់ទងនឹងបញ្ហាមួយចំនួនដែលត្រូវដោះស្រាយ។ ជំពូកនេះផ្តើមចេញពីការពិភាក្សាលើការរៀបចំក្របខ័ណ្ឌ គ.អ.ច.ក. ដោយប្រៀបធៀបជាមួយក្របខ័ណ្ឌសកល និងការកំណត់អំពីបញ្ហាប្រឈមសំខាន់ៗនិងសកម្មភាពត្រូវអនុវត្ត។

## ៣.២ ដំណើរការរៀបចំក្របខ័ណ្ឌ គ.អ.ច.ក.

បន្ទាប់ពីអង្គការសហប្រជាជាតិ បានអនុម័ត គ.អ.ច. សកលនៅចុងឆ្នាំ២០១៥ រាជរដ្ឋាភិបាលកម្ពុជាបានប្រគល់សិទ្ធិប្រទានដល់ក្រសួងផែនការក្នុងការដឹកនាំ និងសម្របសម្រួលការងាររៀបចំក្របខ័ណ្ឌ គ.អ.ច.ក.។ ដំណើរការដំបូងបានចាប់ផ្តើមពីការជូនដំណឹងដល់គ្រប់ក្រសួង ស្ថាប័ន និងអ្នកមានចំណែកពាក់ព័ន្ធទាំងអស់ រួមទាំងសង្គមស៊ីវិល បន្ទាប់មកទៀត គឺដំណើរការរៀបចំក្របខ័ណ្ឌ គ.អ.ច.ក. ផ្លូវការ។ ដូចការរៀបចំគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាដែរ គោលការណ៍របស់រាជរដ្ឋាភិបាលកម្ពុជា គឺបន្សុាំនិងអនុម័តគោលដៅ ការជ្រើសរើសចំណុចដៅនិងការកំណត់សូចនាករដើម្បីបន្សុីជាមួយបរិបទកម្ពុជា និងរៀបចំក្របខ័ណ្ឌមួយដែលកំណត់ក្នុងដំណើរការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់ថាមានការងារកាន់ច្រើន ជាពិសេសទិន្នន័យសម្រាប់ គ.អ.ច. សកល ដែលមានគោលដៅចំនួន១៧ ចំណុចដៅចំនួន១៦៩ និងសូចនាករចំនួន២៣០។ លើសពីនេះទៀត គោលការណ៍សម្រាប់អនុវត្តនិងតាមដានត្រួតពិនិត្យមានលក្ខណៈខុសគ្នាក្នុងចំណោមប្រទេសជាសមាជិកអង្គការសហប្រជាជាតិ ដែលតម្រូវឲ្យប្រទេសជាសមាជិកដឹកនាំលើការងារនេះនិងមានសិទ្ធិសម្រេចទាក់ទងនឹងក្របខ័ណ្ឌនេះ ប៉ុន្តែពឹងផ្អែកលើប្រព័ន្ធទិន្នន័យរដ្ឋបាលនិងប្រព័ន្ធស្ថិតិជាតិ។

ដើម្បីជួយសម្រួលដល់ដំណើរការរៀបចំក្របខ័ណ្ឌ គ.អ.ច.ក. រាជរដ្ឋាភិបាលកម្ពុជា បានសហការជិតស្និទ្ធជាមួយស្ថាប័នរបស់អង្គការសហប្រជាជាតិផ្តល់ការវិភាគដំបូងចំនួន២៖ *ទី១* គឺការវាយតម្លៃរួមឆាប់រហ័ស ដែលធ្វើឡើងក្នុងឆ្នាំ២០១៦ ដោយកម្មវិធីអភិវឌ្ឍសហប្រជាជាតិប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិច ដោយផ្តោតលើគោលដៅ ចំណុចដៅ ផ្តល់ជាការវាយតម្លៃលើគោលនយោបាយនិងយុទ្ធសាស្ត្រនានារបស់កម្ពុជាដែលមានស្រាប់ ជាពិសេស ផ.យ.អ.ជ. និង យុទ្ធសាស្ត្រតាមវិស័យនិង

អន្តរវិស័យ។ ការវាយតម្លៃនេះផ្តល់ជាការវិភាគលើការបន្សុី គ.អ.ច.ក.និង គ.អ.ច. សកល និងផ្តល់ជាមូលដ្ឋានសម្រាប់ការកំណត់អាទិភាពនៅពេលអនាគត។

**រូបភាព ៣.១ : ការវាយតម្លៃភាពបន្សុីគ្នារវាង គ.អ.ច.និងគោលនយោបាយនិងយុទ្ធសាស្ត្រជាតិ**




*ប្រភព : ការគណនាដោយផ្អែកលើក្រុមការងារអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ ឆ្នាំ២០១៦*

ការវាយតម្លៃនេះ បានបង្ហាញពីទំនាក់ទំនងរវាងចំណុចដៅរបស់ គ.អ.ច. (១០៩ចំណុចដៅក្នុងចំណោមចំណុចដៅសរុប១៦៩) និង គោលនយោបាយនិងយុទ្ធសាស្ត្ររបស់កម្ពុជា ដោយបានធ្វើការបន្សុីទាំងស្រុងចំនួន៨៧ចំណុចដៅ ដោយមានការបន្សុីតាមវិស័យចំនួន១៧ចំណុចដៅ និងមិនមានការបន្សុីចំនួន១៧ចំណុចដៅ។[5] ដូចនេះ ចំណុចដៅពាក់ព័ន្ធរបស់ គ.អ.ច. ប្រមាណ៩៥% ត្រូវគ្នាជាមួយរបៀបវារៈនៃកម្មវិធីនយោបាយដែលមានស្រាប់របស់កម្ពុជា ដែលផ្តល់ជាមូលដ្ឋានសម្រាប់ការអនុមតិលើគោលដៅនានា និងការផ្សារភ្ជាប់ទំនាក់ទំនងក្របខ័ណ្ឌ គ.អ.ច.ក. ទៅនឹងដំណើរការរៀបចំផែនការជាតិ។

*ទី២* គឺ ការវាយតម្លៃលើសូចនាករនិងប្រភពទិន្នន័យរបស់អង្គភាពស្ថិតិរបស់អង្គការសហប្រជាជាតិ ក្នុងឆ្នាំ២០១៧។ គោលការណ៍នៃការវាយតម្លៃនេះគឺពិនិត្យមើលការបន្សុី វដ្តទិន្នន័យ និងគុណភាពប្រភពទិន្នន័យបច្ចុប្បន្ន សម្រាប់គាំទ្រដល់ទិន្នន័យរបស់សូចនាករ គ.អ.ច. ចំនួន២៣២ (សូចនាករចំនួន២០៥ បន្ទាប់ពីដកចេញសូចនាករដែលមិនអាចអនុវត្តបាន)។ ការវាយតម្លៃនេះមាន៣ផ្នែក គឺទិន្នន័យដែលមានស្រាប់ឬអាចផលិតបានដោយងាយ ទិន្នន័យដែលអាចធ្វើបានដោយតម្រូវឲ្យមានកិច្ចខិតខំប្រឹងប្រែង និងទិន្នន័យដែលមិនអាចផលិតបាន។ បន្ទាប់មកទៀត ការវាយតម្លៃនេះបានរៀបចេញជាចំនួន១២៣សូចនាករ ដែលជ្រើសរើសដោយអាស៊ាន និងមានការត្រួតពិនិត្យឡើងវិញលើប្រភពទិន្នន័យដែលរៀបចំដោយបេសកកម្មបច្ចេកទេសគាំទ្រដោយសហគមន៍អឺរ៉ុប នៅចុងឆ្នាំ

---

[5] *ការប្រៀបធៀបនេះបានផ្អែកលើសូចនាករចំនួន១០៩ : ក្នុងចំណោមសូចនាករសុរបចំនួន១៦៩ មាន៤មិនអាចអនុវត្តបាន ៥៣ជាមធ្យោបាយសម្រាប់អនុវត្តចំណុចដៅ និង ១៣ជាសូចនាករពាក់ព័ន្ធនឹងគោលដៅភាពជាដៃគូ*

២០១៧។ លទ្ធផលជាមូលដ្ឋាន ការវិភាគទៅលើគោលគំនិត និង សូចនាករអាស៊ានត្រូវបានផ្តល់ជូននៅក្នុងតារាង ៣ .១ និងរូបភាព ៣.២ ខាងក្រោម។

**តារាង ៣.១ : ការវាយតម្លៃរបស់អង្គភាពស្ថិតិរបស់អង្គការសហប្រជាជាតិ ស្តីពីស្ថានភាពសូចនាករ**

| | ការវាយតម្លៃរបស់UNSD | | ការវាយតម្លៃរបស់អាស៊ាន | | ជម្រើសទី២ | |
|---|---|---|---|---|---|---|
| | ចំនួន | % | ចំនួន | % | ចំនួន | % |
| ទិន្នន័យដែលមានស្រាប់ឬអាចផលិតបានដោយងាយ | ៦៦ | ៣២,២ | ៥១ | ៤១,៥ | ៧០ | ៣៤,១ |
| ទិន្នន័យដែលអាចធ្វើបានដោយតម្រូវឲ្យមានកិច្ចខិតខំប្រឹងប្រែង | ៩៤ | ៤៥,៩ | ៥០ | ៤០,៧ | ១០១ | ៤៩,៣ |
| ទិន្នន័យដែលមិនអាចផលិតបាន | ៤៥ | ២២,០ | ២២ | ១៧,៩ | ៣៤ | ១៦,៦ |

*ប្រភព : ការគណនាដោយផ្អែកលើអង្គភាពស្ថិតិរបស់អង្គការសហប្រជាជាតិ ឆ្នាំ២០១៧*

**រូបភាព ៣.២ : ការវាយតម្លៃសូចនាករ**




*ប្រភព : ការគណនាដោយផ្អែកលើអង្គភាពស្ថិតិរបស់អង្គការសហប្រជាជាតិ ឆ្នាំ២០១៧*

ការវាយតម្លៃនីមួយៗបានកំណត់ភាពប្រឈមនានា ក្នុងការរៀបចំសូចនាករ គ.អ.ច. ដោយមានទិន្នន័យដែលមានគុណភាព។ ការវាយតម្លៃដំបូងដោយអង្គភាពស្ថិតិរបស់អង្គការសហប្រជាជាតិ រកឃើញថាសូចនាករចំនួន៣២% មានទិន្នន័យដែលមានស្រាប់ឬអាចផលិតបានដោយងាយ ៤៦% មានទិន្នន័យដែលអាចធ្វើបានដោយតម្រូវឲ្យមានកិច្ចខិតខំប្រឹងប្រែង និង២២%មានទិន្នន័យដែលមិន

អាចផលិតបាន។ ចំនួនសូចនាករតិចដែលកំណត់ដោយអាស៊ានបានកែលម្អស្ថានភាពនេះ ដោយ ៤២% មានទិន្នន័យដែលមានស្រាប់ឬអាចផលិតបានដោយងាយ ៤១% មានទិន្នន័យដែលអាចធ្វើបានដោយតម្រូវឲ្យមានកិច្ចខិតខំប្រឹងប្រែង និង១៧% មានទិន្នន័យដែលមិនអាចផលិតបាន។ ស្ថានភាពបានកែលម្អកាន់តែច្រើន ដោយផ្អែកលើលទ្ធផលនៃការវាយតម្លៃទីពីរ។

លទ្ធផលនៃការវាយតម្លៃទាំងពីរនេះ បានបង្ហាញពីបញ្ហាប្រឈមមួយចំនួនដែលនឹងជួបប្រទះក្នុងការរៀបចំក្របខ័ណ្ឌ គ.អ.ច.ក. និងបានបង្ហាញអំពីការងាររបស់ក្រសួងផែនការក្នុងឆ្នាំ២០១៧ និងដើមឆ្នាំ២០១៨ ក្នុងការរៀបចំក្របខ័ណ្ឌ គ.អ.ច.ក.។ បន្ទាប់ពីការកិច្ចពិភាក្សាដំបូងជាមួយក្រសួង ស្ថាប័នរួចមក ក្រសួងផែនការបានកំណត់យកមូលដ្ឋានរបស់ក្របខ័ណ្ឌ គ.អ.ច.ក. ដែលរួមមានការទទួលយកគោលដៅសកលទាំង១៧ និងបន្ថែមគោលដៅចំនួន១ទៀត គឺគោលដៅទី១៨ ស្តីពីការបោសសម្អាតគ្រាប់មីននិងយុទ្ធភណ្ឌមិនទាន់ផ្ទុះ ព្រមទាំងទទួលយកចំណុចដៅនានាក្នុងក្របខ័ណ្ឌសកលណាដែលទាក់ទងនឹងកម្ពុជានិងមានលទ្ធភាពរៀបចំសូចនាករ ដែលអាចវាស់វែងនិងជឿទុកចិត្តបាន។

ក្របខ័ណ្ឌសម្រាប់អនុវត្ត ត្រូវបានរៀបចំឡើង ដោយក្រសួងផែនការជាមួយក្រសួង ស្ថាប័នដែលមានតួនាទីជ្រើសរើសសូចនាកររបស់សកល ឬរៀបចំសូចនាករថ្មី (សូចនាករតំណាង សូចនាករជំនួស ឬសូចនាករបន្ថែម) និងពិនិត្យប្រភពទិន្នន័យដែលអាចទទួលបានមកពីស្ថិតិជាតិនិងទិន្នន័យរដ្ឋបាល។ ក្រសួងផែនការបានផ្តល់ការណែនាំស្តីពីមូលដ្ឋានរបស់ គ.អ.ច. សកល ការវិភាគដំបូងទាំងពីររបស់អង្គការសហប្រជាជាតិ និងការងារតាមដានត្រួតពិនិត្យនិងវាយតម្លៃតាមគោលការណ៍SMART។ ផ្នែកចុងក្រោយបានដាក់ចេញនូវតារាងគំរូសម្រាប់រៀបចំសូចនាករ ដូចខាងក្រោម៖

- ***តារាងទី១ ការជ្រើសរើសសូចនាករ និងមេតាទិន្នន័យ*** កំណត់ស្ថាប័នទទួលខុសត្រូវ ប្រភពទិន្នន័យ វដ្តទិន្នន័យ និយមន័យ និងវិធីសាស្ត្រគណនា។
- ***តារាងទី២ លម្អិតព័ត៌មានចំណុចដៅរបស់សូចនាករ*** ដោយយកឆ្នាំ២០១៥ ជាឆ្នាំគោលចំណុចដៅប្រចាំឆ្នាំសម្រាប់សូចនាករនីមួយៗ។ តួលេខរបស់ចំណុចដៅត្រូវពឹងផ្អែកលើប្រភពទិន្នន័យដែលមាន។

ការរៀបចំតារាងទាំងពីរនេះ ត្រូវបានសម្របសម្រួល និងពិភាក្សា តាមរយៈសិក្ខាសាលាពិគ្រោះយោបល់ជាច្រើនលើកនៅតាមវិស័យនីមួយៗ ដូចជាវិស័យ អប់រំ សុខាភិបាល ជាដើម និងអន្តរវិស័យដូចជាយេនឌ័រ ការប្រែប្រួលអាកាសធាតុឬបរិស្ថានជាដើម ដែលត្រូវបានរៀបចំឡើងដោយក្រសួងផែនការនិងក្រសួង ស្ថាប័នពាក់ព័ន្ធ។ បន្ទាប់ពីបានធ្វើតារាងបញ្ជីសូចនាករទាំងពីរ មកក្រសួងផែនការក្នុងឆ្នាំ២០១៧រួចមក តារាងបញ្ជីសូចនាករទាំងពីរ នេះត្រូវបានត្រួតពិនិត្យនិងរៀបចំជាថ្មីដោយក្រសួងផែនការនៅដើមឆ្នាំ២០១៨។

## ៣.៣- ក្របខ័ណ្ឌ គ.អ.ច.ក. ដែលបានស្នើឡើង

### ៣.៣.១-ទិដ្ឋភាពទូទៅនៃ គ.អ.ច.ក.

ការដាក់បញ្ចូលគ្នាតារាងទី១និងទី២ខាងលើនេះ គឺជាលទ្ធផលចុងក្រោយនៃដំណើរការរៀបចំក្របខ័ណ្ឌ គ.អ.ច.ក. ដើម្បីតម្រង់ទិសការអភិវឌ្ឍ។ ដូចបានគូសបញ្ជាក់ខាងលើ ក្របខ័ណ្ឌ គ.អ.ច.ក. ដែលបានស្នើឡើងនេះ ត្រូវមានសង្គតិភាពជាមួយ គ.អ.ច. សកល ព្រមទាំងស្របជាមួយនឹងបរិការណ៍ គ.អ.ច.ក. ដែលត្រូវបានអនុម័ត ដោយរាជរដ្ឋាភិបាលកម្ពុជានិងមានទិន្នន័យគ្រប់គ្រាន់។ ក្របខ័ណ្ឌនេះរួមបញ្ចូលទាំង៖

- គោលដៅចំនួន១៨ ដោយរក្សានូវគោលដៅសកលទាំង១៧ និងបន្ថែមគោលដៅមួយរបស់កម្ពុជាពាក់ព័ន្ធនឹងការបោសសម្អាតមីន។
- ចំណុចដៅចំនួន៨៨ រួមបញ្ចូលនូវចំណុចដៅសកលចំនួន៨៤ ដែលមានការគាំទ្រទិន្នន័យ ចំណុចដៅចំនួន៨ របស់គោលដៅភាពជាដៃគូ និងចំណុចដៅបន្ថែមចំនួន៤ រួមទាំងចំណុចដៅ៣ របស់គោលដៅទី១៨និង
- សូចនាករចំនួន១៤៨ រួមបញ្ចូលនូវសូចនាកររបស់សកលមួយចំនួន និងបន្ថែមសូចនាកររបស់ជាតិ ដែលជាសូចនាករថ្មី និង សូចនាករជំនួស។

តារាងនេះ នឹងរួមបញ្ចូលផងដែរនូវមូលដ្ឋានទិន្នន័យដ៏មានសារៈសំខាន់សម្រាប់ គ.អ.ច.ក. ក្នុងរូបភាព ៣.៣ ខាងក្រោម។ តារាងទី១ផ្តល់នូវមេតាទិន្នន័យសម្រាប់ចំណុចដៅនិងសូចនាករ តារាងទី២ ដែលមានសារសំខាន់សម្រាប់ពិនិត្យមើលវឌ្ឍនភាពនៃការសម្រេចបាន ផ្តល់នូវទិន្នន័យសម្រាប់ចំណុចដៅនិងសូចនាករដែលបានជ្រើសរើសនៅចំណុចចាប់ផ្តើម ដល់ចំណុចដៅចុងក្រោយ និងតម្លៃនៃចំណុចដៅសម្រាប់ការធ្វើអន្តរាគមន៍។ ព័ត៌មានពេញលេញ មានបង្ហាញជូននៅក្នុងផ្នែកទី២។

**រូបភាព ៣.៣ : តារាងទី១និងទី២**

**តារាងទី១ : មេតាទិន្នន័យ**

| ចំណុចដៅ | លេខកូដចំណុចដៅ | សូចនាករ | លេខកូដសូចនាករ | ស្ថាប័នទទួលខុសត្រូវ | ប្រភពទិន្នន័យ | វដ្តនៃទិន្នន័យ | និយមន័យ | វិធីសាស្ត្រគណនា | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | ភាគយក | ភាគបែង | |

**តារាងទី២ : ចំណុចដៅរបស់សូចនាករ**

| ចំណុចដៅ | សូចនាករ | សូចនាករបន្ទាប់ | ឯកតា | តម្លៃដើមគ្រា | ចន្លោះពេលនៃចំណុចដៅ | | | | | | | | | | | | | | ចំណុចដៅចុងក្រោយ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |

បន្ទាប់ពីទទួលបានទិន្នន័យ ក្រសួងផែនការនឹងពិនិត្យមើលពីគុណភាព បញ្ហាប្រឈមនានាដែលនឹងត្រូវធ្វើការពិភាក្សាក្នុងជំពូកបន្ទាប់។ ប៉ុន្តែជាទូទៅក្របខ័ណ្ឌនេះ ត្រូវបានបញ្ចប់ដោយផ្តល់នូវការចង្អុលបង្ហាញពីបញ្ជីសូចនាករ ចំណុចដៅ និង គោលដៅ ដែលត្រូវប្រើប្រាស់នៅឆ្នាំបន្ទាប់។

### ៣.៣.២ ការប្រៀបធៀបជាមួយនឹងក្របខ័ណ្ឌសកល

ការប្រៀបធៀបលម្អិតបន្ថែមទៀត ជាមួយនឹងក្របខ័ណ្ឌសកលមានសារៈសំខាន់ណាស់ក្នុងការបង្ហាញពីកម្រិតនិងលក្ខណៈនៃដំណើរការមូលដ្ឋានីយកម្ម។ ភាពខុសគ្នានោះ គឺការបន្ថែមគោលដៅទី១៨ ពាក់ព័ន្ធនឹងការបោសសម្អាតមីន ព្រមទាំងការកែសម្រួលចំណុចដៅ និងសូចនាករឲ្យត្រូវតាមបរិការណ៍កម្ពុជា ។

នៅកម្រិតចំណុចដៅ ទោះបីជាទម្រង់នៃចំណុចដៅនីមួយៗត្រូវបានរក្សាទុកទាំងអស់ ការទទួលយកចំណុចដៅមានភាពខុសគ្នាពីគោលដៅមួយទៅគោលដៅមួយទៀត ដោយផ្អែកលើការអនុវត្តនិងទិន្នន័យដែលអាចមាន។ រូបភាព៣.៤ ផ្តល់ការប្រៀបធៀបដោយសង្ខេប និងបង្ហាញយ៉ាងច្បាស់ពីកម្រិតនៃការប្រែប្រួលចំណុចដៅនៃគោលដៅនីមួយៗ។ ក្របខ័ណ្ឌ គ.អ.ច.ក. ដែលបានរៀបចំនេះ បានរក្សាទុកចំណុចដៅសំខាន់ៗ និង រៀបចំចំណុចដៅបានសមស្របនៅក្នុងគោលដៅនីមួយៗ កម្រិតខុសគ្នាខ្លាំងរវាង គ.អ.ច.ក. និង គ.អ.ច. សកល គឺ គោលដៅទី១៧ ស្តីពីភាពជាដៃគូសកល។ ទន្ទឹមនឹងនោះ ចំនួនចំណុចដៅនៅក្នុងគោលដៅទី៨ រហូតដល់គោលដៅទី១២ និងគោលដៅទី១៤ របស់ គ.អ.ច.ក. មានចំនួនតិច។

**រូបភាព ៣.៤៖ ចំណុចដៅរបស់ គ.អ.ច.ក. និង គ.អ.ច. សកល (តាមគោលដៅ)**




*ប្រភព : ការគណនាផ្ទាល់*

នៅកម្រិតសូចនាករ ការទទួលយកសូចនាករសកល និងការបង្កើតសូចនាករថ្មីនៃក្របខ័ណ្ឌ គ.អ.ច.ក. គឺមានកម្រិតទាប ។ ក្រសួង ស្ថាប័ន បានចូលរួមយ៉ាងពេញលេញក្នុងការធ្វើមូលដ្ឋានីយកម្ម និងបានកំណត់យ៉ាងច្បាស់ពីគម្លាតរបស់សូចនាករ។ សូចនាករសកល មួយចំនួនត្រូវបានរក្សាទុក

មួយចំនួនផ្សេងទៀតត្រូវបានកែសម្រួល ហើយសូចនាករជំនួសជាច្រើនត្រូវបានកំណត់។ សូចនាករចំនួន១៤៨ ត្រូវបានទទួលយក បើប្រៀបធៀបទៅនឹងសូចនាករ សកលចំនួន២៣២។ រូបភាព ៣.៥ ខាងក្រោម បង្ហាញពីការផ្លាស់ប្តូរចំនួនសូចនាករសកល និងចំនួនសូចនាកររបស់ គ.អ.ច.ក.។ ជាថ្មីម្តងទៀត ខណៈពេលដែលមានការប្រែប្រួលសូចនាករត្រូវបានកំណត់ពេញលេញនៅក្នុងគោលដៅនីមួយៗ (និងនៅក្នុងចំណុចដៅនីមួយៗ) របស់ គ.អ.ច.ក.។ ដូចបានបង្ហាញតាមរូបភាពពាក់ព័ន្ធនឹងគោលដៅសកល ចំនួនសូចនាករដែលច្រើនជាងត្រូវបានទទួលយកនៅក្នុងគោលដៅទី២ ភាពអត់ឃ្លាន គោលដៅទី៣ សុខភាព គោលដៅទី៤ ការអប់រំ និងគោលដៅទី៥ យេនឌ័រ ប៉ុន្តែ សូចនាករមានចំនួនតិចតួចនៅក្នុងគោលដៅទី១១ ពាក់ព័ន្ធនឹងទីក្រុងប្រកបដោយចីរភាព គោលដៅទី១៦ សន្តិភាព និងគោលដៅទី១៧ ភាពជាដៃគូ។

**រូបភាពទី៣.៥៖ សូចនាកររបស់ គ.អ.ច.ក. និង គ.អ.ច. សកល (តាមគោលដៅ)**




*ប្រភព: ការគណនាផ្ទាល់*

ការប្រៀបធៀបរវាងក្របខ័ណ្ឌ គ.អ.ច.ក. និង គ.អ.ច. សកល បង្ហាញនៅក្នុងតារាង ៣.២ និងរូបភាព ៣.៦។ តារាងនិងរូបភាពនេះបញ្ជាក់យ៉ាងច្បាស់ថា មានចំណុចរួមគ្នាជាច្រើនរវាងក្របខ័ណ្ឌទាំង២ ជាពិសេស គឺនៅកម្រិតចំណុចដៅ។ ខណៈពេលដែលចំណុចដៅនៃ គ.អ.ច. សកល មានចំនួន១៦៩ ការវាយតម្លៃរួមឆាប់រហ័ស បានបង្ហាញថា មានតែចំណុចដៅចំនួន១០៥ប៉ុណ្ណោះដែលសមស្របនឹងបរិការណ៍កម្ពុជា។ ប៉ុន្តែកម្ពុជាសម្រេចទទួលយកចំណុចដៅចំនួនតែ៨៥ (ប្រមាណ ៨០%) ពី គ.អ.ច. និងបន្ថែមចំណុចដៅចំនួន៣ ទៀតសម្រាប់គោលដៅទី១៨។

បន្ថែមលើនេះទៀត កម្រិតនៃការទទួមានភាពស្មុគ្រស្មាញនិងពិបាកក្នុងការបូកសរុប ជាពិសេស នៅកម្រិតសូចនាករ។ តារាង ៣.២ ផ្តល់នូវការបង្ហាញលម្អិតពីការផ្លាស់ប្តូរនៅក្នុងគោលដៅទី១(ភាពក្រីក្រ)។ ឧទាហរណ៍ នៅក្នុងគោលដៅទី១ កម្ពុជាបានជ្រើសរើសចំណុចដៅចំនួន៣ ក្នុងចំណោមចំណុចដៅសកល ចំនួន៧ ហើយនៅក្នុងចំណុចដៅទាំង៣ ដែលបានជ្រើសរើស កម្ពុជាបានជ្រើសរើសយកសូចនាករចំនួន៤ ក្នុងចំណោមសូចនាករចំនួន៥ និងបន្ថែមសូចនាករថ្មីចំនួន៥ទៀត។

ដូចនេះ ក្នុងគោលដៅទី១នេះ កម្ពុជាមិនបានជ្រើសរើសចំណុចដៅចំនួន៤ និងសូចនាករចំនួន៨ ពី គ.អ.ច ប៉ុន្តែដោយសារការបន្ថែមសូចនាករថ្មីចំនួន៥ ទើបគម្លាតសូចនាករនៃគោលដៅទី១ មានត្រឹម៣។

## រូបភាព ៣.៦ ការប្រែប្រួលនៃចំណុចដៅ និងសូចនាករ គ.អ.ច.ក. ធៀបនឹង គ.អ.ច សាកល (តាមគោលដៅ)




*ប្រភព : ការគណនាផ្ទាល់*

## តារាង ៣.២ : ក្របខ័ណ្ឌ គ.អ.ច.ក. (ធៀបនឹងចំណុចដៅនិងសូចនាករ គ.អ.ច. សកល)

| | គោលដៅ | ក្របខ័ណ្ឌសកល | | ក្របខ័ណ្ឌ គ.អ.ច.ក. | | ការប្រែប្រួល | |
|---|---|---|---|---|---|---|---|
| | | ចំនួនចំណុចដៅ | ចំនួនសូចនាករ | ចំនួនចំណុចដៅ | ចំនួនសូចនាករ | ចំនួនចំណុចដៅ | ចំនួនសូចនាករ |
| 1 | ពុំមានភាពក្រីក្រ | ៧ | ១៤ | ៣ | ៩ | -៤ | -៥ |
| 2 | គ្មានគ្រោះអត់ឃ្លាន | ៨ | ១៣ | ៥ | ៧ | -៣ | -៦ |
| 3 | សុខភាពនិងសុខុមាលភាពល្អប្រសើរ | ១៣ | ២៧ | ១១ | ២១ | -២ | -៦ |
| 4 | ការអប់រំប្រកបទៅដោយគុណភាព | ១០ | ១១ | ៧ | ១៨ | -៣ | ៧ |
| 5 | សមភាពយេនឌ័រ | ៩ | ១៤ | ៧ | ១២ | -២ | -២ |
| 6 | ទឹកស្អាត និងអនាម័យ | ៨ | ១១ | ៥ | ៦ | -៣ | -៥ |
| 7 | ថាមពលស្អាតដែលមានតម្លៃសមរម្យ | ៥ | ៦ | ៣ | ៤ | -២ | -២ |
| 8 | ការងារសមរម្យនិងកំណើនសេដ្ឋកិច្ច | ១២ | ១៧ | ៥ | ១២ | -៧ | -៥ |
| 9 | ឧស្សាហកម្ម និងហេដ្ឋារចនាសម្ព័ន្ធ | ៨ | ១២ | ៥ | ៧ | -៣ | -៥ |
| 10 | កាត់បន្ថយវិសមភាព | ១០ | ១០ | ៥ | ៥ | -៥ | -៥ |
| 11 | ទីក្រុងនិងសហគមន៍ប្រកបដោយចីរភាព | ១០ | ១២ | ១ | ៤ | -៩ | -៨ |
| 12 | ការប្រើប្រាស់និងការផលិតប្រកបដោយការទទួលខុសត្រូវ | ១១ | ១១ | ២ | ៤ | -៩ | -៧ |
| 13 | ការប្រែប្រួលអាកាសធាតុ | ៥ | ៥ | ៣ | ៥ | -២ | ០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 14 | ជីវិតក្រោមទឹក | ១០ | ១០ | ៥ | ៦ | -៥ | -៤ |
| 15 | ជីវិតលើដី | ១២ | ១២ | ៧ | ៩ | -៥ | -៣ |
| 16 | សន្តិភាព យុត្តិធម៌ និងស្ថាប័នរឹងមាំ | ១២ | ២២ | ៣ | ៣ | -៩ | -១៩ |
| 17 | ភាពជាដៃគូ ដើម្បីសម្រេចគោលដៅ | ១៩ | ២៥ | ៨ | ១០ | -១១ | -១៥ |
| 18 | ការបោសសម្អាតមីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះសល់ពីសង្គ្រាម | 0 | 0 | ៣ | ៦ | ៣ | ៦ |
| សូចនាករដូចគ្នានៅក្នុងគោលដៅខុសគ្នា | | | ១២ | | | 0 | 0 |
| | | ១៦៩ | ២៣២ | ៨៨ | ១៤៨ | -៨១ | -៨៤ |

*ប្រភព៖ ការគណនាផ្ទាល់*

## ៣.៤- បញ្ហាដែលនៅសេសសល់

ការពិនិត្យដោយក្រសួងផែនការ បានកំណត់បញ្ហាចំនួន២ដែលត្រូវដោះស្រាយតាមរយៈការបង្កើតក្របខ័ណ្ឌ គ.អ.ច.ក. សម្រាប់ការអនុវត្ត។ បញ្ហាទី១ សំដៅលើបញ្ហាអនុលោមភាពមូលដ្ឋានដែលក្រសួងផែនការត្រូវការដើម្បីចងក្រង រួមមាន ការដាក់បញ្ចូលសំណុំមេតាទិន្នន័យពេញលេញនៅក្នុងតារាងទី១ និងគោលការណ៍ទិន្នន័យតាមដានសំខាន់ៗរបស់តារាងទី២ ពីព្រោះថា បញ្ហាទាំងនេះមានការជាប់ពាក់ព័ន្ធគ្នា និងមានឥទ្ធិពលលើភាពគ្រប់គ្រាន់នៃសូចនាករដែលគ្របដណ្តប់លើគោលដៅនិងចំណុចដៅ។ បញ្ហាទី២ សំដៅទៅលើតម្រូវការទិន្នន័យដែលមានគុណភាពកាន់តែច្រើន ដែលមានឥទ្ធិពលដល់ប្រសិទ្ធភាពនៃក្របខ័ណ្ឌនៅពេលខាងមុខ។

វាមានសារៈសំខាន់ផងដែរដែលត្រូវគូសបញ្ជាក់ពីការប្រើប្រាស់ ធ្វើដូច្នេះគុណភាពតារាងម៉ាទ្រីសនឹងមានការយកចិត្តទុកដាក់កាន់តែខ្លាំងឡើង ជាពិសេសទៅលើតួនាទីក្នុងការផ្សារភ្ជាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទៅនឹងការបម្រើសេវាជាក់ស្តែង។ ក្របខ័ណ្ឌ គ.អ.ច.ក. នឹងផ្សារភ្ជាប់ក្របខ័ណ្ឌនេះទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ក៏ដូចជាទៅនឹងផែនការយុទ្ធសាស្ត្រថវិកា ដែលជាឧទាហរណ៍មួយជាក់ស្តែង បង្ហាញពីនីតិវិធីប្រតិបត្តិ។ ក្រសួងផែនការតាមរយៈវិទ្យាស្ថានជាតិស្ថិតិកំពុងរៀបចំយុទ្ធសាស្ត្រថ្នាក់ជាតិក្នុងការអភិវឌ្ឍស្ថិតិ ដើម្បីលើកកម្ពស់ការគ្របដណ្តប់ឲ្យកាន់តែប្រសើរឡើង និងទទួលបាននូវទិន្នន័យស្ថិតិដែលមាននិយាមកាន់តែប្រសើរ៖

ទី១ គឺការគិតពិចារណាលើគុណភាពមូលដ្ឋាននៃចំណុចដៅ និងសូចនាករ ការរៀបចំនិងការបញ្ជាក់លម្អិតនៃឆ្នាំគោល ចន្លោះពេល និងទិន្នន័យចំណុចដៅឆ្នាំចុងក្រោយនេះ ហើយសូចនាករអាចនឹងវាយតម្លៃទៅតាមលក្ខណវិនិច្ឆ័យ SMART និង ត្រូវផ្អែកលើបរិបទរបស់កម្ពុជា ។

ទី២ គឺការបំបែកសូចនាករនិងរៀបចំទិន្នន័យគាំទ្រឲ្យបានគ្រប់គ្រាន់ ធ្វើដូចនេះមានសារៈសំខាន់ទាំងសម្រាប់តាមដានត្រួតពិនិត្យ នៃការអនុវត្ត គ.អ.ច.ក. ។ កត្តានេះមានសារៈសំខាន់ណាស់

សម្រាប់អ្នករៀបចំផែនការ អ្នករៀបចំគោលនយោបាយ និងអ្នកមានចំណែកពាក់ព័ន្ធដទៃទៀតអាចកំណត់ពីការប្រែប្រួលនៃតម្រូវការនិងការអនុវត្ត ដែលអាចជួយដល់ការវិភាជធនធាន និងការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព។ ដើម្បីធ្វើឲ្យទិន្នន័យមានប្រសិទ្ធភាពនិងមានប្រភពជាក់លាក់ ចាំបាច់ត្រូវមានសមត្ថភាពក្នុងការបំបែកទៅតាមបរិបទកម្ពុជាដែលស្របទៅតាមយុទ្ធសាស្ត្រជាតិអភិវឌ្ឍស្ថិតិ។

ទី៣ ការតាមដានសូចនាករ ត្រូវការការយកចិត្តទុកដាក់ពិសេស។ បទពិសោធនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា បានបង្ហាញថាទិន្នន័យសេដ្ឋកិច្ចសង្គមនិងបរិស្ថាន មិនមានការប្រែប្រួលតាមបន្ទាត់លីនេអ៊ែរ ជាក់លាក់នោះទេ។

# ជំពូកទី៤ : បញ្ហាប្រឈមក្នុងការអនុវត្ត គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា

## ៤.១- សេចក្តីផ្តើម

ជំពូកនេះ នឹងដោះស្រាយពីបញ្ហាប្រឈមដែលអាចជួបប្រទះនៅក្នុងការអនុវត្តក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា (គ.អ.ច.ក.) ហើយដែលចាំបាច់ត្រូវធ្វើការដោះស្រាយនៅក្នុងកំលុងពេលនៃការដាក់ឲ្យអនុវត្តក្នុងរយៈពេល១២ខែទៀត។ ដូចបានបញ្ជាក់នៅក្នុងជំពូកទី១ ការពិភាក្សាបានផ្តោតការយកចិត្តទុកដាក់លើវិធីសាស្ត្រ ដែលក្របខ័ណ្ឌ គ.អ.ច.ក. បានប្រើប្រាស់ដើម្បីតម្រង់ទិស រៀបចំ និងអនុវត្តគោលនយោបាយ ដើម្បីឈានទៅសម្រេចបាន ចក្ខុវិស័យរយៈពេលមធ្យមនិងវែងរបស់កម្ពុជា។ ដើម្បីសម្រេចបានគោលដៅនេះ ទាមទារឲ្យមានការពិនិត្យមើលឡើងវិញនូវឧបករណ៍និងស្ថាប័នដែលមានស្រាប់ និងផ្តោតការយកចិត្តទុកដាក់លើផ្នែកដែលគួរកែសម្រួល។

ជំពូកនេះបែងចែកជា៣ផ្នែក គឺ ទី១ បញ្ហាដែលបានជួបប្រទះក្នុងការធ្វើសមាហរណកម្ម គ.អ.ច.ក. ទៅក្នុងប្រព័ន្ធផែនការនិងគោលនយោបាយជាតិ ទី២ បញ្ហានានាពាក់ព័ន្ធនឹងធនធានសម្រាប់គាំទ្រការអនុវត្តនិងសកម្មភាពដែលត្រូវអនុវត្ត និងទី៣ ការរៀបចំការតាមដានត្រួតពិនិត្យនិងវាយតម្លៃរួមទាំងការធានានូវការទទួលយកនូវមតិយោបល់ឲ្យបានទូលំទូលាយពីការអនុវត្ត គ.អ.ច.ក. ពីអ្នកមានចំណែកពាក់ព័ន្ធមិនមែនរាជរដ្ឋាភិបាល។

## ៤.២- ការធ្វើសមាហរណកម្ម គ.អ.ច.ក. នៅក្នុង ប្រព័ន្ធផែនការនិងគោលនយោបាយជាតិ

ការធ្វើសមាហរណកម្ម គ.អ.ច.ក. ទៅក្នុងផែនការនិងគោលនយោបាយជាតិនានា និងដំណើរការរៀបចំវិភាជន៍ថវិកានៅកម្ពុជា អាចប្រឈមនឹងបញ្ហាចម្បងពីរ គឺ ទី១ ការធានាឲ្យមានសង្គតិភាពនិងភាពប្រទាក់ក្រឡាគ្នារវាង គ.អ.ច.ក. ជាមួយនឹងផែនការនិងសកម្មភាពត្រូវអនុវត្ត និង ទី២ ការកំណត់អាទិភាពនិងគោលនយោបាយដោយដាក់បញ្ចូលចំណុចដៅនៃ គ.អ.ច.ក.។

### ៤.២.១- សង្គតិភាពនិងភាពប្រទាក់ក្រឡាគ្នា

នៅថ្នាក់ជាតិ ភាពប្រទាក់ក្រឡាគ្នានៃ គ.អ.ច.ក. នឹងត្រូវបានអនុវត្តតាមរយៈពីរចំណុច៖ ទី១ តាមរយៈដំណើរការនៃការរៀបចំ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) ដែលជាយន្តការតែមួយគត់សម្រាប់អនុវត្តយុទ្ធសាស្ត្រចតុកោណ និង ទី២ តាមរយៈការពិនិត្យឡើងវិញនូវការអនុវត្តការផ្តល់សេវាកម្មនិងការឆ្លើយតប ដែលត្រូវបានលើកកម្ពស់តាមរយៈកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសការអនុមតិថវិកាកម្មវិធី។ ដំណើរការទាំងពីរនេះ ជាតួនាទីអាទិភាពរបស់ គ.អ.ច.ក. ដូចបង្ហាញនៅក្នុងរូបភាព ៤.១។

## រូបភាព ៤.១ : ចំណុចប្រសព្វជាមួយក្របខ័ណ្ឌនៃការរៀបចំផែនការ




ទី១ ការរៀបចំ ផ.យ.អ.ជ. (ក្នុងប្រអប់ទី១ រូបភាព ៤.១) បានគិតគូរច្បាស់លាស់ពី គ.អ.ច.ក. និង យុទ្ធសាស្ត្រចតុកោណ ដើម្បីកំណត់ពីយុទ្ធសាស្ត្រអាទិភាព ដែលនឹងត្រូវរៀបចំសម្រាប់ការអនុវត្ត នៅក្នុងកម្មវិធីវិនិយោគសាធារណៈ បីឆ្នាំរំកិល របស់រាជរដ្ឋាភិបាលកម្ពុជា។ បន្ថែមលើនេះទៀត គ.អ.ច.ក. ក៏នឹងដើរតួនាទីដ៏សំខាន់នៅក្នុងការពង្រឹងក្របខ័ណ្ឌនៃការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ផ.យ.អ.ជ.។

ទី២ គ.អ.ច.ក. អាចដើរតួនាទីច្បាស់លាស់ នៅក្នុងដំណើរការតាមដានត្រួតពិនិត្យការអនុវត្ត នៅពេលដែលការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា រៀបចំផែនការថវិកា និងបានតភ្ជាប់ទំនាក់ទំនងជាមួយផែនការយុទ្ធសាស្ត្រថវិកា ដែលជាការតភ្ជាប់គ្នារវាងគោលនយោបាយជាមួយថវិកា។ ចំណុចដៅ និង សូចនាកររបស់ គ.អ.ច.ក. មានលក្ខណៈសមស្របទៅនឹងភារកិច្ចក្នុងការវាយតម្លៃពីប្រសិទ្ធភាពដែលទទួលបានដោយផ្តល់នូវម៉ាទ្រីសកម្រិតលទ្ធផល ដែលមានប្រសិទ្ធភាព និងទទួលបានការឯកភាពពីក្រសួង ស្ថាប័ន។

ក្រសួងផែនការនឹងធ្វើការរៀបចំនិងកំណត់ក្រសួង ស្ថាប័នសម្រាប់អនុវត្តការងារនេះ។ ក្រសួងផែនការនឹងធានាថា ដំណើរការអនុវត្ត ផ.យ.អ.ជ. រយៈពេល៥ឆ្នាំ នឹងបង្ហាញនៅក្នុងរបាយការណ៍វឌ្ឍនភាពរបស់ គ.អ.ច.ក. ហើយវិស័យសំខាន់ៗនឹងបង្ហាញតាមរយៈ កម្មវិធីវិនិយោគសាធារណៈ។ បន្ថែមលើនេះ ម៉ាទ្រីសសម្រាប់តាមដានត្រួតពិនិត្យនិងវាយតម្លៃ ផ.យ.អ.ជ. នឹងត្រូវបានធ្វើបច្ចុប្បន្នភាព

ជាប្រចាំ ដើម្បីធានាសង្គតិភាព រវាង គ.អ.ច.ក. និង អាទិភាពរបស់ ផ.យ.អ.ជ.។ ក្រសួងផែនការនឹងសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀតដើម្បីដាក់ចេញនូវក្របខ័ណ្ឌនេះ សម្រាប់អនុវត្តដោយផ្អែកលើថវិកា របស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលតម្រូវឲ្យមានភាពច្បាស់លាស់សម្រាប់វាយតម្លៃចំណុចដៅនានានៃ គ.អ.ច.ក.។ ការងារនេះនឹងភ្ជាប់ទំនាក់ទំនងដោយផ្ទាល់ទៅនឹងលទ្ធផលនៃការអនុវត្ត គ.អ.ច.ក.។

ទោះជាដូចនេះក្តី ដើម្បីធានាសង្គតិភាពនិងភាពប្រទាក់ក្រឡាគ្នាឲ្យបានពេញលេញរវាង គ.អ.ច.ក. និងផែនការនិងសកម្មភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ទាមទារឱ្យមានការច្នៃប្រឌិតនិងកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត។ សមាសភាពចំនួនបីដែលត្រូវពិចារណាសម្រាប់កិច្ចខិតខំប្រឹងប្រែងនោះ គឺ៖

- សង្គតិភាពនៃពេលវេលា ដែលត្រូវបំប្លែងយុទ្ធសាស្ត្ររយៈពេលវែងឲ្យទៅជាគោលនយោបាយរយៈពេលមធ្យម និង សកម្មភាពសម្រាប់ការអនុវត្ត។
- សង្គតិភាពតាមវិស័យ ការអនុវត្តគោលដៅនិងនៅទូទាំងមុខងារ គឺមានសារៈសំខាន់ណាស់ដែលបានផ្តល់នូវការបញ្ចូលគ្នានូវលក្ខណៈរបស់ គ.អ.ច.ក. និង ការកែសម្រួលនិងការបំពេញបន្ថែម។
- ផ្អែកតាមលក្ខណៈភូមិសាស្ត្រ ដើម្បីផ្សារភ្ជាប់ផែនការជាតិ ផែនការតាមវិស័យនិងផែនការនៅថ្នាក់ក្រោមជាតិ។

### ៤.២.២- ការកំណត់អាទិភាព គោលដៅ ចំណុចដៅ និងសកម្មភាព

ការកំណត់អាទិភាព គឺជាការងារសំខាន់ ដែលត្រូវយកចិត្តទុកដាក់។ ផ្អែកលើទំហំនិងមហិច្ឆតារបស់ គ.អ.ច.ក. ចាំបាច់ត្រូវមានការកំណត់អាទិភាពកម្រិតគោលដៅ និង សក្តានុពលគោលដៅនីមួយៗ។ ការងារនេះ គឺជាផ្នែកមួយបន្ថែមពីលើការធ្វើមូលដ្ឋាននីយកម្ម គ.អ.ច.ក. ដែលទាមទារឲ្យមានភាពច្បាស់លាស់បន្ថែមទៀត តាមរយៈដំណើរការនៃការរៀបចំ ផ.យ.អ.ជ. យន្តការពិគ្រោះយោបល់និងការកំណត់ចំណុចដៅសំខាន់ៗរួមទាំងដំណោះស្រាយ។ ការណែនាំចំនួនបីសម្រាប់ដំណើរការនេះរួមមាន៖

- ទី១ ការមិនបោះបង់នរណាម្នាក់ឲ្យនៅឯកោនិងការដោះស្រាយទៅតាមគោលដៅ នៅតាមតំបន់ឬក្រុមនៃប្រជាជន ដែលមានកម្រិតជីវភាពទាបជាងក្រុមប្រជាជនផ្សេងទៀត គឺជាការគិតគូរខ្ពស់បំផុត។ គោលដៅនានានៃ គ.អ.ស.ក. ដែលមិនទាន់សម្រេចបាន ស្ថិតនៅក្នុងលក្ខខណ្ឌនេះ ហើយកម្ពុជានឹងផ្តោតការយកចិត្តទុកដាក់លើការធ្វើឲ្យប្រសើរឡើងនូវវិស័យណា ដែលពុំមានវឌ្ឍនភាពគ្រប់គ្រាន់ (បញ្ជីគោលដៅ ចំណុចដៅ មានបង្ហាញក្នុងជំពូកទី២)។ ការងារដែលត្រូវអនុវត្តបន្ត គឺ ការកំណត់អាទិភាពលើការលុបបំបាត់គម្លាតនិងវិសមភាពនៅតាមវិស័យ។
- ទី២ ការធ្វើឲ្យមានភាពសង្គតិភាពរវាងចំណុចដៅនានារបស់ គ.អ.ច.ក. គោលដៅដែលដាក់បញ្ចូលថ្មី និងគោលដៅមានស្រាប់របស់ជាតិ នឹងបង្កើតនូវមូលដ្ឋានគ្រឹះនៃវិធីសាស្ត្រសម្រាប់

កំណត់អាទិភាពទូទៅរបស់កម្ពុជា។ ការភ្ជាប់ទំនាក់ទំនងគ្នារវាងក្របខ័ណ្ឌ គ.អ.ច.ក. និងយុទ្ធសាស្ត្រចតុកោណ ដែលនឹងក្លាយជាក្របខ័ណ្ឌគោលនយោបាយសម្រាប់រៀបចំ ផ.យ.អ.ជ. នឹងផ្តល់អាទិភាពសម្រាប់ការអនុវត្ត។

**តារាង ៤.១ : ទំនាក់ទំនងរវាង គ.អ.ច.ក. និង អាទិភាព ផ.យ.អ.ជ.**

(ពណ៌ផ្ទៃមេឃចាស់ មានទំនាក់ទំនងដោយផ្ទាល់និងពណ៌ផ្ទៃមេឃ មានទំនាក់ទំនងផ្នែកខ្លះ)

| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ | ១៤ | ១៥ | ១៦ | ១៧ | ១៨ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| (១) ការកាត់បន្ថយភាពក្រីក្រ និងកំណើនប្រកបដោយបរិយាបន្ន | ● | ● | ○ | | ○ | ○ | | | | ● | | | | | | | | ○ |
| (២) ការពង្រីកវិស័យកសិកម្ម | ○ | ● | | | | | | | | ○ | | | | ○ | ○ | | | ○ |
| (៣) ការធានាឱ្យមានការប្រកួតប្រជែងកាន់តែច្រើន | | | | | | | ● | ● | ● | | ○ | | | | | | | |
| (៤) ការគ្រប់គ្រងការផ្លាស់ប្តូរទីលំនៅ និងនគរូបនីយកម្ម | | | | | | ● | | | | ○ | ● | | | | | | | |
| (៥) ការប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ និងការបាត់បង់ព្រៃឈើ | | | | | | | | | | | | ● | ● | ● | ● | | | |
| (៦) ធ្វើឱ្យប្រសើរឡើង អភិបាលកិច្ចល្អ | | | | | ○ | | | | | ○ | | | | | | ● | | |
| (៧) ធ្វើឱ្យប្រសើរឡើងធនធានមនុស្ស | | | ● | ● | ○ | | | ○ | | ○ | | | | | | | | |

ចំណាំ គោលដៅទី១៧ នៃ គ.អ.ច. ពាក់ព័ន្ធនឹងភាពជាដៃគូ

- ទី៣ ផ្អែកតាមបទពិសោធនិងការណែនាំពីកម្រិតសកល ការផ្តោតការយកចិត្តទុកដាក់គួរតែត្រូវបានធ្វើទៅលើសកម្មភាពដែលមានលក្ខណៈជាគោលនយោបាយ ដែលអាចដើរតួនាទីជា "ឧបករណ៍បង្កើនល្បឿន" (សកម្មភាពណាដែលអាចជំរុញឲ្យមានវឌ្ឍនភាព គ.អ.ច.ក. ទាំងមូល ដូចជា គោលនយោបាយវិសមភាពយេនឌ័រ និងការកែទម្រង់ការគាំពារសង្គមដ៏ទូលំទូលាយ)។

ការយល់ច្បាស់ពីបញ្ហាទាំងនេះ រួមជាមួយនឹងគោលដៅនិងគោលបំណងរបស់ជាតិ នឹងផ្តល់នូវមូលដ្ឋានរឹងមាំសម្រាប់ការកំណត់អាទិភាព ហើយក្រសួងផែនការនឹងអភិវឌ្ឍសមត្ថភាពរបស់ខ្លួនបន្ថែមទៀតសម្រាប់ធ្វើការវិភាគលើការអនុវត្តគោលដៅនានារបស់ គ.អ.ច.ក.។

## ៤.៣- ការផ្តល់ធនធាននិងការជ្រើសរើសគោលដៅ

ផ្នែកនេះ លើកឡើងពីការងារចាំបាច់និងការកៀរគរធនធាន ដើម្បីអនុវត្តឲ្យសម្រេចបាន គ.អ.ច.ក. ជាមួយនឹងសកម្មភាពដែលអាចធ្វើបាន។ ជាដំបូង ចាំបាច់ត្រូវបញ្ជាក់ឡើងវិញចំណុចឧស្សាហ៍ រវាង គ.អ.ច.ក និង គ.អ.ស.ក ដែលធនធានសម្រាប់អនុវត្ត គ.អ.ច.ក ជាបន្ទុករបស់រាជរដ្ឋាភិបាល និងជាធនធានកៀរគរពីប្រភពក្នុងស្រុក។ ដូចនេះដើម្បីសម្រេចបានគោលដៅ គ.អ.ច.ក. គឺត្រូវមាន

ការចូលរួមទទួលខុសត្រូវរបស់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ ដែលមិនត្រឹមតែរាជរដ្ឋាភិបាល ប៉ុន្តែរួមបញ្ចូលទាំង វិស័យឯកជន សង្គមស៊ីវិល និងប្រជាជនខ្លួនឯងផងដែរ។ ជាមួយគ្នានេះក៏ត្រូវទទួលស្គាល់ផងដែរថា កម្ពុជាកំពុងជួបប្រទះនឹងបញ្ហាប្រឈមនឹងការខ្វះខាតធនធាន ដើម្បីឈានទៅសម្រេចបានគោលដៅរបស់ គ.អ.ច.ក. និងចក្ខុវិស័យឆ្នាំ២០៣០ និង ឆ្នាំ២០៥០។ ក្នុងន័យនេះ ដើម្បីសម្រេចបានគោលដៅនិងចក្ខុវិស័យទាំងនេះ ទាមទារឲ្យមានការខិតខំវិនិយោគបន្ថែមទៀត និងការពង្រីកបន្ថែមប្រភពចំណូល ឬលំហូរធនធាន។

ការធ្វើចំណោលពីការវាយតម្លៃហិរញ្ញវត្ថុសម្រាប់ការអភិវឌ្ឍ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដោយមានការគាំទ្រពីកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ បានបង្ហាញថា ទោះបីជាកម្ពុជាមានសេដ្ឋកិច្ច និងស្ថានភាពសារពើពន្ធរឹងមាំ ជាពិសេស ការកើនឡើងនៃធនធានសាធារណៈក្នុងស្រុកក៏ដោយ ក៏បញ្ហាប្រឈមផ្នែកហិរញ្ញវត្ថុនៅតែអាចបន្តកើតមាន។ រូបភាព ៤.២ បង្ហាញថា ខណៈដែលចំណូលជាតិប្រមូលបាន លើសពី១៨% នៃ ផ.ស.ស. រួមទាំង កំណើន ផ.ស.ស. ដ៏រឹងមាំប្រចាំឆ្នាំលើសពី៧% ជំនួយអភិវឌ្ឍផ្លូវការ និងលំហូរជំនួយដល់អង្គការមិនមែនរដ្ឋាភិបាល នឹងមានការថយចុះជាលំដាប់។ នៅពេលអនាគតនឹងមានសម្ពាធលើចំណូលថវិកាចរន្ត ដែលបណ្តាលមកពីការកើនឡើងនៃការរំពឹងទុកជាមួយនឹងកំណើនតម្រូវការ ការបំពេញ បរិមាណជំនួយអភិវឌ្ឍដែលធ្លាប់ទទួលបាន និងការបង្កើនតម្រូវការវិនិយោគសាធារណៈ។

ការងារនេះទាមទារឲ្យមានការលើកកម្ពស់សមត្ថភាពនិងពង្រឹងយន្តការរៀបចំ ផ.យ.អ.ជ. ហើយក្រសួងផែនការនឹងធ្វើឲ្យកាន់តែប្រសើរឡើងនៃ ការវិភាគនិងការព្យាករពីហិរញ្ញវត្ថុ និងប្រភពចំណូលផ្សេងទៀត តាមរយៈការរៀបចំស្ថាប័នការវាយតម្លៃហិរញ្ញវត្ថុសម្រាប់ការអភិវឌ្ឍ និងការអភិវឌ្ឍសមត្ថភាពវិភាគរបស់មន្ត្រី។ ការងារនេះក៏ទាមទារឲ្យមានការពង្រឹងកម្មវិធីវិនិយោគសាធារណៈ ជាពិសេស បន្តកែទម្រង់ដើម្បីធានាឱ្យមានទំនាក់ទំនងកាន់តែខ្លាំងក្លាជាងមុនរវាងកម្មវិធីវិនិយោគសាធារណៈ និង ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ផែនការយុទ្ធសាស្ត្រថវិកាទៅជាការរៀបចំថវិកាកម្មវិធី។

ការព្យាកររបស់ស្ថាប័ន វាយតម្លៃហិរញ្ញវត្ថុសម្រាប់ការអភិវឌ្ឍ ក៏បានបង្ហាញថា លំហូរចំណូលដែលមានប្រភពពីវិស័យឯកជន (ការវិនិយោគពីក្នុងនិងក្រៅប្រទេស) នឹងមានការកើនឡើងស្របគ្នាជាមួយកំណើនសេដ្ឋកិច្ច ដែលចំណែកនៃលំហូរនេះនៅក្នុងផលិតផលក្នុងស្រុកសរុប នឹងបន្តមានស្ថិរភាពដដែល។ លំហូរទាំងនេះ នៅតែមានសារៈសំខាន់ណាស់សម្រាប់រក្សាកំណើនសេដ្ឋកិច្ច និងធានាអន្តរកាលរបស់កម្ពុជា ទៅជាប្រទេសផលិតកម្មមានតម្លៃបន្ថែមខ្ពស់។ កំណើនសេដ្ឋកិច្ច នៅតែជាកត្តាចម្បងសម្រាប់ការកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់បរិយាបន្នសេដ្ឋកិច្ច និងផ្តល់ផងមធ្យោបាយសម្រាប់ទទួលបាននូវចំណូលពន្ធខ្ពស់ ដែលផ្តល់ផលប្រយោជន៍ក្នុងការលើកកម្ពស់ការផ្តល់សេវាសាធារណៈ។ ដូចនេះ ការជំរុញការវិនិយោគពីប្រភពនេះ គឺជាកត្តាគន្លឹះដូចបានរំលេចនៅក្នុង

គ.អ.ច.ក.។ រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តជំរុញឲ្យមានការវិនិយោគដែលមិនប៉ះពាល់ដល់បរិស្ថាន ស្របនឹងការបន្តធ្វើឲ្យប្រសើរឡើងនូវប្រសិទ្ធភាពនៃប្រព័ន្ធប្រមូលពន្ធ។

**រូបភាព ៤.២ : ចំណោលលំហូរហិរញ្ញវត្ថុ ដល់ឆ្នាំ២០២៥ (សេណារីយ៉ូ ទាបនិងខ្ពស់)**




| | |
|---|---|
| ចំណូលក្នុងស្រុក | កិច្ចសហប្រតិបត្តិការត្បូង ត្បូង |
| ការវិនិយោគឯកជនក្នុងស្រុក | ប្រាក់ដែលផ្ញើមកពីបរទេស |
| ការវិនិយោគផ្ទាល់ពីបរទេស | ថវិកាសម្រាប់អង្គការមិនមែនរដ្ឋាភិបាល |
| ជំនួយអភិវឌ្ឍផ្លូវការ | ហិរញ្ញវត្ថុសម្រាប់ការងារប្រែប្រួលអាកាសធាតុ |

ប្រភព : រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០១៧

រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់ការចូលរួមចំណែករបស់វិស័យឯកជន និងបានផ្ដល់ឱកាសធ្វើអាជីវកម្មដល់សង្គមស៊ីវិលនិងប្រជាជន ដើម្បីឈានទៅសម្រេចបាន គ.អ.ច.ក.។ ការងារនេះនឹងរួមបញ្ចូលការជំរុញនិងការលើកទឹកចិត្ត ព្រមទាំងការផ្លាស់ប្ដូរឥរិយាបថក្នុងការផលិតនិងការប្រើប្រាស់ស្របតាមបរិបទ "សេដ្ឋកិច្ចបៃតង" ហើយរាជរដ្ឋាភិបាលកម្ពុជានឹងផ្ដល់ការលើកទឹកចិត្តផ្នែកពន្ធនិងផ្នែកមិនមែនពន្ធផ្សេងៗទៀត។ បន្ថែមលើនេះទៀត ការសម្របសម្រួលភាពជាដៃគូរវាងរដ្ឋាភិបាលនឹងវិស័យឯកជន ក៏នឹងចូលរួមចំណែកក្នុងការ សម្រេច គ.អ.ច.ក.។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងរៀបចំគោលនយោបាយជាតិសម្រាប់ភាពជាដៃគូរវាងរដ្ឋាភិបាលនឹងវិស័យឯកជន ព្រមទាំងកែសម្រួលលិខិតបទដ្ឋានចាំបាច់មួយចំនួន ដែលទាក់ទងនឹងនីតិវិធីអនុវត្តភាពជាដៃគូរវាងរដ្ឋាភិបាល និង វិស័យឯកជន ដូចជាភាពជាដៃគូតាមទម្រង់ សាងសង់ ដំណើរការ និងផ្ទេរ ជាដើម[6]។

ជាចុងក្រោយ ការពិភាក្សានិងការឆ្លើយតបតាមរយៈគោលនយោបាយដែលបានស្នើឡើងបានដោះស្រាយតែផ្នែកលំហូរហិរញ្ញវត្ថុ។ ទន្ទឹមនឹងនោះ ការទទួលបានលទ្ធផល ក៏តម្រូវឱ្យមានការអភិវឌ្ឍសមត្ថភាព និងឧបករណ៍នានា ដើម្បីពិនិត្យនិងប៉ាន់ស្មានការចំណាយ ដើម្បីឲ្យសម្រេចបាន

[6] ក្នុងកំណត់បង្ហាញគោលនយោបាយ ភាពជាដៃគូរវាងផ្នែកឯកជននិងរដ្ឋរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គ.អ.ច.ក.។ ទិន្នន័យភាគច្រើនរបស់ក្របខ័ណ្ឌ គ.អ.ច.ក. គឺបានផ្តល់សម្រាប់តែការចាប់ផ្តើមដំបូង ដែលទាមទាឱ្យយើង ធ្វើការវិភាគបន្ថែមទៀតពីនិន្នាការ និងតម្រូវការក្នុងពេលអនាគត។

បទពិសោធ លើការប៉ាន់ស្មានចំណាយរបស់ គ.អ.ស. កន្លងមក បានបង្ហាញពីភាពទន់ខ្សោយនៃការកំណត់ចំណាយរបស់អន្តរវិស័យក្នុងរយៈពេលវែង។ ការកំណត់នេះ ជាទូទៅ បានផ្តល់នូវចំហាក(សេណារីយ៉ូ)មិនច្បាស់លាស់ សម្រាប់ការចំណាយនិងការកំណត់តម្លៃសម្រាប់ធនធាន និងផែនការសារពើពន្ធ។ លើសពីនេះទៀត បញ្ហាប្រឈមទាំងនេះ ទំនងជាត្រូវបានផ្តោតការយកចិត្តទុកដាក់តាមរយៈការពង្រឹកគោលដៅ និងគោលបំណងអភិវឌ្ឍបើកទូលាយប្រកបដោយបរិយាបន្ន។ ទោះជាយ៉ាងនេះក្តី សម្ពាធនៃការគ្រប់គ្រងនិងការប៉ាន់ស្មានសារពើពន្ធ នៅមានសារៈសំខាន់ ហើយបច្ចេកទេសនិងវិធីសាស្ត្រថ្មី នឹងត្រូវបានអនុវត្តសាកល្បង ដោយរដ្ឋាភិបាលប្រទេសមួយចំនួន ដូចជា បង់ក្លាដេស និងអេត្យូពី ជាដើម។ ក្រសួងផែនការនឹងពិនិត្យពិចារណានិងជ្រើសគំរូទាំងនេះ រួមទាំងការប្រើប្រាស់ការវាយតម្លៃសារពើពន្ធនិងផ្តោតលើវិស័យជាក់លាក់ និងកំណត់ពេលវេលាវែងជាងមុន (ដោយផ្សារភ្ជាប់ការរៀបចំថវិកា កម្មវិធី និងផែនការយុទ្ធសាស្ត្រថវិកា)។

## ៤.៤- ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ និងការផ្តល់យោបល់ផ្នែកគោលនយោបាយ

ផ្នែកនេះបានកំណត់នូវសមាសភាគសំខាន់ៗនៃការរៀបចំការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ គ.អ.ច.ក. និងសង្ខេបពីបញ្ហានានាដែលនឹងត្រូវបានដោះស្រាយ។ ការទទួលស្គាល់វិធីសាស្ត្រវាយការណ៍បែបទំនើបនានា ហើយការសម្រេចបាន គ.អ.ច.ក. ហាក់បីដូចជាលើសពីសមត្ថភាពរបស់រាជរដ្ឋាភិបាល ទើបផ្នែកនេះក៏ធ្វើការពិភាក្សាលើការតាមដានត្រួតពិនិត្យនិងវាយតម្លៃប្រព័ន្ធអេកូឡូស៊ី។ ការងារនេះ អាចត្រូវបានផ្តល់តួនាទីដល់ស្ថាប័នឯករាជ្យសម្រាប់ផ្តល់មតិយោបល់ ហើយវិស័យឯកជន និងសង្គមស៊ីវិល ក៏អាចចូលរួមបានដែរ។

### ៤.៤.១- សមាសភាគសំខាន់ៗក្នុងការរៀបចំការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ការទទួលខុសត្រូវរួមសម្រាប់ដំណើរការតាមដានត្រួតពិនិត្យនិងវាយតម្លៃថ្នាក់ជាតិ ជាភារកិច្ចរបស់ក្រសួងផែនការ ដែលទទួលបន្ទុកក្នុងការផ្តល់ទិន្នន័យមូលដ្ឋាននិងដើរតួនាទីជាអ្នកសម្របសម្រួលផ្នែកបច្ចេកទេស។ តួនាទីនេះ នឹងរួមបញ្ចូលទាំងការប្រមូលចងក្រងទិន្នន័យ និងផ្តល់នូវការកំណត់ចំណុចដៅប្រចាំឆ្នាំ និងរៀងរាល់៥ឆ្នាំ សម្រាប់វាយតម្លៃវឌ្ឍនភាពនៃការសម្រេចបានរបស់ គ.អ.ច.ក. ដោយក្រសួងផែនការនិងរាជរដ្ឋាភិបាលកម្ពុជា។ ក្រសួងផែនការទទួលខុសត្រូវការងារបច្ចេកទេស និងរួមទាំងការផ្តល់មតិយោបល់ដល់ភាគីពាក់ព័ន្ធជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការរៀបចំការប៉ាន់ស្មាន និងការគណនាតម្លៃរបស់សូចនាករនីមួយៗ ការប្រមូលទិន្នន័យ និងនីតិវិធីរាយការណ៍។

ក្រសួង ស្ថាប័ន គឺជាអ្នកទទួលខុសត្រូវចំពោះសូចនាកររបស់ខ្លួន និងការផ្តល់ទិន្នន័យគាំទ្រ។ សមត្ថភាពនិងប្រព័ន្ធទិន្នន័យរបស់ក្រសួងស្ថាប័នទាំងនោះ នឹងត្រូវពង្រឹងតាមរយៈយុទ្ធសាស្ត្រជាតិ

អភិវឌ្ឍស្ថិតិ ដែលវាជាការបំពេញបន្ថែមដ៏សំខាន់ សម្រាប់តាមដានត្រួតពិនិត្យ គ.អ.ច.ក.។ ក្របខ័ណ្ឌ គ.អ.ច.ក. ដែលបានណែនាំនៅក្នុងជំពូកទី៣នៃផ្នែកទី១ និងដែលបានបង្ហាញនៅក្នុងតារាងទី១ និង តារាងទី២ នៃផ្នែកទី២ របស់ឯកសារនេះបានផ្តល់នូវសូចនាករ ប្រភព និងវដ្តទិន្នន័យ ដែលត្រូវបាន កំណត់ថាមានការគាំទ្រ។ តួអង្គទទួលខុសត្រូវនានា តម្រូវឲ្យធ្វើបច្ចុប្បន្នកម្មទិន្នន័យ និង រាយការណ៍ ប្រចាំឆ្នាំមកក្រសួងផែនការ ។ ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវធ្វើការវាយតម្លៃពីវឌ្ឍនភាពនៃចំណុចដៅរួម ទាំង សូចនាករដែលពាក់ព័ន្ធនឹងវិស័យខ្លួនលើទិដ្ឋភាពបីដូចខាងក្រោម៖

- ការសម្រេចបានលើសចំណុចដៅ ដែលបានកំណត់ យ៉ាងតិច១០%
- កំពុងស្ថិតក្នុងទិសដៅឆ្ពោះទៅរកការសម្រេចបានចំណុចដៅដែលបានគ្រោងទុក ក្នុងតម្លៃទាប ជាង ឬមិនលើសពី១០%។
- កំពុងស្ថិតក្នុងគន្លងខុសពីទិសដៅដែលបានកំណត់ ក្នុងកម្រិតប្រមាណ១០%។

សម្រាប់ទិដ្ឋភាពនីមួយៗ ត្រូវមានការបកស្រាយ ហើយក្នុងលក្ខខណ្ឌចាំបាច់ ត្រូវស្នើឡើងនូវ ដំណោះស្រាយចំពោះសូចនាករដែលមិនសម្រេចបាននោះ។ ក្រសួងផែនការនឹងប្រើប្រាស់វិធីសាស្ត្រ គ្រប់គ្រងតាមតារាង (dashboard) ក្នុងការរៀបចំរបាយការណ៍ នៅកម្រិតចំណុចដៅ និងគោលដៅ ដើម្បីឲ្យការវាយតម្លៃពីវឌ្ឍនភាពដំណើរការបានឆាប់រហ័ស តាមរយៈការកំណត់ចំណុចដៅពណ៌បៃតង ពណ៌លឿង និងពណ៌ក្រហម ដោយផ្អែកលើទិន្នន័យនៃសូចនាករ។ សំណើណាមួយសម្រាប់កែប្រែ តម្លៃមូលដ្ឋាន ចំណុចដៅ ឬចំណុចដៅចុងក្រោយ នឹងទាមទារឲ្យមានការ ឯកភាពពីក្រសួងផែនការ ហើយសំខាន់ជាងនេះ ចំណុចដៅនឹងមិនត្រូវបានផ្លាស់ប្តូរញឹកញាប់ទេ ហើយតម្លៃត្រូវបានកំណត់ យ៉ាងហ្មត់ចត់ព្រមទាំងផ្សារភ្ជាប់ទៅនឹង ទិសដៅនៃក្របខ័ណ្ឌ គ.អ.ច.ក.។

ដូចមានចែងក្នុងជំពូកទី៣ បញ្ហាមួយចំនួនពាក់ព័ន្ធនឹងទិន្នន័យ ចាំបាច់ត្រូវដោះស្រាយនៅ ក្នុងដំណាក់កាលបន្ទាប់ ហើយនឹងត្រូវបានតាមដានត្រួតពិនិត្យដោយក្រសួងផែនការ ក្នុងរយៈពេល ៣ខែបន្ទាប់។ ក្រសួងផែនការនឹងផ្តល់ការបណ្តុះបណ្តាលស្តីពីទិន្នន័យសម្រាប់សូចនាករ គ.អ.ច.ក ដល់ក្រសួង ស្ថាប័ន។

បន្ថែមលើនេះទៀត ជាមួយនឹងការគាំទ្រពីដៃគូអភិវឌ្ឍ នៅក្នុងរយៈពេល១២ខែបន្ទាប់ ក្រសួងផែនការនឹងរៀបចំការពិនិត្យមើលឡើងវិញនូវសូចនាករនៅតាមគោលដៅនីមួយៗ ដើម្បីជានា គុណភាព ជាពិសេស ការបំពេញតាមលក្ខខណ្ឌ SMART។ ក្រសួងផែនការក៏នឹងផ្តល់នូវការកសាង សមត្ថភាព ជាបន្តបន្ទាប់ដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងពិចារណាផ្តល់នូវការគាំទ្របច្ចេកទេសក្នុងការ ប្រមូលទិន្នន័យសម្រាប់សូចនាករដែលមិនមានទិន្នន័យគាំទ្រ។ បន្ទាប់មកទៀត នឹងផ្តល់អាទិភាពដល់ សូចនាករដែលត្រូវបានកំណត់ នៅក្នុងការវាយតម្លៃរបស់អង្គភាពស្ថិតិរបស់អង្គការសហប្រជាជាតិ។ ការងារនេះ នឹងស្របគ្នាជាមួយវិធីសាស្ត្រដែលបានកំណត់នៅក្នុងផែនការមេរបស់វិទ្យាស្ថានជាតិស្ថិតិ។

### ៤.៤.២- ការធ្វើឲ្យប្រសើរឡើង ការតាមដានត្រួតពិនិត្យនិងវាយតម្លៃប្រព័ន្ធអេកូឡូស៊ី គ.អ.ច.ក.

ដើម្បីផ្តល់នូវវិសាលភាពទូលំទូលាយដល់ គ.អ.ច.ក. និងទាមទារឲ្យមានការរួមចំណែកពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ក្នុងការសម្រេចបានគោលដៅនេះ រាជរដ្ឋាភិបាលកម្ពុជានឹងផ្តល់ការគាំទ្រចំពោះការផ្តល់មតិយ៉ាងទូលំទូលាយលើ "ប្រព័ន្ធអេកូឡូស៊ី" និងធ្វើឲ្យមានទំនាក់ទំនងជាមួយវិស័យឯកជន សង្គមស៊ីវិលនិងអង្គការអន្តរជាតិ។ ប្រព័ន្ធអេកូឡូស៊ីនេះសំដៅលើបរិស្ថាន(ប្រជាជន ទំនាក់ទំនង និងធនធាន) ដែលទិន្នន័យត្រូវបានបង្កើតឡើងនិងប្រើប្រាស់ដោយរដ្ឋាភិបាលនិងភាគីពាក់ព័ន្ធនានា សម្រាប់គាំទ្រការធ្វើសេចក្តីសម្រេចចិត្តដើម្បីសម្រេចបាន គ.អ.ច.ក.។

ក្នុងករណីនេះ ការអនុវត្តបានធ្វើរួចហើយក្នុងដំណាក់កាល គ.អ.ស.ក. ហើយបានដាក់នៅក្នុងយុទ្ធសាស្ត្រជាតិអភិវឌ្ឍន៍ប្រព័ន្ធស្ថិតិ។ ក្រសួងផែនការនឹងពិចារណាបន្តអនុវត្តនូវសកម្មភាពដូចខាងក្រោម៖

- យុទ្ធសាស្ត្រថ្នាក់ជាតិមួយសម្រាប់លើកកម្ពស់ការចូលរួមពីភាគីពាក់ព័ន្ធសំខាន់ៗនិងសាធារណជនទូទៅនៅកម្ពុជាក្នុងការធ្វើឲ្យសម្រេចបាន គ.អ.ច.ក. ជាមួយនឹងការធ្វើទំនាក់ទំនងសម្រាប់ការផ្តួចផ្តើមអភិវឌ្ឍ ដើម្បីលើកទឹកចិត្តដល់ការតាមដានត្រួតពិនិត្យដោយអនុលោមតាមគោលដៅទាំងនេះ សម្រាប់ធ្វើឲ្យប្រសើរឡើងឥរិយាបថរបស់អ្នកផលិតនិងអ្នកប្រើប្រាស់។ វិធីសាស្ត្រនេះនឹងអាចប្រើប្រាស់ទាំងប្រព័ន្ធផ្សព្វផ្សាយសម័យទំនើបនិងប្រព័ន្ធផ្សព្វផ្សាយប្រពៃណី។
- ការចូលរួមជាក្នុងអាជីវកម្មនិងតំណាងវិស័យឯកជន ដើម្បីរៀបចំនិងលើកទឹកចិត្តដល់ការរួមចំណែកធ្វើឲ្យសម្រេចបាន គ.អ.ច.ក. ។
- ការរៀបចំគោលនយោបាយសម្រាប់ គ.អ.ច.ក. និងបណ្តាញនៅក្នុងតំបន់ ជាមួយនឹងស្ថាប័នផ្តល់មតិយោបល់ និងអ្នកមានចំណែកពាក់ព័ន្ធជាសង្គមស៊ីវិលផ្សេងទៀត ដោយផ្អែកលើវិស័យទាំងនេះ ដែលបានកំណត់ខាងលើ ក្នុងការរៀបចំកិច្ចពិគ្រោះយោបល់ជាតិស្តីពី គ.អ.ច.ក.។
- ការចែករំលែកទិន្នន័យផ្លូវការនិងការរៀបចំប្រព័ន្ធអនឡាញ គឺអនុញ្ញាតឲ្យអ្នកប្រើប្រាស់ព័ត៌មានរួមទាំងប្រជាជនទូទៅ ចូលរួមក្នុងការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ស្រាវជ្រាវ និងចូលរួមក្នុងការពិគ្រោះយោបល់ថ្នាក់ជាតិស្តីពី គ.អ.ច.ក.។

# ជំពូកទី ៥ : សេចក្តីសន្និដ្ឋាននិងអនុសាសន៍

ឯកសារនេះបានណែនាំនិងពិនិត្យមើលឡើងវិញនូវ ក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា (គ.អ.ច.ក.)ដែលបានស្នើឡើងដោយរាជរដ្ឋាភិបាលកម្ពុជា។ ឯកសារនេះក៏បានរាយការណ៍អំពីបរិបទជាតិនិងការអនុវត្តក្រោមការដឹកនាំរបស់ គ.អ.ច.ក. ដែលពាំនាំនូវបទពិសោធនិងការយល់ដឹងស៊ីជម្រៅ។ វាគូសបញ្ជាក់អំពីដំណើរការអភិវឌ្ឍ កំណត់ក្របខ័ណ្ឌដែលបានស្នើឡើង និងកំណត់នូវបញ្ហាដែលនៅសេសសល់ ហើយក៏ពិចារណាផងដែរលើបញ្ហាប្រឈមចំពោះមុខក្នុងការអនុវត្តក្របខ័ណ្ឌ។ ជំពូកចុងក្រោយនេះសង្ខេបពីការសន្និដ្ឋានគន្លឹះនិងបង្ហាញពីគោលនយោបាយនិងវិធានការសម្រាប់អនុវត្តរយៈពេលខ្លី មធ្យម និងវែង។

## ៥.១- ការសន្និដ្ឋានគន្លឹះ

ជាដំបូងឯកសារនេះ បង្ហាញអំពីក្របខ័ណ្ឌ គ.អ.ច.ក. ដែលមានគោលដៅចំនួន១៨ ចំណុចដៅចំនួន៨៨ និងសូចនាករចំនួន១៤៨ ដែលនឹងត្រូវអនុវត្តដោយរាជរដ្ឋាភិបាលកម្ពុជា។ គោលបំណងជាបណ្តោះអាសន្ននៃក្របខ័ណ្ឌនេះគឺដើម្បីជាធាតុចូលសម្រាប់ការរៀបចំ ***ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ (ផ.យ.អ.ជ. ២០១៩- ២០២៣)***។

ក្របខ័ណ្ឌ គ.អ.ច.ក. កើតចេញពីការធ្វើមូលដ្ឋាននីយកម្ម គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពសកល ទៅក្នុងបរិការណ៍ជាតិដោយបន្ថែមគោលដៅចំនួនមួយថ្មី ស្តីពីការបោសសម្អាតមីននិងយុទ្ធភណ្ឌមិនទាន់ផ្ទុះសល់ពីសង្គ្រាម ព្រមទាំងរក្សាទុកចំណុចដៅសកលប្រមាណ៧៥% ដែលពាក់ព័ន្ធនឹងកម្ពុជា។ កង្វះខាតទិន្នន័យគាំទ្រសូចនាករដែលមាន មានប្រហែលតែ៣០%-៤០% ប៉ុណ្ណោះនៃប្រព័ន្ធទិន្នន័យសកលដែលអាចរកបាន ហើយក្រៅពីនោះគួរត្រូវដោះស្រាយតាមរយៈការអនុវត្តជម្រើសបែបជំនួស(ប្រុកស៊ី) និងជម្រើសសាកល្បង ដើម្បីធានាការគ្របដណ្តប់ទិន្នន័យឲ្យបានគ្រប់គ្រាន់លើគោលដៅនិងចំណុចដៅ។ ទោះជាដូចនេះក្តី រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ថា គម្លាតទិន្នន័យនឹងត្រូវបំពេញ ហើយចំណុចខ្វះខាតមួយចំនួននឹងត្រូវដោះស្រាយក្នុងពេលខាងមុខ រួមជាមួយការខិតខំប្រឹងប្រែងបន្ថែមទៀតដើម្បីធ្វើឲ្យប្រសើរឡើងនូវគុណភាពសូចនាករ និងទិន្នន័យគាំទ្រសូចនាករ។

ការវិភាគអំពីការស្ថានភាព សង្គមសេដ្ឋកិច្ចកម្ពុជា និងលទ្ធផលនៃការសម្រេចបាន គ.អ.ស.ក. បានបង្ហាញពីភាពរឹងមាំនៃការអភិវឌ្ឍជាតិ ប៉ុន្តែប្រទេសកម្ពុជាប្រឈមមុខនឹងបញ្ហា ថ្មីៗជាច្រើន រួមទាំងបរិយាកាសអភិវឌ្ឍន៍ដែលកំពុងតែប្រែប្រួលយ៉ាងឆាប់រហ័ស។ ប្រការនេះមានសារៈសំខាន់ណាស់ នៅពេលដែលប្រទេសកម្ពុជាបន្តរីកចម្រើនក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាបតាមរយៈការដាក់ចេញនូវផែនការនិងគោលនយោបាយនានា សំដៅធានាបាននូវកំណើនសេដ្ឋកិច្ច

ខ្ពស់ប្រកបដោយបរិយាបន្ន។ កម្ពុជាក៏ត្រូវលើកកម្ពស់ការអភិវឌ្ឍសង្គមឲ្យកាន់តែទូលំទូលាយ ថែមទាំងការពារបរិស្ថាន ធនធានធម្មជាតិ ផងដែរ។ បញ្ហាប្រឈមចម្បងមួយគឺការកើនឡើងនូវភាពងាយរងគ្រោះទាំងសេដ្ឋកិច្ចនិងបរិស្ថាន។ ដូចបណ្តាប្រទេសដែលមានចំណូលមធ្យមកម្រិតទាបដែរ ប្រទេសកម្ពុជាបាននិងកំពុងប្រឈមនឹងសម្ពាធជាច្រើនរួមមាន៖ ឧស្សាហូបនីយកម្ម នគរូបនីយកម្មចំណាកស្រុក និងភាពទន់ខ្សោយនៃសេវាសាធារណៈ។ គ.អ.ច.និងគ.អ.ច.ក. ចង្អុលបង្ហាញនូវក្របខ័ណ្ឌជាមូលដ្ឋានដែលគ្របដណ្តប់យ៉ាងទូលំទូលាយនូវកម្រិតនៃការធ្វើសមាហរណកម្ម នាំមកនូវការរីកចម្រើននិងផ្តល់ការណែនាំដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមនៃការអភិវឌ្ឍ។

គ.អ.ច.ក. មានការគិតគូរច្បាស់លាស់ក្នុងការដាក់បញ្ចូលគោលដៅនៅក្នុងដំណើរការរៀបចំផែនការជាតិ។ ដូច្នេះ ទំនាក់ទំនងរវាង គ.អ.ច.ក. និង ផ.យ.អ.ជ. គួរត្រូវពង្រឹងបន្ថែមទៀត។ លើសពីនេះទៀត ក៏មានសារៈសំខាន់ផងដែរក្នុងការតភ្ជាប់ គ.អ.ច.ក. ទៅនឹងការធ្វើផែនការនិងថវិកា ហើយប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ត្រូវពង្រឹងបន្ថែមនិងរៀបចំក្របខ័ណ្ឌស្ថាប័ន ដោយដាក់បញ្ចូលក្នុងកម្មវិធីការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ចំណុចនេះរាប់បញ្ចូលទាំងការកំណត់ចំណុចដៅជាក់លាក់របស់ គ.អ.ច.ក. ដែលអាចវាស់វែងលទ្ធផលនៅក្នុងផែនការយុទ្ធសាស្ត្រថវិកា។

គោលដៅរបស់ គ.អ.ច.ក. នឹងត្រូវធ្វើការត្រួតពិនិត្យកាន់តែច្បាស់ជាង គ.អ.ស.ក. ដែលអនុញ្ញាតឲ្យមិនត្រឹមតែសម្រាប់ការរាយការណ៍ពីវឌ្ឍនភាពប៉ុណ្ណោះទេ ថែមទាំងសម្រាប់ឆ្លុះបញ្ចាំងពីគោលនយោបាយនិងការឆ្លើយតបនានាប្រកបដោយប្រសិទ្ធភាពផងដែរ។

ការកំណត់អាទិភាពបានបង្ហាញច្បាស់ថា មិនមែនគ្រប់គោលដៅទាំងអស់របស់ គ.អ.ច.ក. អាចនឹងត្រូវបញ្ចប់ក្នុងពេលដំណាលគ្នានោះទេ ហើយនៅក្នុងករណីជាច្រើនការអនុវត្តប្រកបដោយប្រសិទ្ធភាព ត្រូវទាមទារឲ្យមានការរៀបចំគោលនយោបាយនិងសកម្មភាពនានា តាមដំណាក់កាល។ ខណៈពេលដែលអាទិភាពត្រូវបានកំណត់ ការមិនបោះបង់នរណាម្នាក់ឲ្យនៅឯកោ និងការបំពេញគោលដៅ គ.អ.ស.ក. ដែលមិនទាន់សម្រេចនៅជាអាទិភាពខ្ពស់បំផុត និងត្រូវការគិតគូរបន្ថែមទៀតក្នុងរយៈពេលមធ្យម។ ការផ្ទៀងផ្ទាត់ជាមួយនឹងអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជាដែលមានស្រាប់ក្នុង ផ.យ.អ.ជ. និងផែនការតាមវិស័យ ផ្តល់នូវមូលដ្ឋានរឹងមាំ ប៉ុន្តែការពិចារណាលើទំនាក់ទំនងរវាងគោលដៅនិងការកំណត់ល្បឿន គឺជាវិធីសាស្ត្រអាទិភាពមួយដ៏មានប្រសិទ្ធភាព។

សរុបរួមមក ដើម្បីសម្រេចគោលដៅរបស់ គ.អ.ច.ក. ទាមទារឲ្យមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីធានានូវការកំណត់ធនធានឲ្យមានភាពច្បាស់លាស់ តាមរយៈការកំណត់តួនាទីស្ថាប័នវាយតម្លៃហិរញ្ញវត្ថុសម្រាប់ការអភិវឌ្ឍ ព្រមទាំងធានានូវសង្គតិភាពទៅនឹងការរៀបចំគម្រោងកម្មវិធីវិនិយោគសាធារណៈ និងទុនវិនិយោគ។

## ៥.២- ជំហានបន្ទាប់

### *នៅក្នុងរយៈពេលខ្លី ៣-៦ខែ*

- ក្របខ័ណ្ឌ គ.អ.ច.ក. នឹងត្រូវបានអនុមតិដោយគណៈរដ្ឋមន្ត្រី សម្រាប់ការអនុវត្ត។
- ការផ្សារភ្ជាប់ គ.អ.ច.ក. ទៅនឹង ផ.យ.អ.ជ. ត្រូវរៀបចំដោយក្រសួងស្ថាប័ន ដោយផ្អែកលើចំណុចដៅរបស់ គ.អ.ច.ក. ដែលមាននៅក្នុងក្របខ័ណ្ឌតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្ត ផ.យ.អ.ជ.។ ការពិនិត្យមើលវឌ្ឍនភាពរបស់ គ.អ.ច.ក. ក្នុងរយៈពេល៥ឆ្នាំម្តង ត្រូវមានសង្គតិភាពជាមួយនឹងវដ្តរបស់ ផ.យ.អ.ជ.។
- ការផ្សារភ្ជាប់ទៅនឹងការរៀបចំថវិកា គឺត្រូវដាក់បញ្ចូលចំណុចដៅនានារបស់ គ.អ.ច.ក. នៅក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង ស្ថាប័ន។ ដំណើរការនេះត្រូវរៀបចំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួងផែនការ។

### *នៅក្នុងរយៈពេលមធ្យម ៦-១២ខែ*

- ក្រសួងផែនការ ត្រូវពិនិត្យគោលដៅនីមួយៗ ឡើងវិញដើម្បីធានាថា សូចនាករ និងទិន្នន័យមានគ្រប់គ្រាន់សម្រាប់ គ.អ.ច.ក. និង បំពេញតាមលក្ខខណ្ឌ SMART។
- កិច្ចខិតខំប្រឹងប្រែងត្រូវបានធ្វើឡើងដើម្បីធានាឲ្យមានសង្គតិភាពរវាង គ.អ.ច.ក. តាមវិស័យនិងគ្រប់កម្រិត ដើម្បីរៀបចំរបាយការណ៍និងការដោះស្រាយបញ្ហាប្រឈម។
- លើកសំណើដើម្បីកំណត់អាទិភាពនិងកំណត់ដំណាក់កាលនៃចំណុចដៅសម្រាប់ ការតាមដានត្រួតពិនិត្យ។ ការមិនបោះបង់នរណាម្នាក់ឲ្យនៅឯកោ ឬ ការងាររបស់ គ.អ.ស.ក. ដែលមិនទាន់សម្រេចបានតាមគោលដៅ គឺជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជាដែលមានស្រាប់ពីមុន និងជាសក្តានុពលដើម្បីបង្កើនល្បឿន។
- ដំណើរការតាមដានត្រួតពិនិត្យនិងវាយតម្លៃ គ.អ.ច.ក. ត្រូវបានកែលម្អជាបន្តបន្ទាប់ស្របតាមការលើកឡើងរបស់អង្គភាពស្ថិតិរបស់អង្គការសហប្រជាជាតិ។

### *ក្នុងរយៈពេលវែង១២ខែ*

- ការគ្រប់គ្រងធនធានដើម្បីសម្រេចគោលដៅ គ.អ.ច.ក. ត្រូវបានអនុវត្តជាលក្ខណៈប្រព័ន្ធតាមរយៈរធ្វើរបាយការណ៍វាយតម្លៃហិរញ្ញវត្ថុសម្រាប់ការអភិវឌ្ឍ (ជាការវាយតម្លៃហិរញ្ញវត្ថុរបស់ គ.អ.ច.ក.) ដែលបានអនុវត្តជាទៀងទាត់ពី៣ទៅ៥ឆ្នាំ ដោយភ្ជាប់ទៅនឹង ផ.យ.អ.ជ. កម្មវិធីវិនិយោគសាធារណៈ ថវិកាប្រចាំឆ្នាំ និងផែនការយុទ្ធសាស្ត្រថវិកា។
- កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ដើម្បីទាក់ទាញឲ្យមានការចូលរួមរបស់ វិស័យឯកជន សង្គមស៊ីវិល និងវិស័យសាធារណៈ ដើម្បីសម្រេចបាន គ.អ.ច.ក.។
- កិច្ចខិតខំប្រឹងប្រែងដើម្បីលើកកម្ពស់ "ប្រព័ន្ធអេកូឡូស៊ីទិន្នន័យ គ.អ.ច.ក."។

# ឧបសម្ព័ន្ធទី១ : ពាក្យបំព្រួញ

| | |
|---|---|
| ក.វ.ស. | កម្មវិធីវិនិយោគសាធារណៈ បីឆ្នាំរំកិល |
| គ.អ.ស. | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ |
| គ.អ.ស.ក. | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា |
| គ.អ.ច. | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
| គ.អ.ច.ក. | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា |
| ផ.ស.ស. | ផលិតផលក្នុងស្រុកសរុប |
| ផ.យ.អ.ជ. | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |

# ឧបសម្ព័ន្ធទី២ : គេហទំព័ររបស់ក្រសួង ស្ថាប័ន

| ល.រ. | ក្រសួង ស្ថាប័ន | គេហទំព័រ(www) |
|---|---|---|
| ១ | គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា/ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | cdc- crdb.gov.kh |
| ២ | គណៈកម្មាធិការវិនិយោគកម្ពុជា/ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | cib-cdc.gov.kh |
| ៣ | រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | civilaviation.gov.kh |
| ៤ | អាជ្ញាធរជាតិកម្ពុជាគ្រប់គ្រងសកម្មភាពកម្ចាត់មីន និងសង្គ្រោះជនពិការដោយសារមីន | cmaa.gov.kh |
| ៥ | ក្រសួងឧស្សាហកម្មនិងសិប្បកម្ម | mih.gov.kh |
| ៦ | សន្តិសុខស្បៀងនិងអាហារូបត្ថម្ភនៅកម្ពុជា | card.gov.khf |
| ៧ | ក្រសួងព័ត៌មាន | information.gov.kh |
| ៨ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | maff.gov.kh |
| ៩ | ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | mcfa.gov.kh |
| ១០ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | mef.gov.kh |
| ១១ | ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | mfaic.gov.kh |
| ១២ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | mlmupc.gov.kh |
| ១៣ | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | mlvt.gov.kh |
| ១៤ | ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | mnasrl.gov.kh |
| ១៥ | ក្រសួងពាណិជ្ជកម្ម | moc.gov.kh |
| ១៦ | ក្រសួងធម្មការនិងសាសនា | mocar.gov.kh |
| ១៧ | ក្រសួងការពារជាតិ | mod.gov.kh |
| ១៨ | ក្រសួងបរិស្ថាន | moe.gov.kh |
| ១៩ | ក្រសួងអប់រំ យុវជន និងកីឡា | moeys.gov.kh |
| ២០ | ក្រសួងសុខាភិបាល | moh.gov.kh |
| ២១ | ក្រសួងមហាផ្ទៃ | moi.gov.kh |
| ២២ | ក្រសួងយុត្តិធម៌ | moj.gov.kh |
| ២៣ | ក្រសួងផែនការ | mop.gov.kh |
| ២៤ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | mosalvy.gov.kh |
| ២៥ | ក្រសួងទេសចរណ៍ | mot.gov.org |
| ២៦ | ក្រសួងកិច្ចការនារី | mowa.gov.kh |

| | | |
|---|---|---|
| ២៧ | ក្រសួងធនធានទឹកនិងឧតុនិយម | mowram.gov.kh |
| ២៨ | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | mptc.gov.kh |
| ២៩ | ក្រសួងសាធារណការនិងដឹកជញ្ជូន | mpwt.gov.kh |
| ៣០ | ក្រសួងអភិវឌ្ឍន៍ជនបទ | mrd.gov.kh |
| ៣១ | ក្រសួងមុខងារសាធារណៈ | sspf.gov.kh |
| ៣២ | ក្រសួងរ៉ែនិងថាមពល | mme.gov.kh |
| ៣៣ | អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ | naa.org.kh |
| ៣៤ | ធនាគារជាតិនៃកម្ពុជា | nbc.org.kh |
| ៣៥ | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ | ncdd.gov.kh |
| ៣៦ | គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | ncdm.gov.kh |
| ៣៧ | គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា | cnmc.gov.h |
| ៣៨ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ | cnm.gov.kh |
| ៣៩ | អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន | nacd.gov.kh |
| ៤០ | វិទ្យាស្ថានជាតិស្ថិតិ | nis.gov.kh |
| ៤១ | សាលារាជធានីភ្នំពេញ | phnompenh.gov.kh |
| ៤២ | ទីស្ដីការគណៈរដ្ឋមន្ត្រី | pressocm.gov.kh |
| ៤៣ | ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | snec.gov.kh |

# ឧបសម្ព័ន្ធទី៣ : គ.អ.ស.ក. និងសមិទ្ធផលនៃការសម្រេចបាន គ.អ.ស.ក.

| ល.រ | សូចនាករ | ឯកតា | ២០០០ | ២០០៥ | ២០១០ | ២០១៥ ជាក់ស្តែង | ២០១៥ ចំណុចដៅ | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|---|
| គោលដៅទី១ : ស្ថានភាពនៃការលុបបំបាត់ភាពក្រីក្រនិងភាពអត់ឃ្លាន | | | | | | | | |
| 1.1 | កាត់បន្ថយសមមាត្រប្រជាជនរស់នៅក្នុងភាពក្រីក្រ | % | 39.5 (1993) | - | 21.1 | 13.5 (2014) | ≤19.5 | អ.ស.ស.ក |
| 1.2 | កាត់បន្ថយសមមាត្រប្រជាជនរស់នៅក្នុងភាពអត់ឃ្លាន | % | 20 (1993) | - | 4.1 | 0 (2014) | ≤10 | អ.ស.ស.ក |
| 1.3 | បង្កើនចំណែកក្នុងការប្រើប្រាស់របស់ប្រជាជនក្រីក្របំផុត២០%នៃចំនួនប្រជាជនសរុប | % | 7.4 (1993) | - | 8.34 | 8.6 (2014) | ≥11 | អ.ស.ស.ក |
| 1.4 | កាត់បន្ថយប្រេវ៉ាឡង់នៃកុមារខ្វះគ្រប់ទម្ងន់(អាយុក្រោម៥ឆ្នាំ) | % | 45.2 | 28 | 28 | 23 (2014) | ≤ 19 | អ.ស.ស.ក |
| 1.5 | កាត់បន្ថយប្រេវ៉ាឡង់នៃកុមារក្រិន | % | 44.6 | 43 | 40 | 32 (2014) | ≤25 | អ.ប.ស.ក |
| 1.6 | កាត់បន្ថយប្រេវ៉ាឡង់នៃកុមារស្គមស្គាំង | % | 15 | 8 | 11 | 10 (2014) | ≤9 | អ.ប.ស.ក |
| 1.7 | កាត់បន្ថយប្រេវ៉ាឡង់កង្វះគ្រាប់ឈាមរបស់កុមារអាយុ៦-៥៩ខែ | % | | 62 | 55 | 56 (2014) | 42 | អ.ប.ស.ក |
| 1.8 | កាត់បន្ថយប្រេវ៉ាឡង់កង្វះគ្រាប់ឈាមរបស់ស្ត្រីអាយុ១៥-៤៩ឆ្នាំ | % | | 47 | 44 | 45 (2014) | 42 | អ.ប.ស.ក |
| 1.9 | បង្កើនសមាមាត្រគ្រួសារដែលប្រើប្រាស់អំបិលអ៊ីយ៉ូដ | % | 14 | 73 | 83 | | 90 | អ.ប.ស.ក |
| 1.10 | កាត់បន្ថយអត្រានៃពលកម្មកុមារ(តិចជាងឬស្មើអាយុ១៧ឆ្នាំ)នៃចំនួនកុមារសរុបនៅក្នុងក្រុមអាយុនោះ | % | 16.5 (1999) | - | 16.8 | 19.3 (2014) | ≤8 | អ.ស.ស.ក |
| គោលដៅទី២ : សម្រេចឲ្យបានសកលកម្មអក្ខរកម្មនិងការអប់រំបឋមសិក្សា | | | | | | | | |
| 2.1 | សាកលកម្មអក្ខរកម្មមនុស្សពេញវ័យ(១៥ដល់២៤ឆ្នាំ | % | - | 80.4 | 89.1 | 93 (2013) | 94.5 | ក.អ.យ.ក |
| 2.2 | អត្រាពិតនៃការសិក្សានៅបឋមសិក្សា | | | | | | | |
| | សរុប | % | 88.9 | 91.9 | 94.8 | 97.9* | 99 | ក.អ.យ.ក |
| | ស្ត្រី | % | 86.8 | 90.7 | 94.6 | 98.4* | | |
| 2.3 | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ | | | | | | | |
| | សរុប | % | 36.5 | 45.8 | 58.1 | 55.1* | 74 | ក.អ.យ.ក |
| | ស្ត្រី | % | 29.5 | 40.3 | 57.1 | 56.2* | | |
| 2.4 | អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា | | | | | | | |
| | សរុប | % | - | 46.8 | 83.2 | 84.1 | 100 | ក.អ.យ.ក |
| | ស្ត្រី | % | - | 45.7 | 83.6 | 86.6 | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 2.5 | អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ | | | | | | |
| | សរុប | % | - | 19.7 | 48.7 | 40.3 | 57 | ក.អ.យ.ក |
| | ស្ត្រី | % | - | 18.5 | 47.2 | 41.8 | | |
| 2.6 | យុគភាពយេនឌ័រក្នុងការអប់រំនៅបឋមសិក្សា | សន្ទស្សន៍ | 0.95 | 0.97 | 1 | 1 | - | ក.អ.យ.ក |
| 2.7 | យុគភាពយេនឌ័រក្នុងការអប់រំនៅមធ្យមសិក្សាបឋមភូមិ | សន្ទស្សន៍ | 0.68 | 0.79 | 0.97 | 1.1 | - | ក.អ.យ.ក |
| គោលដៅទី៣ : លើកកម្ពស់សមភាពយេនឌ័រនិងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី | | | | | | | |
| 3.1 | ផលធៀបរវាងសិស្សស្រីនិងប្រុសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ | % | 48<br>(2001) | 60 | 82 | 100 | 100 | ក.អ.យ.ក |
| 3.2 | ផលធៀបរវាងសិស្សស្រីនិងប្រុសនៅកម្រិតឧត្តមសិក្សា | % | 38<br>(2001) | 45.6 | 86.7 | 85 | 85 | ក.អ.យ.ក |
| 3.3 | ផលធៀបអក្ខរកម្មស្ត្រីនិងបុរសអាយុ១៥-២៤ឆ្នាំ | % | 87<br>(1998) | 90 | 98.3 | 100 | 100 | ក.អ.យ.ក |
| 3.4 | ផលធៀបអក្ខរកម្មស្ត្រីនិងបុរសអាយុ២៥-៤៤ឆ្នាំ | % | 78<br>(1998) | 80 | 99 | 100 | 100 | ក.អ.យ.ក |
| 3.5 | បង្កើនសមាមាត្រនៃស្ត្រីធ្វើការងារមានប្រៀវត្សរ៍ក្នុងវិស័យកសិកម្ម | % | 35<br>(1998) | 52.5 | 53 | 45.7<br>(2013) | 50 | អ.ស.ស.ក |
| 3.6 | បង្កើនសមាមាត្រនៃស្ត្រីធ្វើការងារមានប្រៀវត្សរ៍ក្នុងវិស័យឧស្សាហកម្ម | % | 44<br>(1998) | 53.5 | 73.7 | 45.4 | 50 | អ.ស.ស.ក |
| 3.7 | បង្កើនសមាមាត្រនៃស្ត្រីធ្វើការងារមានប្រៀវត្សរ៍ក្នុងវិស័យសេវាកម្ម | % | 21<br>(1998) | 27 | 27.4 | 32<br>(2013) | 50 | អ.ស.ស.ក |
| 3.8 | បង្កើនសមាមាត្រនៃអាសនៈរបស់ស្ត្រីនៅក្នុងសភាជាតិ | % | 12.3<br>(1998) | 19.5<br>(2003) | 21<br>(2008) | 20.32<br>(2013) | 30 | កិច្ចនារីមហាផ្ទៃ |
| 3.9 | បង្កើនសមាមាត្រនៃអាសនៈរបស់ស្ត្រីនៅក្នុងព្រឹទ្ធសភា | % | 14.75<br>(1999) | 14.75<br>(2006) | 14.75<br>(2012) | 14.75<br>(2012) | 30 | កិច្ចនារីមហាផ្ទៃ |
| 3.10 | បង្កើនសមាមាត្រនៃស្ត្រីជារដ្ឋមន្ត្រី | % | 7.4<br>(1998) | 7.1<br>(2003) | 7.1<br>(2008) | 10.7<br>(2013) | 15 | កិច្ចនារីមហាផ្ទៃ |
| 3.11 | បង្កើនសមាមាត្រនៃស្ត្រីជារដ្ឋលេខាធិការ | % | 6<br>(1998) | 6.6<br>(2003) | 8<br>(2008) | 20.54<br>(2013) | 18 | កិច្ចនារីមហាផ្ទៃ |
| 3.12 | បង្កើនសមាមាត្រនៃស្ត្រីជាអនុរដ្ឋលេខាធិការ | % | 4<br>(1998) | 7.5<br>(2003) | 15.1<br>(2008) | 17.6<br>(2013) | 20 | កិច្ចនារីមហាផ្ទៃ |
| 3.13 | បង្កើនសមាមាត្រនៃស្ត្រីជាអភិបាលខេត្ត | % | 0 | 0 | 0 | 0 | 10 | កិច្ចនារីមហាផ្ទៃ |
| 3.14 | បង្កើនសមាមាត្រនៃស្ត្រីជាអភិបាលរងខេត្ត | % | 0 | 1<br>(2003) | 20<br>(2011) | 17<br>(2014) | 15 | កិច្ចនារីមហាផ្ទៃ |
| 3.15 | បង្កើនសមាមាត្រនៃអាសនៈរបស់ស្ត្រីជាសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ | % | - | 9.4<br>(2002) | 15.1<br>(2007) | 17.8<br>(2012) | 25 | កិច្ចនារីមហាផ្ទៃ |
| គោលដៅទី៤ : កាត់បន្ថយអត្រាមរណភាពកុមារ | | | | | | | |
| 4.1 | កាត់បន្ថយអត្រាមរណភាពរបស់កុមារអាយុក្រោម១ឆ្នាំ ដល់ ៥០ នៅឆ្នាំ២០១៥ | ក្នុង១០០០កំណើតរស់ | 95<br>(1998) | 66 | 45 | 28<br>(2014) | 50 | អ.ប.ស.ក |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 4.2 | កាត់បន្ថយអត្រាមរណភាពរបស់កុមារអាយុក្រោម៥ឆ្នាំ | ក្នុង១០០០ កំណើតរស់ | 124 (1998) | 83 | 54 | 35 (2014) | 65 | អ.ប.ស.ក |
| 4.3 | បង្កើនការផ្តល់វ៉ាក់សាំងដល់កុមារឲ្យបាន ៩០% | % | 71 | 79 | 92 | 98 | >90 | អ.ប.ស.ក |
| 4.4 | បង្កើនការបំបៅដោះដល់កុមាររហូតអាយុ៦ខែ ឲ្យបាន៧០% | % | 11.4 | - | 74 | 93 | 70 | អ.ប.ស.ក |
| **គោលដៅទី៥ : លើកកម្ពស់សុខភាពមាតា** | | | | | | | | |
| 5.1 | អត្រាមរណភាពមាតា | ក្នុង១០០ ០០០ កំណើតរស់ | 437 (1997) | 472 | 206 | 170 (2014) | 250 | អ.ប.ស.ក |
| 5.2 | ការសម្រាលកូនជាមួយបុគ្គលិកសុខាភិបាលជំនាញ | % | 22.1 (2002) | 40.57 | 69.6 | 85 (2014) | 87 | សុខាភិបាល |
| 5.3 | អត្រាផ្តល់កំណើតសរុប | % | 4 | 3.4 | 3 | 2.7 | 3 | អ.ប.ស.ក |
| 5.4 | សមាមាត្រស្ត្រីដែលបានរៀបអាពាហ៍ពិពាហ៍ប្រើប្រាស់វិធីពន្យារកំណើត | % | 19 | 21 | 24.82 (2008) | 35 (2014) | 60 | អ.ប.ស.ក |
| 5.5 | សមាមាត្រស្ត្រីមានផ្ទៃពោះ ទទួលបានការពិនិត្យផ្ទៃពោះ២ដងឬច្រើនជាងនេះ | % | 25.4 | 52.2 | 72 | 90.5 (2014) | 90 | អ.ប.ស.ក |
| 5.6 | សមាមាត្រនៃការសម្រាលកូនដោយវិធីវះកាត់ | % | 1.12 | 1.18 | 2.56 | 5.37 (2014) | 4 | អ.ប.ស.ក |
| **គោលដៅទី៦ : ការប្រយុទ្ធប្រឆាំងមេរោគអេដស៍ ជំងឺអេដស៍ ជំងឺគ្រុនចាញ់ និងជំងឺផ្សេងៗទៀត** | | | | | | | | |
| 6.1 | អត្រាផ្ទុកនៃមេរោគអេដស៍ | % | 1.9 | 1.2 | 0.8 | 0.6 (2014) | 0.4 | សុខាភិបាល |
| 6.2 | ប្រេវ៉ាឡង់ជំងឺរបេង | ក្នុង១០០ ០០០ កំណើតរស់ | 1,620 | 1,230 | 875 | 668 (2014) | 653 | សុខាភិបាល |
| 6.3 | អត្រាស្លាប់ដោយជំងឺរបេង | ក្នុង១០០ ០០០ កំណើតរស់ | 5.3 | 1.4 | 0.98 | 0.07 (2014 | 0.8 | សុខាភិបាល |
| **គោលដៅទី៧ : ធានាចីរភាពបរិស្ថាន** | | | | | | | | |
| 7.1 | ផ្ទៃដីតំបន់ការពារធម្មជាតិ២៣កន្លែង | ពាន់ហ.ត. | 3,263 | 3,111 | 3,101 | 3,098 | - | សុខាភិបាល |
| 7.2 | សហគមន៍តំបន់ការពារធម្មជាតិ | ចំនួន | 4 | 59 | 98 | 129 | - | សុខាភិបាល |
| 7.3 | ឧទ្យានអនុរក្សក្នុងតំបន់ការពារធម្មជាតិ | ចំនួន | 325 | 700 | 480 | 960 | - | សុខាភិបាល |
| 7.4 | បង្កើនសមាមាត្រប្រជាជនមានទឹកស្អាតប្រើប្រាស់ | | | | | | | |
| | a) តំបន់ជនបទ | % | 24 (1998) | 41.6 (2008) | 43.46 | 50 (2014) | 50 | អ.ស.ស.ក |
| | b) តំបន់ទីប្រជុំជន | % | 60 (1998) | - | 80.5 | 81 (2014) | 80 | អ.ស.ស.ក |
| 7.5 | បង្កើនសមាមាត្រប្រជាជនដែលទទួលបានអនាម័យ | | | | | | | |
| | a) តំបន់ជនបទ | % | 8.6 (1998) | 16.8 (2004) | 29.2 | 46.2 (2014) | 46 | អ.ស.ស.ក |
| | b) តំបន់ទីប្រជុំជន | % | 49 (1998) | - | 86.6 | 89 (2014) | 74 | អ.ស.ស.ក |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 7.6 | កាត់បន្ថយការប្រើប្រាស់អុសសម្រាប់ចម្អិនអាហារ | % | 92 (1993) | - | 79.5 | 74.8 (2014) | 52 | អ.ស.ស.ក |
| 7.7 | បង្កើនសមាមាត្រប្រជាជនទទួលបានកម្មសិទ្ធិដីធ្លី | % | 10 | 15 | 24 | 58 | 57 | ក.រ.ន.ស |
| 7.8 | គម្របព្រៃឈើ | % | 63.74 | 59.09 | 57.07 | 49.87 (2014) | - | ក.ស.ក |
| | | ពាន់ហ.ត | 11,540 | 10,730 | 10,363 | 9,056 (2014) | - | ក.ស.ក |
| 7.9 | សហគមន៍ព្រៃឈើ | សហគមន៍ | 264 | 402 | 441 | 497 | - | ក.ស.ក |
| | | ហ.ត | 179,021 | 380,589 | 391,831 | 514,834 | - | ក.ស.ក |
| 7.10 | សហគមន៍ព្រៃឈើបានចុះបញ្ជីផ្លូវការ | សហគមន៍ | - | - | 233 | 401 | - | ក.ស.ក |
| | | ហ.ត | - | - | 230,370 | 338,317 | - | ក.ស.ក |
| 7.11 | ការកាត់បន្ថយឡូត៍នេសាទជូនសហគមន៍នេសាទមូលដ្ឋាន | % | - | 56.36 | 56.74 | 89.77 | - | ក.ស.ក |
| 7.12 | បរិមាណផលិតកម្មនេសាទ(ទឹកសាប សមុទ្រ និងវារីវប្បកម្ម) | ពាន់តោន | 136 | 354.89 | 550 | 647 | - | ក.ស.ក |
| 7.13 | ចំនួនសហគមន៍នេសាទ | សហគមន៍ | - | 440 | 469 | 516 | - | ក.ស.ក |
| គោលដៅទី៩ : ការបោសសម្អាតមីន សំណល់ជាតិផ្ទុះពីសង្គ្រាម និងការសង្គ្រោះជនពិការដោយសារមីន | | | | | | | | |
| 9.1 | ចំនួននៃជនរងគ្រោះដែលបង្ករឡើងដោយគ្រាប់មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម (ស្លាប់និងរបួស) | | | | | | | |
| | ចំណុចដៅ | នាក់ | 575 | 357 | 220 | 130 | - | អាជ្ញាធរមីន |
| | លទ្ធផល | នាក់ | 858 | 875 | 286 | 79 | - | អាជ្ញាធរមីន |
| 9.2 | ផ្ទៃដីដែលបានបោសសម្អាតគ្រាប់មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម | | | | | | | |
| | ចំណុចដៅ | ហ.ត | 1,562 | 4,466 | 5,374 | 5,909 | - | អាជ្ញាធរមីន |
| | លទ្ធផល | ហ.ត | 3,208 | 4,065 | 11,950 | 16,104 | - | អាជ្ញាធរមីន |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

*រាជរដ្ឋាភិបាលកម្ពុជា*

# ក្របខ័ណ្ឌ
# គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា
# ឆ្នាំ២០១៦-២០៣០

# ផ្នែកទី២ គោលដៅ ចំណុចដៅ និងសូចនាករ

**បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី**

**ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨**

# តារាងមាតិកា

**តារាងមាតិកា** ........................................................................................................ i

**តារាងទី១ : សូចនាករគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា តាម គោលដៅ និង ចំណុចដៅ នីមួយៗ** ........................................................................ ១

គោលដៅទី១ : បញ្ចប់ភាពក្រីក្រគ្រប់ទម្រង់នៅគ្រប់ទីកន្លែង ........................................... ១

គោលដៅទី២ : បញ្ចប់ភាពអត់ឃ្លាន សម្រេចឲ្យបានសន្តិសុខស្បៀង ធ្វើឲ្យប្រសើរឡើងស្ថានភាពអាហារូបត្ថម្ភ និង លើកកម្ពស់កសិកម្មប្រកបដោយចីរភាព .................... ៣

គោលដៅទី៣ : ធានាឲ្យជីវភាពរស់នៅរបស់ប្រជាជនប្រកបដោយសុខភាពល្អ និងលើកកម្ពស់សុខុមាលភាពរបស់មនុស្សគ្រប់រូបនិងគ្រប់វ័យ ........................................ ៦

គោលដៅទី៤ : ធានាការអប់រំប្រកបដោយ គុណភាព បរិយាបន្ន និងសមធម៌ និងលើកកម្ពស់កាលានុវត្តភាពសិក្សាពេញមួយជីវិត សម្រាប់ប្រជាជនគ្រប់រូប ...................... ១០

គោលដៅទី៥ : សម្រេចឲ្យបានសមភាពយេនឌ័រនិងពង្រឹងភាពអង់អាចរបស់ស្ត្រីនិងកុមារីគ្រប់រូប .......................................................................................... ១៤

គោលដៅទី៦ : ធានាឲ្យមានទឹកនិងអនាម័យនិងការគ្រប់គ្រងទឹកនិងអនាម័យប្រកបដោយចីរភាពសម្រាប់ប្រជាជនគ្រប់រូប ................................................ ១៧

គោលដៅទី៧ : ធានាឲ្យទទួលបានថាមពលដែលមានលក្ខណៈបច្ចេកទេសទំនើប ប្រកបដោយចីរភាព អាចជឿជាក់បាន និងមានតម្លៃសមរម្យ សម្រាប់ប្រជាជនគ្រប់រូប ....... ១៩

គោលដៅទី៨ : ធានាកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពនិងបរិយាបន្ន មានមុខរបរពេញលេញនិងផលិតភាព និងមានការងារសមរម្យសម្រាប់ប្រជាជនគ្រប់រូប .......... ២០

គោលដៅទី៩ : កសាងហេដ្ឋារចនាសម្ព័ន្ធដែលធន់នឹងបម្រែបម្រួលអាកាសធាតុ លើកកម្ពស់ឧស្សាហូបនីយកម្មប្រកបដោយចីរភាពនិងបរិយាប័ន្ននិងលើកកម្ពស់នវានុវត្តន៍ ២៣

គោលដៅទី១០ : កាត់បន្ថយវិសមភាពនៅក្នុងប្រទេសនិងក្នុងចំណោមបណ្តាប្រទេសនានា ...... ២៥

គោលដៅទី១១ : ធ្វើឲ្យទីក្រុងនិងកន្លែងតាំងទីលំនៅថ្មីសម្រាប់ប្រជាជន មានលក្ខណៈបរិយាបន្ន សុវត្ថិភាព ធន់នឹងបម្រែបម្រួលអាកាសធាតុនិងចីរភាព ............................... ២៧

គោលដៅទី១២ :ធានាឲ្យមានចីរភាពក្នុងទម្រង់នៃការប្រើប្រាស់និងផលិតកម្ម ........................ ២៨

គោលដៅទី១៣ : ចាត់វិធានការជាបន្ទាន់ ដើម្បីប្រយុទ្ធប្រឆាំងនឹងបម្រែបម្រួលអាកាសធាតុ និងផលប៉ះពាល់របស់វា ............................................................................ ២៩

គោលដៅទី១៤ : អភិរក្សនិងប្រើប្រាស់ប្រកបដោយចីរភាពនូវ មហាសមុទ្រ សមុទ្រ និងធនធានសមុទ្រ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព .......................................... ៣១

គោលដៅទី១៥ : ការពារ ស្តារ និងជំរុញការប្រើប្រាស់ប្រកបដោយចីរភាពនូវប្រព័ន្ធអេកូឡូស៊ីនៅលើដែនគោក គ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព ប្រយុទ្ធប្រឆាំងនឹង ឱនភាពដី បញ្ឈប់និងបង្វែរទិសនៃការសឹករេចរឹលគុណភាពដី និងបញ្ឈប់កុំឲ្យបាត់បង់ជីជាតិដីនិងជីវៈចម្រុះ ........................................ ៣៣

គោលដៅទី១៦ : លើកកម្ពស់សង្គមដែលមានសន្តិភាពប្រកបដោយបរិយាបន្ន ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព ផ្តល់នូវការទទួលបានយុត្តិធម៌សម្រាប់ប្រជាជន គ្រប់រូបនិងកសាងស្ថាប័នដែលមានប្រសិទ្ធភាព គណនេយ្យភាព និងបរិយាបន្ននៅគ្រប់កម្រិត ........................................ ៣៥

គោលដៅទី១៧ : ពង្រឹងមធ្យោបាយអនុវត្តនានានិងបង្កើតភាពរស់រវើកនៃភាពជាដៃគូសកលសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ........................................ ៣៦

គោលដៅទី១៨ : បញ្ចប់ផលប៉ះពាល់ជាអវិជ្ជមានរបស់មីន/សំណល់ជាតិផ្ទុះពីសង្គ្រាម និងជំរុញការសង្គ្រោះជនរងគ្រោះ ........................................ ៤០

**តារាងទី២ : តម្លៃគ្រាដើមនិងចំណុចដៅ នៃសូចនាករនីមួយៗ របស់គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា** ........................................ ៤២

គោលដៅទី១ : បញ្ចប់ភាពក្រីក្រគ្រប់ទម្រង់នៅគ្រប់ទីកន្លែង ........................................ ៤២

គោលដៅទី២ : បញ្ចប់ភាពអត់ឃ្លាន សម្រេចឲ្យបានសន្តិសុខស្បៀង ធ្វើឲ្យប្រសើរឡើងស្ថានភាពអាហារូបត្ថម្ភនិងលើកកម្ពស់កសិកម្មប្រកបដោយចីរភាព ........................................ ៤៤

គោលដៅទី៣ : ធានាឲ្យជីវភាពរស់នៅរបស់ប្រជាជនប្រកបដោយសុខភាពល្អ និងលើកកម្ពស់សុខមាលភាពរបស់មនុស្សគ្រប់រូបនិងគ្រប់វ័យ ........................................ ៤៧

គោលដៅទី៤ : ធានាការអប់រំប្រកបដោយគុណភាព បរិយាបន្ន និងសមធម៌ និងលើកកម្ពស់កាលានុវត្តភាពសិក្សាពេញមួយជីវិតសម្រាប់ប្រជាជនគ្រប់រូប ........................................ ៥១

គោលដៅទី៥ : សម្រេចឲ្យបានសមភាពយេនឌ័រនិងពង្រឹងភាពអង់អាចរបស់ស្ត្រីនិងកុមារីគ្រប់រូប ........................................ ៥៤

គោលដៅទី៦ : ធានាឲ្យមានទឹកនិងអនាម័យនិងការគ្រប់គ្រងទឹកនិងអនាម័យប្រកបដោយចីរភាព សម្រាប់ប្រជាជនគ្រប់រូប ........................................ ៥៧

គោលដៅទី៧ : ធានាឲ្យទទួលបានថាមពលដែលមានលក្ខណៈបច្ចេកទេសទំនើប ប្រកបដោយចីរភាពអាចជឿជាក់បាន និងមានតម្លៃសមរម្យ សម្រាប់ប្រជាជនគ្រប់រូប ........ ៦០

គោលដៅទី៨ : ធានាកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពនិងបរិយាបន្ន មានមុខរបរពេញលេញនិងផលិតភាព និងមានការងារសមរម្យ សម្រាប់ប្រជាជនគ្រប់រូប ........ ៦០

គោលដៅទី៩ : កសាងហេដ្ឋារចនាសម្ព័ន្ធដែលធន់នឹងបម្រែបម្រួលអាកាសធាតុ លើកកម្ពស់ឧស្សាហូបនីយកម្មប្រកបដោយចីរភាពនិងបរិយាបន្ននិងលើកកម្ពស់នវានុវត្តន៍ ៦៣

គោលដៅទី១០ : កាត់បន្ថយវិសមភាពនៅក្នុងប្រទេសនិងក្នុងចំណោមបណ្តាប្រទេសនានា..... ៦៦

គោលដៅទី១១ : ធ្វើឲ្យទីក្រុងនិងកន្លែងតាំងទីលំនៅថ្មីសម្រាប់ប្រជាជន មានលក្ខណៈបរិយាបន្ន សុវត្ថិភាព ធន់នឹងបម្រែបម្រួលអាកាសធាតុនិងចីរភាព ............................ ៦៨

គោលដៅទី១២ : ធានាឲ្យមានចីរភាពក្នុងទម្រង់នៃការប្រើប្រាស់និងផលិតកម្ម ..................... ៦៨

គោលដៅទី១៣ : ចាត់វិធានការជាបន្ទាន់ ដើម្បីប្រយុទ្ធប្រឆាំងនឹងបម្រែបម្រួលអាកាសធាតុ និងផលប៉ះពាល់របស់វា ..................................................................... ៦៩

គោលដៅទី១៤ : អភិរក្សនិងប្រើប្រាស់ប្រកបដោយចីរភាពនូវ មហាសមុទ្រ សមុទ្រ និងធនធានសមុទ្រ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ................................ ៧១

គោលដៅទី១៥ : ការពារ ស្តារ និងជំរុញការប្រើប្រាស់ប្រកបដោយចីរភាពនូវប្រព័ន្ធអេកូឡូស៊ីនៅលើដែនគោក គ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព ប្រយុទ្ធប្រឆាំងនឹងឱនភាពដី បញ្ឈប់និងបង្វែរទិសនៃការសឹករេចរឹលគុណភាពដី និងបញ្ឈប់កុំឲ្យបាត់បង់ជីជាតិដីនិងជីវៈចម្រុះ ........................................ ៧២

គោលដៅទី១៦ : លើកកម្ពស់សង្គមដែលមានសន្តិភាពប្រកបដោយបរិយាបន្ន ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព ផ្តល់នូវការទទួលបានយុត្តិធម៌សម្រាប់ប្រជាជនគ្រប់រូប និងកសាងស្ថាប័នដែលមានប្រសិទ្ធភាព គណនេយ្យភាព និងបរិយាបន្ន នៅគ្រប់កម្រិត ........................................................................................ ៧៥

គោលដៅទី១៧ : ពង្រឹងមធ្យោបាយអនុវត្តនានានិងបង្កើតភាពរស់រវើកនៃភាពជាដៃគូសកល សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ................................................ ៧៦

គោលដៅទី ១៨ : បញ្ចប់ផលប៉ះពាល់ជាអវិជ្ជមានរបស់មីន/សំណល់ជាតិផ្ទុះពីសង្គ្រាម និងជំរុញការសង្គ្រោះជនរងគ្រោះ ........................................................... ៨០

# តារាងទី១

# សូចនាករ
# គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា
# តាមគោលដៅនិងចំណុចដៅនីមួយៗ

# តារាងទី១ : សូចនាកររបស់គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជាតាមគោលដៅនិងចំណុចដៅនីមួយៗ

| ចំណុចដៅ | សូចនាករ | ស្ថាប័នទទួលខុសត្រូវ | ប្រភពទិន្នន័យ | វដ្តនៃទិន្នន័យ | និយមន័យ | វិធីសាស្ត្រគណនាតម្លៃសូចនាករ | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | | | | ភាគយក | ភាគបែង | |
| **គោលដៅទី១ : បញ្ចប់ភាពក្រីក្រគ្រប់ទម្រង់នៅគ្រប់ទីកន្លែង** | | | | | | | | |
| ១.២ កាត់បន្ថយយ៉ាងតិចពាក់កណ្ដាលនូវសមាមាត្រនៃបុរស ស្ត្រីនិងកុមារ គ្រប់អាយុ ដែលរស់នៅក្នុងភាពក្រីក្រ គ្រប់សមាសភាព ដោយផ្អែកលើនិយមន័យរបស់កម្ពុជា នៅត្រឹមឆ្នាំ២០៣០ | ១.២.១. សមាមាត្រនៃប្រជាជនកម្ពុជារស់នៅក្រោមបន្ទាត់ភាពក្រីក្រជាតិបែងចែកតាមភេទ អាយុ និងតំបន់ភូមិសាស្ត្រ | ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជា | វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ | រៀងរាល់២ឆ្នាំ | ចំនួនប្រជាជនកម្ពុជាដែលរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រជាតិ បែងចែកតាម ភេទ អាយុ និង តំបន់ភូមិសាស្ត្រ ក្នុងចំណោមចំនួនប្រជាជនកម្ពុជាសរុប បែងចែកតាមភេទ អាយុ និងតំបន់ភូមិសាស្ត្រ | ចំនួនប្រជាជនកម្ពុជាដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្រជាតិ បែងចែកតាមភេទ អាយុ និងតំបន់ភូមិសាស្ត្រនៅក្នុងឆ្នាំ | ចំនួនប្រជាជនកម្ពុជាសរុបបែងចែកតាម ភេទ អាយុ និងតំបន់ភូមិសាស្ត្រនៅក្នុងឆ្នាំ | |
| | ១.២.១.១ សមាមាត្រនៃប្រជាជនកម្ពុជារស់នៅក្រោមបន្ទាត់ភាពក្រីក្រជាតិ | ក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជា | វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ | រៀងរាល់២ឆ្នាំ | ចំនួនប្រជាជនកម្ពុជាដែលរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រជាតិ ក្នុងចំណោមចំនួនប្រជាជនកម្ពុជាសរុប | ចំនួនប្រជាជនកម្ពុជាដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្រជាតិ នៅក្នុងឆ្នាំ | ចំនួនប្រជាជនកម្ពុជាសរុបនៅក្នុងឆ្នាំ | |
| | ១.២.១.២ សមាមាត្រនៃប្រជាជនកម្ពុជានៅរាជធានីភ្នំពេញដែលរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រជាតិ | ក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជា | វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ | រៀងរាល់២ឆ្នាំ | ចំនួនប្រជាជនកម្ពុជានៅរាជធានីភ្នំពេញ រស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រជាតិ ក្នុងចំណោមចំនួនប្រជាជនកម្ពុជាទាំងអស់ដែលរស់នៅរាជធានីភ្នំពេញ | ចំនួនប្រជាជនកម្ពុជានៅរាជធានីភ្នំពេញដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្រជាតិ នៅក្នុងឆ្នាំរាយការណ៍ | ចំនួនសរុបនៃប្រជាជនកម្ពុជារស់នៅរាជធានីភ្នំពេញ នៅក្នុងឆ្នាំរាយការណ៍ | |
| | ១.២.១. ៣ សមាមាត្រនៃប្រជាជនកម្ពុជានៅតំបន់ទីប្រជុំជន ដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្រ | ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជា | វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ | រៀងរាល់២ឆ្នាំ | ចំនួនប្រជាជនកម្ពុជានៅតំបន់ទីប្រជុំជន រស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រជាតិ ក្នុងចំណោមចំនួនប្រជាជនកម្ពុជាសរុបដែលរស់នៅតំបន់ទីប្រជុំជន | ចំនួនប្រជាជនកម្ពុជានៅតំបន់ទីប្រជុំជនដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្រជាតិ នៅក្នុងឆ្នាំរាយការណ៍ | ចំនួនសរុបនៃប្រជាជនកម្ពុជារស់នៅតំបន់ទីប្រជុំជន នៅក្នុងឆ្នាំរាយការណ៍ | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | ១.២.១.៤ សមាមាត្រនៃប្រជាជនកម្ពុជា នៅតំបន់ជនបទ ដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្រ | ក្រសួង ស្ថាប័ន របស់រាជរដ្ឋាភិបាលកម្ពុជា | វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ | រៀងរាល់២ឆ្នាំ | ចំនួនប្រជាជន កម្ពុជានៅតំបន់ជនបទរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រជាតិ ក្នុងចំណោមចំនួនប្រជាជនកម្ពុជាសរុបរស់នៅតំបន់ជនបទ | ចំនួនប្រជាជនកម្ពុជានៅតំបន់ជនបទដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្រជាតិ នៅក្នុងឆ្នាំរាយការណ៍ | ចំនួនសរុបនៃប្រជាជនកម្ពុជារស់នៅតំបន់ជនបទ នៅក្នុងឆ្នាំរាយការណ៍ | |
| | ១.២.១.៥ សមាមាត្រនៃកុមារកម្ពុជារស់នៅក្រោមបន្ទាត់ភាពក្រីក្រជាតិ | ក្រសួង ស្ថាប័ន របស់រាជរដ្ឋាភិបាលកម្ពុជា | វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ | រៀងរាល់២ឆ្នាំ | ចំនួនកុមារកម្ពុជា (អាយុ ០-១៧ឆ្នាំ) រស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រជាតិ ក្នុងចំណោមចំនួនកុមារកម្ពុជា (អាយុ ០-១៧ឆ្នាំ) សរុប | ចំនួនកុមារកម្ពុជា (អាយុ ០-១៧ឆ្នាំ) ដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្រជាតិ នៅក្នុងឆ្នាំរាយការណ៍ | ចំនួនកុមារកម្ពុជា (អាយុ ០-១៧ឆ្នាំ) សរុបនៅក្នុងឆ្នាំរាយការណ៍ | |
| | ១.២.២ សមាមាត្រ កុមារដែលរស់នៅក្នុងភាពក្រីក្រគ្រប់សមាសភាព ផ្អែកតាមនិយមន័យរបស់ជាតិ | ក្រសួង ស្ថាប័ន របស់រាជរដ្ឋាភិបាលកម្ពុជា | វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ | ៥ឆ្នាំ | សមាមាត្រនៃកុមារកម្ពុជា (អាយុ ០-១៧ឆ្នាំ) ដែលមិនបានទទួលការបំពេញតម្រូវការជាមូលដ្ឋានដែលមានទំនាក់ទំនងយ៉ាងសំខាន់ចំពោះសុខុមាលភាពកុមាររួមមានសុខភាព អាហា រូបត្ថម្ភទឹកស្អាត និង អនាម័យ ការអប់រំ ការការពារ និងលំនៅដ្ឋាន | ចំនួនកុមារកម្ពុជា (អាយុ ០-១៧ឆ្នាំ) ដែលមិនបានទទួលការបំពេញតម្រូវការជាមូលដ្ឋានយ៉ាងហោចណាស់ចំនួន៣ ក្នុងចំណោមទាំង៥សមាសភាគនៅក្នុងឆ្នាំរាយការណ៍ | ចំនួនកុមារកម្ពុជា (អាយុ ០-១៧ឆ្នាំ) សរុប នៅក្នុងឆ្នាំរាយការណ៍ | |
| ១.៣ អនុវត្តប្រព័ន្ធជាតិគាំពារសង្គមនិងវិធានការផ្សេងៗ ឲ្យបានទូទាំងប្រទេស និងសម្រេចឲ្យបានភាគច្រើននូវភាពគ្របដណ្តប់នៃប្រព័ន្ធនេះដល់ប្រជាជនក្រីក្រ និងប្រជាជនងាយរងគ្រោះ នៅត្រឹមឆ្នាំ២០៣០ | ១.៣.១ សមាមាត្រនៃជនក្រីក្រ និងជនងាយរងគ្រោះ ដែលទទួលបានសេវាសង្គ្រោះសង្គម | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ប្រព័ន្ធព័ត៌មានរដ្ឋបាល ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា<br>ក្រសួងផែនការ | ប្រចាំឆ្នាំ | ចំនួនប្រជាជនដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្ររបស់ជាតិ និងប្រជាជនដែលពុំអាចទប់ទល់បាននឹងវិបត្តិឬដែលមានភាពប្រឈម ខ្ពស់ទៅនឹងវិបត្តិ (ប្រជាជនដែលរស់នៅក្រោមឬក្បែរបន្ទាត់ភាពក្រីក្រហើយមានភាពងាយរងគ្រោះខ្ពស់ជាងគេ) ដែលទទួលបានសេវាកម្មជំនួយសង្គ្រោះបន្ទាន់ក្នុងចំណោមជនក្រីក្រនិងជនងាយរងគ្រោះសរុប។ | ចំនួនជនក្រីក្រនិងជនងាយរងគ្រោះ ដែលទទួលបានជំនួយសង្គ្រោះសង្គម នៅក្នុងឆ្នាំរាយការណ៍ | ចំនួនជនក្រីក្រនិងជនងាយរងគ្រោះសរុប នៅក្នុងឆ្នាំរាយការណ៍ | **MOSVY** |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ១.៤ ត្រឹមឆ្នាំ២០៣០ ធានាថា បុរសស្ត្រីគ្រប់រូបជាពិសេសប្រជាជនក្រីក្រនិងប្រជាជនងាយរងគ្រោះ មានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ធនធានសេដ្ឋកិច្ចនិងក្នុងការទទួលបានសេវាមូលដ្ឋានភាពជាម្ចាស់ និងការគ្រប់គ្រងដីនិងកម្មសិទ្ធិផ្សេងទៀត ធនធានធម្មជាតិ បច្ចេកវិទ្យាថ្មីៗសមស្របនិងសេវាហិរញ្ញវត្ថុ រួមទាំងមីក្រូហិរញ្ញវត្ថុ។ | ១.៤.១ ភាគរយនៃសមាជិកសហគមន៍នេសាទនិងព្រៃឈើដែលទទួលបានសិទ្ធិស្របច្បាប់ក្នុងការចូលរួមគ្រប់គ្រងធនធានជលផលនិងព្រៃឈើ តាមរយៈការចុះបញ្ជីនិងអភិវឌ្ឍសហគមន៍ប្រកបដោយប្រសិទ្ធភាព | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រព័ន្ធព័ត៌មានរដ្ឋបាលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រចាំឆ្នាំ | ចំនួនសមាជិកសហគមន៍នេសាទនិងព្រៃឈើដែលទទួលបានសិទ្ធិស្របច្បាប់ក្នុងការចូលរួមគ្រប់គ្រងធនធានជលផលនិងព្រៃឈើ តាមរយៈ ការចុះបញ្ជីនិងអភិវឌ្ឍសហគមន៍ប្រកបដោយប្រសិទ្ធភាពក្នុងចំណោមសហគមន៍នេសាទនិងព្រៃឈើសរុប។ | ចំនួនសមាជិកសហគមន៍នេសាទនិងព្រៃឈើដែលទទួលបានសិទ្ធិស្របច្បាប់ក្នុងការចូលរួមគ្រប់គ្រងធនធានជលផលនិងព្រៃឈើតាមរយៈការ ចុះបញ្ជីនិងអភិវឌ្ឍសហគមន៍ប្រកបដោយប្រសិទ្ធភាព គិតត្រឹមឆ្នាំរាយការណ៍ | ចំនួនសមាជិកសហគមន៍នេសាទនិងព្រៃឈើសរុបគិតត្រឹមឆ្នាំរាយការណ៍ | **MAFF** |
| **គោលដៅទី២ : បញ្ចប់ភាពអត់ឃ្លាន សម្រេចឲ្យបានសន្តិសុខស្បៀង ធ្វើឲ្យប្រសើរឡើងស្ថានភាពអាហារូបត្ថម្ភ និងលើកកម្ពស់កសិកម្មប្រកបដោយចីរភាព** | | | | | | | | |
| ២.២ ត្រឹមឆ្នាំ២០៣០ បញ្ចប់គ្រប់ទម្រង់នៃកង្វះអាហារូបត្ថម្ភ រួមទាំងការសម្រេចបាននៅឆ្នាំ ២០២៥ នូវ ចំណុចដៅដែលបានឯកភាពក្នុងកម្រិតអន្តរជាតិស្តីពីភាពក្រិននិងភាពស្គមស្គាំងរបស់កុមារអាយុក្រោមអាយុ៥ឆ្នាំ និងដោះស្រាយនូវតម្រូវការអាហារូបត្ថម្ភរបស់កុមារីវ័យជំទង់ ស្ត្រីមានផ្ទៃពោះនិងស្ត្រីកំពុងបំបៅដោះកូន និង ស្ត្រីវ័យចាស់។ | ២.២.១ ប្រេវ៉ាឡង់នៃភាពក្រិន (កម្ពស់ធៀបនឹងអាយុមានកម្រិតទាបជាងបទដ្ឋានរីកលូតលាស់មធ្យមរបស់កុមារ របស់អង្គការសុខភាពពិភពលោក) ក្នុងចំណោមកុមារ អាយុក្រោម៥ឆ្នាំ។ | ពណ៌នាទិន្នន័យត្រួតពិនិត្យ និងធ្វើរបាយការណ៍ដោយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ដៃគូដែលចូលរួម | ប្រមូលទិន្នន័យដោយៈ ក្រសួងផែនការ/ក្រសួងសុខាភិបាល | រាល់៥ឆ្នាំ | ភាពក្រិនគឺកម្ពស់ទាបធៀបនឹងអាយុ ហើយសូចនាករនេះវាស់វែងកុមារដែលមានអាយុ ក្រោមនិង៥ឆ្នាំដែលកម្ពស់ធៀបនឹងអាយុមានកម្រិតបទដ្ឋានរីកលូតលាស់ ២ឬច្រើនស្ថិតនៅក្រោមកម្ពស់ជាមធ្យមធៀបនឹងអាយុរបស់កុមារ។ | ចំនួនកុមារដែលមានកម្ពស់ធៀបនឹងអាយុ Z គឺមានកម្រិតបទដ្ឋាន ២ឬច្រើនស្ថិតនៅក្រោមកម្រិតរីកលូតលាស់មធ្យម នៃកម្ពស់ធៀបនឹងអាយុរបស់កុមារ | ចំនួននៃកុមាររស់ដែលមានអាយុចន្លោះពី០ដល់៥៩ខែ មុនការអង្កេត | **CARD** |
| | ២.២.២ ប្រេវ៉ាឡង់នៃភាពស្គមស្គាំង ឬលើសទម្ងន់ (ទម្ងន់ធៀបនឹងកម្ពស់មានកម្រិតទាបជាងឬខ្ពស់ជាងបទដ្ឋានរីកលូតលាស់មធ្យមរបស់អង្គការសុខភាពពិភពលោក (>+2 ឬ<-2) របស់កុមារក្នុងចំណោមកុមារអាយុក្រោម៥ឆ្នាំទៅតាមប្រភេទនីមួយៗ ស្គមស្គាំងឬលើសទំងន់ | ពណ៌នាទិន្នន័យត្រួតពិនិត្យ និងធ្វើរបាយការណ៍ដោយ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ<br>ក្រសួងសុខាភិបាល<br>ក្រសួងអភិវឌ្ឍន៍ជនបទ<br>**ដៃគូដែលចូលរួម**<br>USAID, WFP, UNICEF, WHO, SUN-CSA-CAM | ប្រមូលទិន្នន័យដោយ ក្រសួងផែនការ/ក្រសួងសុខាភិបាល | រាល់៥ឆ្នាំ | សន្ទស្សន៍ទំងន់ធៀបនឹងកម្ពស់ត្រូវបានវាស់វែងពីម៉ាសរាងកាយដែលទាក់ទងនឹងប្រវែងរាងកាយ និងពណ៌នាពីស្ថានភាព អាហារូបត្ថម្ភ។<br>កុមារដែលមានពិន្ទុ Z គឺស្ថិតនៅក្រោមចំនួនសង (-2 SD) នៃបទដ្ឋានមធ្យមរបស់ប្រជាជនដែលមានភាពស្គមស្គាំង ធៀបនឹងកម្ពស់ និងខ្វះអាហារូបត្ថម្ភធ្ងន់ធ្ងរ។ | ចំនួននៃកុមារដែលមានទំងន់ធៀបនឹងកម្ពស់ពិន្ទុ Z គឺជាបទដ្ឋានរីកលូតលាស់២ឬច្រើន ដែលស្ថិតនៅក្រោមមធ្យមនៃទំងន់ធៀបនឹងកម្ពស់របស់ប្រជាជន។ | ចំនួននៃកុមាររស់ដែលមានអាយុចន្លោះពី០ដល់៥៩ខែ មុនការអង្កេត និងកុមារដែលមានតាមសំណាកនៃការអង្កេត | **CARD** |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ២.៣ ត្រឹមឆ្នាំ២០៣០ ទទួលបានកំណើនទ្វេដង នៃផលិតភាពក្នុងវិស័យកសិកម្ម និងចំណូលរបស់ផលិតករធុនតូច ជាពិសេស ស្ត្រីក្នុងគ្រួសារទុរគត គ្រួសារកសិករ អ្នកគង្វាលនិងអ្នកនេសាទ រួមទាំងតាមរយៈការធានា និងការទទួលបានស្មើភាពគ្នានូវដីធ្លី ធនធានផលិតកម្មផ្សេងទៀតនិងធាតុចូល ចំណេះដឹង សេវាហិរញ្ញវត្ថុ ទីផ្សារនិងកាលានុវត្តភាពសម្រាប់តម្លៃបន្ថែម និងការងារក្នុងផ្នែកមិនមែនកសិកម្ម។ | ២.៣.១ ទំហំផលិតកម្មកសិកម្មក្នុងកសិករម្នាក់ដែលប្រកបរបរកសិកម្ម(ស្រែចម្ការការចិញ្ចឹមសត្វនិងជលផល) | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រព័ន្ធព័ត៌មានរដ្ឋបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រចាំឆ្នាំ | តម្លៃនៃផលិតផលកសិកម្មក្នុងកសិករម្នាក់ដែលប្រកបរបរស្រែចម្ការ ការចិញ្ចឹមសត្វនិងជលផល ក្នុងមួយឆ្នាំ | តម្លៃនៃផលិតផលកសិកម្មសរុប (ពីស្រែចម្ការ ការចិញ្ចឹមសត្វ និងជលផល) នៅក្នុងឆ្នាំរាយការណ៍ | ចំនួនពលកម្មសរុបក្នុងវិស័យកសិកម្ម(ស្រែចម្ការ ការចិញ្ចឹមសត្វ និងជលផល) ក្នុងឆ្នាំរាយការណ៍ | MAFF |
| ២.៤ ត្រឹមឆ្នាំ២០៣០ ធានានូវប្រព័ន្ធផលិតកម្មស្បៀងអាហារដែលមានចីរភាព អនុវត្តសកម្មភាពកសិកម្មដោយមានការឆ្លើយតបនឹងការប្រែប្រួលអាសធាតុដែល ជួយឲ្យមានការកើនឡើងនូវផលិតកម្មនិងផលិតផល ជួយថែរក្សាប្រព័ន្ធអេកូឡូស៊ី ជួយពង្រឹងសមត្ថភាពសម្រាប់ធន់នឹងការប្រែប្រួលអាកាសធាតុអាក្រក់ ភាពរាំងស្ងួត ទឹកជំនន់ និងគ្រោះមហន្តរាយផ្សេងទៀត និងធ្វើឲ្យប្រសើរឡើងជាបន្តបន្ទាប់គុណភាពដី។ | ២.៤.១ ផលិតភាពដីកសិកម្មដែលបាននិងកំពុងប្រើប្រាស់ធ្វើកសិកម្មប្រកបដោយចីរភាព | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ទិន្នន័យរដ្ឋបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រចាំឆ្នាំ | តម្លៃផលិតផលកសិកម្មជាមធ្យម ក្នុងមួយហិកតា ក្នុងមួយឆ្នាំ | តម្លៃផលិតផលកសិកម្មសរុប នៅក្នុងឆ្នាំ | ផ្ទៃដីកសិកម្មសរុបដែលបាននិងកំពុងប្រើប្រាស់ធ្វើកសិកម្មប្រកបដោយចីរភាព នៅក្នុងឆ្នាំ | MAFF |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ២.៥ ត្រឹមឆ្នាំ២០២០ រក្សាការធ្វើពិពិធកម្មហ្សែននៃគ្រាប់ពូជការធ្វើកសិកម្ម និងចំការ ការផ្សាំពូជសត្វ និងប្រភេទសត្វព្រៃដែលពាក់ព័ន្ធ រួមទាំងតាមរយៈការគ្រប់គ្រងសមស្រប ការធ្វើពិពិធកម្ម និងរក្សាគ្រាប់ពូជ នៅកម្រិតជាតិ តំបន់ និងអន្តរជាតិ និងលើកកម្ពស់ការទទួលបានចំណែកប្រកបដោយយុត្តិធម៌ និងសមធម៌នៃផលប្រយោជន៍ពីការប្រើប្រាស់ធនធានហ្សែននិងចំណេះដឹងប្រពៃណីដែលពាក់ព័ន្ធ ដូចការឯកភាពជាអន្តរជាតិ | ២.៥.១ ចំនួនធនធានពន្ធុរុក្ខជាតិសម្រាប់ស្បៀងអាហារនិងកសិកម្មបានធានាក្នុងគោលនយោបាយយុទ្ធសាស្ត្រនិងទីកន្លែងអភិរក្សរយៈពេលមធ្យមឬរយៈពេលវែង | ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ក្រសួងបរិស្ថាន | ក្រសួងបរិស្ថាន/អគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ | រៀងរាល់៣ឆ្នាំ | ចំនួនធនធានពន្ធុរុក្ខជាតិសម្រាប់គាំទ្រវិស័យស្បៀងនិងកសិកម្ម | ចំនួនធនធានពន្ធុរុក្ខជាតិសម្រាប់ស្បៀងអាហារនិងកសិកម្មបានអភិវឌ្ឍនិងរក្សាទុក នៅត្រឹមឆ្នាំវាយការណ៍ | | MAFF |
| | ២.៥.២ ចំនួនគ្រួសារក្នុងសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានលើកកម្ពស់កម្រិតជីវភាព តាមរយៈការទទួលបានផលប្រយោជន៍ពី NTFP ការបញ្ចូលក្នុងវិស័យកសិកម្ម ទេសចរណ៍ធម្មជាតិ នៅក្នុងតំបន់ការពារ | ក្រសួងបរិស្ថាន | ក្រសួងបរិស្ថាន/អគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ<br>WWF, WCS | ប្រចាំឆ្នាំ | ចំនួនគ្រួសារក្នុងសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានលើកកម្ពស់កម្រិតជីវភាព ដោយផ្អែកលើផលិតផលព្រៃឈើ ជលផល កសិកម្មចម្រុះ និងការផ្តល់សេវាទេសចរណ៍ធម្មជាតិ ដល់ការអភិរក្សនិងអភិរក្សធនធានព្រៃជីវៈចម្រុះនិងនិរន្តរភាពនៃប្រព័ន្ធអេកូឡូស៊ី។ | ចំនួនគ្រួសារក្នុងសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានលើកកម្ពស់កម្រិតជីវភាព | | MAFF |
| ២.a បង្កើនការវិនិយោគ រួមទាំងតាមរយៈការលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងផ្នែកហេដ្ឋារចនាសម្ព័ន្ធជនបទ ការស្រាវជ្រាវនិងសេវាផ្សព្វផ្សាយកសិកម្ម ការអភិវឌ្ឍបច្ចេកវិជ្ជានិងធនាគារហ្សែនរុក្ខជាតិនិងសត្វ ដើម្បីលើកកម្ពស់សមត្ថភាពផលិតក្នុងប្រទេសកម្ពុជា។ | ២.a.១ លំហូរនៃហិរញ្ញប្បទានសរុប (ហិរញ្ញប្បទានសហប្រតិបត្តិការនិងលំហូរផ្សេងទៀត) ដល់វិស័យកសិកម្ម ធៀបនឹង ផ.ស.ស. ។ | គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា/ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | មូលដ្ឋានទិន្នន័យស្តីពីជំនួយអភិវឌ្ឍន៍ផ្លូវការដល់កម្ពុជា | ប្រចាំឆ្នាំ | ទំហំនៃការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់វិស័យកសិកម្ម តាមឆ្នាំនីមួយៗ ធៀបនឹង ផ.ស.ស. ក្នុងឆ្នាំនីមួយៗ | ទំហំនៃការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់វិស័យកសិកម្ម នៅក្នុងឆ្នាំ | ផ.ស.ស. សរុប នៅក្នុងឆ្នាំ | CRDB/CDC |

| គោលដៅទី៣ : ធានាឲ្យជីវិតរស់នៅរបស់ប្រជាជនប្រកបដោយសុខភាពល្អនិងលើកកម្ពស់សុខមាលភាពរបស់មនុស្សគ្រប់រូបនិងគ្រប់វ័យ | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៣.១ កម្រិតនៃការអភិវឌ្ឍនៃប្រទេសកម្ពុជា សុខភាពនិងសុខមាលភាពរបស់ប្រជាពលរដ្ឋ និងបង្ការហានិភ័យហិរញ្ញវត្ថុ | ៣.១.១ អាយុសង្ឃឹមរស់ពីកំណើត | ក្រសួងសុខាភិបាល | ក្រសួងផែនការ (ជំរឿន អង្កេតចន្លោះជំរឿន អង្កេតប្រជាសាស្ត្រនិងសុខភាព) | រៀងរាល់៥ឆ្នាំ | រយៈពេលមធ្យមនៃជីវិតរស់នៅរបស់ប្រជាជនម្នាក់ក្នុងប្រទេសមួយ គិតជាឆ្នាំ ដែលត្រូវបានគណនាពីពេលចាប់កំណើត រហូតដល់ស្លាប់ | | | MOH |
| | ៣.១.២ អត្រាលទ្ធភាពបង្កើតកូនសរុប (ចំនួនកូនកើតក្នុងស្ត្រីម្នាក់) | ក្រសួងសុខាភិបាល | ក្រសួងផែនការ (ជំរឿន អង្កេតចន្លោះជំរឿន អង្កេតប្រជាសាស្ត្រនិងសុខភាព) | រៀងរាល់៥ឆ្នាំ | គឺជាចំនួនកូនជាមធ្យម ដែល ត្រូវបានផ្តល់កំណើត ដោយស្ត្រីក្នុងវ័យបន្តពូជម្នាក់ | ចំនួនកូនដែលកើតរស់សរុបត្រឹមឆ្នាំរាយការណ៍ | ចំនួនស្ត្រីដែលស្ថិតក្នុងវ័យបន្តពូជ (១៥ដល់៤៩ឆ្នាំ) សរុប គិតត្រឹមឆ្នាំរាយការណ៍ | MOH |
| ៣.២ ត្រឹមឆ្នាំ២០៣០ កាត់បន្ថយអត្រាមរណភាពមាតានៅកម្រិតសាកល ឲ្យនៅកម្រិតទាបជាង ៧០ក្នុងចំណោម ១០០ ០០០ កំណើតរស់។ | ៣.២.១ អត្រាមរណភាពមាតា | ក្រសួងសុខាភិបាល | ក្រសួងផែនការ (ជំរឿន អង្កេតចន្លោះជំរឿន អង្កេតប្រជាសាស្ត្រនិងសុខភាព) | រៀងរាល់៥ឆ្នាំ | គឺជាចំនួននៃការស្លាប់របស់ស្ត្រីក្នុងវ័យបន្តពូជ ប្រចាំឆ្នាំ ដែលមកពីមូលហេតុណាមួយ ឬទាក់ទងនឹងភាពធ្ងន់ធ្ងរនៃផ្ទៃពោះឬការគ្រប់គ្រងខ្លួនផ្ទាល់(លើកលែងដោយមូលហេតុចៃដន្យនិងការជួបឧបទ្ទវហេតុ) អំឡុងពេលមានផ្ទៃពោះនិងសម្រាលកូនឬក្នុងរយៈពេល៤២ថ្ងៃក្រោយបញ្ចប់នៃការមានផ្ទៃពោះ ដោយមិនគិតពីរយៈពេលនិងទីតាំងនៃការមានផ្ទៃពោះ ក្នុងចំណោម ១០០ ០០០ កំណើតរស់ សម្រាប់ឆ្នាំកំណត់ជាក់លាក់។ | ចំនួននៃការស្លាប់របស់ស្ត្រីអាយុពី១៥-៤៩ឆ្នាំ នៅឆ្នាំរាយការណ៍ ដែលមកពីមូលហេតុណាមួយឬទាក់ទងនឹងភាពធ្ងន់ធ្ងរនៃផ្ទៃពោះឬការគ្រប់គ្រងខ្លួនផ្ទាល់ (លើកលែងដោយមូលហេតុចៃដន្យនិងការជួបឧបទ្ទវហេតុ) នៅអំឡុងពេលមានផ្ទៃពោះនិងសម្រាលកូន ឬក្នុងរយៈពេល៤២ថ្ងៃក្រោយបញ្ចប់នៃការមានផ្ទៃពោះដោយមិនគិតពីរយៈពេលនិងទីតាំងនៃការមានផ្ទៃពោះ | ចំនួនស្ត្រីអាយុពី១៥-៤៩ឆ្នាំ ដែលសម្រាលកូន(កើតរស់) នៅក្នុងឆ្នាំរាយការណ៍ | MOH |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | ៣.២.២ ភាគរយនៃការសម្រាលដោយបុគ្គលិកសុខាភិបាលមានជំនាញ | ក្រសួងសុខាភិបាល MOH | ក្រសួងសុខាភិបាល/ប្រព័ន្ធព័ត៌មានវិស័យសុខាភិបាល<br>ក្រសួងផែនការ (ជំរឿន អង្កេតចន្លោះជំរឿន អង្កេតប្រជាសាស្ត្រនិងសុខភាព) | ប្រចាំឆ្នាំ | ផ្តោតលើសមាមាត្រចំនួននៃការសម្រាលកូនដោយបុគ្គលិកសុខាភិបាលមានជំនាញ រួមមាន វេជ្ជបណ្ឌិត គ្រូពេទ្យជំនួយ ឆ្មប និងគិលានុបដ្ឋាកយិការ ដោយមិនរាប់បញ្ចូលឆ្មបបុរាណ (នៅមូលដ្ឋានសុខាភិបាលនិងនៅផ្ទះ)ក្នុងចំណោមចំនួននៃការសម្រាលកូនសរុប | ចំនួនសម្រាលកូនដោយបុគ្គលិកសុខាភិបាលមានជំនាញនៅក្នុងឆ្នាំរាយការណ៍ | ចំនួនស្ត្រីមានផ្ទៃពោះរំពឹងទុក | MOH |
